01408855

**E1/252.1**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de Premiere instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

# <u>ជំនុំជម្រះក្តីនៅដំណាក់កាលពីរ</u>

## <u>សាធារណៈ</u>

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៦នាទី**

**សវនាការលើកទី២៣៣**


**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 10-Mar-2017, 14:51
CMS/CFO: Sann Rada


**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន

*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)

*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ជា ស៊ីវហ៊ាង

កញ្ញា រ៉ូប៊ីនី ក្រូហ្វត៍ *(Ms. Robynne CROFT)*

លោក ម៉ាធូវ ម៉ាកាធី

*(Mr. Matthew McCARTHY)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន

*(Mr. Nicolas KOUMJIAN)*

លោក សេង ប៊ុនឃាង

កញ្ញា សុង ឆវ័ន្ត

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

លោក ស្រ៊ា រតនៈ

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី

*(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក សួន វិសាល

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរលក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក ហុង គីមសួន

លោក វ៉ែន ពៅ

លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

លោក យីគាំង លូ *(Mr. Yiqiang LIU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
| --- | --- |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| កញ្ញា សុង ឆរ័ន្ត | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក យីគាំង លូ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី អ៊ុំ សុផានី | ខ្មែរ |
| លោកស្រី ជូ គឹមឡូន | ខ្មែរ |

# ខ្លឹមសារ

**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី អ៊ុំ សុផានី** (2-TCCP-296)

សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី ............................................................ ទំព័រ ៤

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី............................................................ ទំព័រ ១៩

សួរដោយលោក គង់ សំអុន ផ្ដើមពី ............................................................ ទំព័រ ២២

សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី ............................................................ ទំព័រ ២៤

**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី ជុំ គឹមឡួន** (2-TCCP-238)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ............................................................ ទំព័រ៣៤

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្ដើមពី ............................................................ ទំព័រ ៣៦

សួរដោយកញ្ញា សុង ឆវ័ន្ត ផ្ដើមពី ............................................................ ទំព័រ ៥៩

សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ីយលី ផ្ដើមពី............................................................ ទំព័រ ៦៤

# កិច្ចដំណើរការនីតិវិធី

[០៩:០៦:៣៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ សុផានី បញ្ចប់ ហើយនិងចាប់ផ្ដើមស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបទៀត ដែលមានរហស្សនាម TCCP-238។

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដែលលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិត លះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ សុផានី លោកស្រីមានវត្តមាននៅក្នុងបន្ទប់សវនាការនេះរួចហើយ និងដើមបណ្ដឹងរដ្ឋប្ប-វេណីបម្រុងមួយរូបដែលមានរហស្សនាម 2-TCCP-238 មានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមុននឹងបន្តកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសម្រេចលើបញ្ហាមួយចំនួនទី១ គឺអង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគីឲ្យជ្រាបថា ការស្ដាប់សក្ខីកម្មសាក្សី អ៊ុំ សុផានី និង សាក្សីឬដើមបណ្ដឹងរដ្ឋប្បវេណីជាបន្តបន្ទាប់នៅថ្ងៃនេះ និងថ្ងៃបន្តបន្ទាប់នោះ អង្គជំនុំជម្រះថាសវនាការថ្ងៃនេះ និងថ្ងៃបន្តបន្ទាប់ លោក យូរ ឧត្ដរា ជាចៅក្រមជាតិអវត្តមាន ដោយមានមូលហេតុធុរៈផ្ទាល់ខ្លួនចាំបាច់គាត់មិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះបាន ហើយបន្ទាប់ពីយើងខ្ញុំបានពិគ្រោះយោបល់ជាមួយនឹងបណ្ដាចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចតែងតាំងលោកចៅក្រម ធូ មណី ដែលជាចៅក្រមបម្រុងខាងភាគីជាតិ ជំនួសចៅក្រម យូរ ឧត្ដរា ដែលមាន -- ដែលអវត្តមាន

រហូតដល់ពេលចៅក្រម យូរ ឧត្តរា មានវត្តមាន និងអាចមានលទ្ធភាពបំពេញការងារក្នុងការចូលរួមក្នុងកិច្ចដំណើរការសវនាការ ក្នុងអង្គជំនុំជម្រះសាលាដំបូងវិញបាន។ ការសម្រេចនេះ គឺផ្អែកតាមបទប្បញ្ញត្តិនៃវិធាន៧៩(៤) នៃវិធានផ្ទៃក្នុង អ.វ.ត.ក។

[០៩:០៩:៥៣]

ទី២ អង្គជំនុំជម្រះបានទទួលនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ នៅក្នុងបន្ទប់សវនាការនេះរបស់លោក នួន ជា ដោយគាត់បង្ហាញពីបញ្ហាសុខភាពរបស់គាត់ ដែលមិនអាចអង្គុយយូរបាន និងមិនអាចផ្ចង់អារម្មណ៍យូរបាន ហើយគាត់សុំលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់នៅក្នុងសវនាការនៅថ្ងៃនេះ និងគាត់សុំបន្តតាមដានកិច្ចដំណើរការសវនាការនៅខាងក្រោម។ ហើយការស្នើសុំនេះ ដោយមានការគាំទ្រអំពីអនុសាសន៍របស់លោកគ្រូពេទ្យដែលទទួលបន្ទុកពិនិត្យ ថែទាំព្យាបាល សុខភាពជនជាប់ចោទនៅ អ.វ.ត.ក នេះ។ គាត់បានផ្តល់អនុសាសន៍ថា -- បានធ្វើការកត់សម្គាល់ថា ស្ថានភាពសុខភាពមិនប្រែប្រួលទេ ប៉ុន្តែគាត់មិនអាចអង្គុយយូរបាន ហើយគប្បីអនុញ្ញាតឲ្យគាត់សម្រាក និងតាមដានកិច្ចដំណើរការសវនាការពីបន្ទប់រង់ចាំពីខាងក្រោមសាលសវនាការនេះ។

ដោយផ្អែកលើមូលដ្ឋាននៃពាក្យសុំ និងអនុសាសន៍របស់លោកគ្រូប្រចាំការនៅ អ.វ.ត.ក អង្គជំនុំជម្រះយល់ និងអនុញ្ញាតឲ្យលោក នួន ជា នៅបន្ត -- ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោម តាមរយៈប្រព័ន្ធសោតទស្សន៍ ហើយនិងបង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍តភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់លោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការពីចម្ងាយពីបន្ទប់ខាងក្រោមនៅ ក្នុងអំឡុងពេលសវនាការថ្ងៃនេះ។

ហើយទី៣ គឺសូមផ្តល់ភារកិច្ចទៅជូនទៅលោកស្រីចៅក្រម ហ្វេនស៍ ដើម្បីបញ្ជាក់ទៅលើសេចក្តីជំទាស់តវ៉ាពាក់ព័ន្ធនឹងការដាក់ឯកសារដេញដោលចុងក្រោយរបស់មេធាវីការពារក្តី នួន ជា គឺលោក វ៉ិចទ័រ កូប៉េ នាចុងម៉ោង កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៥ កន្លងមក។

សូមអញ្ជើញលោកស្រីចៅក្រម ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អង្គជំនុំជម្រះកត់សម្គាល់ឃើញថាមេធាវីការពារក្តីលោក នួន ជា បានសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ដែលយោងទៅរកឯកសារជាអត្ថបទសារព័ត៌មាន ដែលមិនទាន់បានដាក់ចូលក្នុងសំណុំរឿង <> ហើយ<>យកមកសួរតទល់ដើមបណ្តឹងរដ្ឋប្បវេណីពីខ្លឹមសារនៃឯកសារនេះ។ ហើយសហមេធាវី

នាំមុខក៏បានជំទាស់ ហើយក៏បានរំឭកគាត់អំពីទម្លាប់អនុវត្តរបស់អង្គជំនុំជម្រះពីដំបូង ដែលត្រូវដាក់ឯកសារនៅក្នុងឯកសារ *ស៊ែជ្រាយ* ដែលឲ្យភាគីផ្សេងៗបានដឹង។ ហើយអង្គជំនុំជម្រះសូមជូនដំណឹងរំឭកដល់ភាគីទាំងអស់ថាពីទម្លាប់អនុវត្តពីមុន វិធាន៨៧ បានចែងអំពីវិធានភស្តុតាង គឺថាភស្តុតាង ដែលយកមកដេញដោលអាចប្រើបាន លុះត្រាតែឯកសារដែលគោរពទៅតាមវិធាន៨៧(៤) ដែលឯកសារនោះ ភស្តុតាងនោះត្រូវបានដាក់ក្នុងសំណុំរឿង ហើយជូនដំណឹងទៅភាគី។

[០៩:១៣:២០]

ឥឡូវនេះ យើងផ្អែកទៅតាមឱកាសនោះ គឺថាអង្គជំនុំជម្រះបានទន់ភ្លន់ ឬក៏បត់បែន ទៅក្នុងការទទួលយកឯកសារតាមវិធាន៨៧(៤) បើបានបំពេញទៅតាមលក្ខខណ្ឌភាពដែលអាចរកបាន ពីមុនរកមិនបាន ឥឡូវរកបាន ឧទាហរណ៍។ ប៉ុន្តែ<នេះ មិនមែន>មានន័យថា យើងមិនចាំបាច់មានសេចក្តីសម្រេចលើអត្ថបទ នេះទេ ដើម្បីឲ្យអង្គជំនុំជម្រះអាចប្រើដេញដោលបាន ត្រូវតែដាក់ចូលនៅក្នុងឃ្លាំងឯកសាររួម ដើម្បីឲ្យភាគីបានទទួលបាន ហើយត្រូវដាក់ឲ្យបាន៤៨ម៉ោងមុន។ ដើម្បីសេចក្តីសង្ខេប។ ប្រសិនបើភាគីណាមួយចង់ប្រើឯកសារដែលមិនទាន់បានដាក់ចូលក្នុងសំណុំរឿងទេនោះ ហើយជាលក្ខណៈលើកលែងគឺថា បើមិនក្នុងសំណុំរឿងទេ គឺត្រូវដាក់ក្នុងឃ្លាំងឯកសាររួមដើម្បីឲ្យភាគី ឬក៏អង្គជំនុំជម្រះអាចវាយតម្លៃជា មុនសិន មុននឹងសម្រេចសេចក្តីទៅតាមវិធាន៨៧(៤)។ ហើយបន្ទាប់ពីការបំភ្លឺ<ទៅ>លោកមេធាវីការពារក្តី លោក នួន ជា <ហើយ វាច្បាស់ណាស់ថាសហ>មេធាវីនាំមុខ<ដើមបណ្តឹងរដ្ឋប្បវេណីបានរំឭកលោករួចហើយកាលពីថ្ងៃសុក្រ អំពី>ទម្លាប់<នៃការ>អនុវត្ត<នេះ។> <តើ>ឯកសារ<បាន>ដាក់ចូលក្នុងឃ្លាំងឯកសាររួម<ហើយឬនៅ?> ហើយ<បើដាក់រួចហើយ> <តើវា>មានសំណើ <ជាប់មកជាមួយទេ>?

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកចៅក្រម ហ្វេនស៍។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។ <សេចក្តីព្រាង>ប្រតិចារឹកនៃសវនាការមិនទាន់មាននៅឡើយទេ <>ហើយតាមអ្វីដែលយើងចាំច្បាស់នោះ គឺថាយុទ្ធសាស្ត្រដែលសួរសំណួររបស់ខ្ញុំ គឺលោក លោកស្រីចៅក្រមជ្រាបហើយ ខ្ញុំមិន<>មានចំណុចអ្វីដែលថាយោងទៅខ្លឹមសារនៃឯកសារនោះទេ។ ខ្ញុំប្រុងប្រយ័ត្នក្នុងការរៀបសំណួរ ហើយខ្ញុំមិនមានចេតនាដើម្បីបង្ហាញឯកសារនោះទេ។ សំណួររបស់ខ្ញុំ គឺថាតើសាក្សីបាននិយាយជាមួយភ្នំពេញប៉ុស្តិ៍ដែរឬទេ? បើថាមែន តើគាត់និយាយដែរឬអត់ថាគេបានបង្ខំឲ្យគាត់រៀបការ? ហើយគាត់ផ្តល់សម្ភាសន៍

នោះ អ៊ីចឹងហើយ។ ជាសំណួរទូទៅទេ ខ្ញុំ<>មិនបានមានចេតនាដាក់ឯកសារនៅក្នុងឃ្លាំងរួមនោះដែរ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<លោកមេធាវីការពារក្ដី តើលោកយល់ស្របទេថា លោកបានក្រោកឈរឡើង ហើយយកអត្ថបទឯកសាររបស់ភ្នំពេញប៉ុស្ដិ៍មកសួរថា "តើអ្នកស្រីបានប្រាប់ភ្នំពេញប៉ុស្ដិ៍ពីរឿងនេះ រឿងនោះឬទេ?" ពីព្រោះថា នេះជាអ្វីដែលខ្ញុំបានចាំពីទិដ្ឋភាពនៅពេលនោះ ហើយវាជាក់ច្បាស់ហើយថា វាមិនបានផ្ទុះបញ្ចាំងនៅក្នុងប្រតិចារឹកទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំបានលើកឯកសារហ្នឹងនឹងដៃ ប៉ុន្តែខ្ញុំមិនមានចេតនាដើម្បីបង្ហាញ ឬក៏ដាក់ដេញដោលនោះទេ។ ខ្ញុំគ្រាន់តែសួរទៅដើមបណ្ដឹងរដ្ឋប្បវេណីថាតើគាត់ពិតជាបានផ្ដល់បទសម្ភាសន៍<ជាមួយភ្នំពេញប៉ុស្ដិ៍> ឬមិនបានផ្ដល់បទសម្ភាសន៍ហ្នឹងតែប៉ុណ្ណឹងទេ លោកចៅក្រម។

[០៩:១៦:២០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ ហើយរួមទាំងក្រុមមេធាវីការពារក្ដីលោក នួន ជា ផង។ គឺមានពេលមួយវគ្គនៃសវនាការព្រឹកនេះ គឺពីពេលនេះទៅរហូតដល់ម៉ោងឈប់សម្រាក។ បាទ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកស្រី សុផានី។ លោកស្រីប្រហែលជាចាំ<>សំណួររបស់ខ្ញុំកាលពីថ្ងៃសុក្រកន្លងទៅនោះ សំណួរចុងក្រោយដែលខ្ញុំសួរលោកស្រីនោះ គឺថាតើចំណុចពេលណាមួយលោកស្រីបានផ្ដល់បទសម្ភាសន៍ទៅឱ្យកាសែតភ្នំពេញប៉ុស្ដិ៍ដែរឬទេ? ដែលលោកស្រីបានប្រាប់គេថានៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យថាគេបានបង្ខំឱ្យលោកស្រីរៀបការ។ សំណួរខ្ញុំ ខ្ញុំសួរថាតើលោកស្រីបាននិយាយបែបនោះទៅប្រាប់សារព័ត៌មានភ្នំពេញប៉ុស្ដិ៍ ដែរឬអត់?

**លោកស្រី អ៊ុំ សុផានី៖**

**ឆ៖** សូមគោរពលោកប្រធាន។ ខ្ញុំមិនចាំទេ។ ទាល់តែខ្ញុំអានឡើងវិញ។

[០៩:១៨:០០]

**ស៖** តើ<អ្នកស្រី>ចាំពីហេតុការណ៍ថាបានផ្តល់បទសម្ភាសន៍ ហើយសម្ភាសពីរឿងអ្វី ឬក៏មិនចាំអ្វីទាល់តែសោះ?

**ឆ៖** ខ្ញុំដឹងថាគេសម្ភាសពីសម័យខ្មែរក្រហម ពីព្រោះខ្ញុំបានបង្ហាញពីសៀវភៅកំណត់ហេតុថាខ្ញុំបានសរសេរនៅក្នុងសម័យនោះមែន។

**ស៖** សូមអរគុណដែលលោកស្រីបានឆ្លើយ។ លោកស្រី សុផានី ខ្ញុំសួរលោកស្រីជាទូទៅ ថាតើលោកស្រីបានឆ្លើយទៅខាងសារព័ត៌មាន ឬក៏អ្នកណាផ្សេងទៀតថា<> គេបានបង្ខំឱ្យលោកស្រីរៀបការទេ ក្នុងពីឆ្នាំ១៩៧៥ ដល់ ១៩៧៩។ <> តើធ្លាប់បាននិយាយប្រាប់អ្នកណាដែរឬទេ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំទាន់អាលឆ្លើយតប។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអរគុណ ហើយសរសើរដែលមេធាវីមិនមានចេតនាដាក់ឯកសារនេះចំពោះអង្គជំនុំជម្រះ។ ប៉ុន្តែទោះយ៉ាងណាក្តី យើងជំទាស់ទៅលើការសួររបស់មេធាវីការពារក្តីដែលផ្អែកទៅលើសំណួរទៅលើឯកសារ។ ប៉ុន្តែការតាំងសំណួរនេះ ហាក់ដូចជាផ្អែកទៅលើឯកសារ <ដោយមិនបានទទួលបានការកត់សម្គាល់ និងដោយមិនបានដាក់ឯកសារនេះចំពោះអង្គជំនុំជម្រះ>។ <មូលហេតុគឺដោយសារ បើសិនជា>លោក<ពិតជា>បានអានខ្លឹមសារ<ពីក្នុងអត្ថបទសារព័ត៌មាននេះនូវចម្លើយផ្តល់ទៅសាក្សីថា គាត់មិនបាននិយាយថា គេបានបង្ខំឱ្យរៀបការទេ> <វាជាអត្ថបទរបស់អ្នករាយការណ៍ព័ត៌មាន។ ឥឡូវនេះ ដោយសារមិនបានដាក់ឯកសារនេះចូលទៅក្នុងសំណុំរឿង តាមតួនាទីរបស់លោក វាមានន័យថា វាអនុញ្ញាតឱ្យលោក>ធ្វើឱ្យសាធារណជន <រួមទាំងសាក្សី និងអង្គជំនុំជម្រះផង យល់>ច្រឡំហើយ។ <អ្វីទាំងអស់ដែលយើងស្នើសុំ គឺការកត់សម្គាល់។ ប្រសិនបើគេបានអានបទសម្ភាសន៍នេះក្នុងពេលបាយថ្ងៃត្រង់ នៅសវនាការវគ្គចុងក្រោយ ត្រូវផ្តល់ការកត់សម្គាល់ថាយើងមានបំណងប្រើប្រាស់ឯកសារនេះ។ យើងមិនដែលពឹងផ្អែក>ទៅតាមគោលការណ៍វិធាន ៨៧(៤)

<ដើម្បី>ជំទាស់<ភស្តុតាងពាក់ព័ន្ធ>ទេ<។ យើងពេញចិត្តនឹងភាពបត់បែន ដែលចៅក្រម ហ្វេនស៍ បាននិយាយ។ អ្វីដែលយើងស្នើសុំ គឺថានេះមិនមែនជាការជំនុំជម្រះក្តី ដែលធ្វើឡើងដោយការពួនស្ទាក់វាយនោះទេ គឺថាគេផ្តល់ការកត់សម្គាល់ នៅពេលគេរកឃើញភស្តុតាងណាមួយ ដែលគេចង់ប្រើវា។>

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២២:១៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកស្រីចៅក្រមហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ឥឡូវនេះយើងបានចូលដល់ស្ថានភាពមួយដែលថា ឯកសារមិនទាន់បានដាក់ចូលក្នុងសំណុំរឿង ហើយ<ខ្លឹមសារនៃអត្ថបទនេះ> ត្រូវបាន<>ភាគី<ជជែកគ្នាដោយមិនចុះសម្រុង>។ អង្គជំនុំជម្រះមិនទាន់បានទទួលឯកសារនោះទេ។ ហើយស្ថានភាពនេះយើងមិនអាចអនុញ្ញាតឲ្យបន្តទេ ដូច្នេះមេធាវីការពារក្តីប្រសិនបើយើងចង់សួរសំណួរណាផ្អែកទៅលើឯកសារនេះ គឺថាសុំឲ្យដាក់ដេញដោលចំពោះមុខអង្គជំនុំជម្រះ។ បើលោកមិនដាក់ឯកសារនេះទេ យើងមិនអនុញ្ញាតឲ្យលោកសួរបន្តទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកស្រីចៅក្រម ហ្វេនស៍ បើសិនជាអង្គជំនុំជម្រះស្នើបែបនេះ ខ្ញុំរីករាយនឹងដាក់ចូល។ ប៉ុន្តែសំណួរនេះត្រូវបានជំទាស់ ហើយដែលខ្ញុំសួរនោះ មិនសួរផ្អែកលើឯកសារនេះទៀត។ ហើយខ្ញុំបានចាប់ផ្តើមកម្រងវិធីសាស្ត្រសួរខ្ញុំថ្មីទាំងស្រុងទៅហើយ បាទ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី ប៉ុន្តែលោកចាប់ផ្តើមតាំងសំណួរផ្អែកលើអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអត់? <ឬក៏ការតាំងសំណួរពាក់ព័ន្ធទៅនឹងការដែលគាត់បាននិយាយជាមួយ>ភ្នំពេញប៉ុស្តិ៍<>។ <ឥឡូវនេះសហព្រះរាជអាជ្ញាបានប្រាប់អង្គជំនុំជម្រះថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមិនបាននិយាយដូច្នោះទេ។> ប៉ុន្តែចាប់ពីពេលនេះទៅដែលថា ដែលលោកសួរទាក់ទងទៅនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ គឺថាអាចនឹងផ្អែកទៅលើអត្ថបទឯកសារនោះឯង។ <ដូច្នេះ លោកត្រូវដាក់ឯកសារនេះចំពោះមុខអង្គជំនុំជម្រះ ហើយធ្វើសំណើសុំ បើសិនជាលោកមានចេតនាចង់ប្រើប្រាស់វា។>

[០៩:២៤:០៩]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកស្រីចៅក្រម ហ្វេនស៍! គាត់មិនត្រឹមតែប្រាប់ភ្នំពេញប៉ុស្តិ៍ <អំពីការរៀបការដោយបង្ខំនោះទេ> គាត់ហាក់ដូចជាបានប្រាប់សាធារណជនឲ្យដឹងតាមរយៈការសរសេរ តាមសម្ភាសន៍របស់គាត់នោះ។ <ខ្ញុំពិតជារីករាយ បើសិនជាលោកស្រីចៅក្រមចង់ឲ្យខ្ញុំដាក់ឯកសារផ្សេងៗទៀតចំពោះមុខចៅក្រមនោះ។ ខ្ញុំគ្មានបញ្ហាអីក្នុងរឿងនេះទេ។>

**លោក ឌេល លីសាក់៖**

ប្រសិនបើមេធាវីថា មានឯកសារផ្សេងៗទៀត ឬក៏សម្ភាសន៍ផ្សេងទៀត គឺមេធាវីមានភារកិច្ចក្នុងការផ្តល់ឯកសារហ្នឹងមកអង្គជំនុំជម្រះ។ <នោះហើយជាអ្វីដែលយើងស្នើសុំ។ យើងមិនប្រឆាំងទៅនឹងភស្តុតាងពាក់ព័ន្ធដែលដាក់ស្នើសុំចំពោះមុខអង្គជំនុំជម្រះនោះទេ គឺយើងគ្រាន់តែចង់ឲ្យមានការកត់សម្គាល់តែប៉ុណ្ណោះ>។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនមានបញ្ហានឹងប្រគល់ជូនទេ។ ហើយតាមពិត គឺឯកសារ មានឯកសារមួយចំនួនបីបួន បាទនេះៗអត្ថបទភ្នំពេញប៉ុស្តិ៍ ហើយនេះសេចក្តីប្រកាសព័ត៌មានពីអង្គការមួយ គឺសមាគមអតីត<ជនរងគ្រោះ>ខ្មែរក្រហមនៅកម្ពុជា <ដែលសាក្សីរូបនេះជាសមាជិកអចិន្ត្រៃយ៍>។ ហើយ<ខ្ញុំមាន>ឯកសារ<មួយទៀតមកពី>វិទ្យុជាតិ <> ហើយ<ខ្ញុំក៏បានរកឃើញឯកសារ>មួយទៀតជាសៀវភៅតូចមួយ គឺនិយាយអំពី“ក្រោមតំណក់ភ្លៀង” ដែលជាសៀវភៅរបស់ដើមបណ្តឹងរដ្ឋប្បវេណី<បដិសេធមិនផ្តល់ឲ្យខ្ញុំប៉ុន្តែ>ដែលខ្ញុំទទួលបានពីជនម្នាក់ដែលមានសប្បុរសចិត្ត សប្បុរសធម៌ ហើយឥឡូវហ្នឹងខ្ញុំមាន<សៀវភៅនេះ> ហើយខ្ញុំសូមដាក់ជូន<>ឯកសារសៀវភៅ<“ក្រោមដំណក់ភ្លៀង”> ជារឿងមិនមែនប្រឌិតទេ។ <ហើយខ្ញុំសូមដាក់វាចូលទៅក្នុងសំណុំរឿង។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

យើងមានសំណួរពីរទៅលោក។ ថាតើឯកសារនេះបានដាក់មាននៅក្នុងសំណុំរឿងហើយឬនៅលោកមេធាវី?

**លោក វ៉ិចទ័រ កូប៉េ៖**

មិនទាន់មានទេ។

[០៩:២៦:០៨]

01408866



**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើលោកបានដឹងអំពីទម្លាប់អនុវត្តតាមវិធានផ្ទៃក្នុង គឺថានីតិវិធីនេះគឺថាលោកត្រូវជូនដំណឹង៤៨ ម៉ោង មុនៗនឹងលោកដាក់ដេញដោលនៅនៅទីនេះទេ?

**លោក វ៉ិចទ័រ កូប៉េះ៖**

លោកស្រីចៅក្រមខ្ញុំដឹងហើយ! នេះគឺថាអាចជាស្ថានភាពខុសគ្នា បើសិនជាសាក្សីរបស់សហព្រះរាជអាជ្ញា<។ គ្រាន់តែ៥នាទីមុនពេលចូលក្នុងបន្ទប់សវនាការ មេធាវី>ដើមបណ្ដឹងរដ្ឋប្បវេណីក៏បានជជែក បានពិភាក្សាជាមួយមេធាវីរបស់គាត់ <ហើយទទួលបានការណែនាំនៅនាទីចុងក្រោយ។> ហើយ<បើ>ខ្ញុំ<>ចង់<ការពារមិន>ឲ្យមានការណែនាំសាក្សីនេះ <ខ្ញុំនឹងមិនធ្វើដូច្នេះទេ>។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ដូច្នេះលោកកំពុងសួរសំណួរដោយផ្អែកលើ>ទម្លាប់អនុវត្តនីតិវិធី<។ លោកកំពុងនិយាយថាលោកមិនគោរពតាមទម្លាប់អនុវត្តទេ ក្នុងករណីខ្លះ>--

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំគោរពទៅតាមវិធានផ្ទៃក្នុងស្ដីពីទម្លាប់អនុវត្ត។ ប៉ុន្តែដើមបណ្ដឹងរដ្ឋប្បវេណីហាក់ដូចជាបានទទួលការណែនាំពីមេធាវីរបស់គាត់ថាត្រូវឲ្យធ្វើម៉េច? ដូច្នេះ <ជាការពិត> ខ្ញុំ<មិនមានឆន្ទៈគោរពតាមទម្លាប់អនុវត្តនោះទេ។ ហើយសំណួររបស់ខ្ញុំគឺជាសំណួរសាមញ្ញធម្មតា អំពីថាតើគាត់បាននិយាយជាមួយអ្នកសារព័ត៌មានទេ?> ខ្ញុំមិនបាន<ចង់>ដាក់<បង្ហាញ>ឯកសារ<ទេ>។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ឥឡូវនេះគឺថា លោកចង់និយាយថាលោកមិន<ចង់>គោរពទៅតាមទម្លាប់អនុវត្តវិធានផ្ទៃក្នុងរបស់តុលាការទេ <សម្រាប់ភស្តុតាង>បែបនេះ? <តើខ្ញុំយល់ត្រឹមត្រូវទេ?>

**លោក វ៉ិចទ័រ កូប៉េះ៖**

<គឺគ្រាន់តែក្នុងស្ថានភាពមួយ ដែល>ខ្ញុំ<ពិតជាចង់ឲ្យ>ដាក់ឯកសារចូលក្នុងសំណុំរឿង<។> ខ្ញុំ<មិនមានចេតនាចង់>ស្នើដាក់<ឯកសារ>ចូលក្នុងសំណុំរឿង<ទេ>។

[០៩:២៧:៤៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ហើយមុននឹងផ្ដល់វេទិកាជូន

ដល់លោកស្រី យើងសូមរំឭកលោកស្រីថា បន្ទាប់ពីស្ដាប់នូវភាគីម្ខាងទៀតដែលលើកឡើងមានមូលហេតុ ផ្សេងៗដែលភាគីលោកស្រីមិនពេញចិត្ត ហើយគិតថាសំណួរបែបនោះគឺមិនត្រឹមត្រូវ លោកស្រីគប្បីធ្វើការជំទាស់ព្រមគ្នាទន្ទឹមគ្នាជាមួយនឹងសហព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាធ្វើសេចក្ដីជំទាស់រួចលោកស្រី អាចធ្វើបន្ទាប់ទៀត បើលោកស្រីធ្វើរបៀបនេះភាគីម្ខាងទៀតនឹងអាចមានឱកាសឆ្លើយពីរបីដងឯណោះ ឆ្លើយតបនឹងការដែលតវ៉ារបស់លោកស្រី។ អ៊ីចឹងនីតិវិធីហ្នឹង គឺគ្រាន់តែឆ្លើយតវ៉ាឥឡូវគឺអស់កន្លះម៉ោងទៅហើយ ប្រសិនជាដើមបណ្ដឹងរដ្ឋប្បវេណីមួយ ឬសាក្សីមួយតវ៉ាគ្នា ហើយសម្រេចលើការការតវ៉ាជំទាស់តវ៉ាលើរបៀបតាំងសំណួរ កន្លះម៉ោងនោះ ការកំណត់ស្ដាប់សក្ខីកម្មសាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ដែលចំណាយពេលមួយថ្ងៃនោះទំនងជាធ្វើទៅមិនបានទេ ហើយពេលវេលាអាចកើនតាមហ្នឹងដែរ បើធ្វើ ២០០ថ្ងៃ វាអាចដល់២៥០ថ្ងៃឯណោះទម្រាំតែចប់ បើធ្វើបែបនេះ។ សូមរំឭកថាលោកស្រីមានឱកាសក្នុងការតវ៉ាស្ដាប់ឲ្យហើយ ហើយតវ៉ានៅក្នុងអំឡុងពេលបន្ទាប់គ្នា។ បានន័យភាគីម្ខាងទៀត គឺមានអាចបញ្ជាក់លើបញ្ហាខ្លួន ជំហរខ្លួនតវ៉ាលើការតាំងសំណួរឬក៏យ៉ាងម៉េចដើម្បីឲ្យអង្គជំនុំជម្រះហ្នឹងបានសម្រេចបញ្ហានោះតែម្ដង។ សូមអញ្ជើញប្រគល់វេទិកា។

[០៩:២៩:២៦]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធានចំពោះការរំឭកអំពីនីតិវិធីដែលខ្ញុំមិនដឹងនេះ។ <ខ្ញុំចង់មានប្រតិកម្មតបចំពោះអ្វីដែលលោក កូប៉េ បានលើកឡើងដែរ>បន្ទាប់ពីសហព្រះរាជអាជ្ញាបាននិយាយ<រួច> ក៏ប៉ុន្តែខ្ញុំងើបវាមិនទាន់។ ខ្ញុំសូមជំទាស់ដាច់ខាតទៅនឹងអ្វីដែលមេធាវី កូប៉េ ទើបតែបង្ហាញឯកសារដែលអត់បានផ្ដល់ជូនភាគីជាមុននេះ។ នេះវាផ្ទុយទៅនឹងវិធានរបស់យើងទាំងស្រុងហើយ<នៅក្នុងតុលាការនេះ។> គាត់ត្រូវតែប្រគល់ឯកសារឲ្យពួកយើងមុនពេលសវនាការ ពីព្រោះថា យើងស្ថិតនៅក្នុង<សវ-នាការ>សាធារ<ណៈ ដូច្នេះ វាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់>យើងត្រូវតែដឹងអំពីឯកសារទាំងអស់ដែលផ្ដល់ជូនអង្គជំនុំជម្រះ។

ដូច្នេះ ខ្ញុំជំទាស់ចំណុចនេះទាំងស្រុង <ទៅនឹងមេធាវីការពារក្ដី ក្នុងការដាក់បង្ហាញឯកសារដែលមិនធ្លាប់បានបញ្ជាក់ពីមុនមក>។ ហើយ<លោកមេធាវីរូបនេះកំពុងតែប្រជែងនឹង>វិធានរបស់អង្គជំនុំជម្រះ<ហើយ។> <>ដើមបណ្ដឹង<រដ្ឋប្បវេណី>គឺជាភាគី មិនមែនជាសាក្សីទេ។ <មេធាវីមានសិទ្ធិទាក់ទងជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណី ហើយ>ខ្ញុំសូមរំឭក<អ្នកទាំងអស់គ្នា>ថាលោកស្រី អ៊ុំ

សុផានី <>មិនមែនជាសាក្សី<ឲ្យដើមបណ្តឹងរដ្ឋប្បវេណីនោះ>ទេ គាត់ជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អង្គជំនុំជម្រះ។ គឺអង្គជំនុំជម្រះជាអ្នកសម្រេច <កោះហៅបុគ្គលទាំងឡាយ ដូច>ជាដើមបណ្តឹងរដ្ឋប្បវេណី<>ជាសាក្សី ឬក៏ជា<អ្នក>ជំនាញ ដែលត្រូវកោះហៅមកស្តាប់សក្ខីកម្ម។ <>មិន<មាន>ជាសាក្សីរបស់ព្រះរាជអាជ្ញា ឬក៏ជាសាក្សីរបស់មេធាវីការពារក្តីទេ<។ <មានសាក្សី សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ>ដែលអង្គជំនុំជម្រះបានជ្រើសរើសដោយខ្លួនឯង។ ដូច្នេះ មេធាវីការពារក្តី <នួន ជា អាចរស់ស្រួលនៅក្នុងពិភពស្រមើស្រមៃរបស់ខ្លួនបាន> ហើយ<បង្កើត>វិធាន<>ស្រមើស្រមៃ<របស់ខ្លួន ទោះយ៉ាងណាក្តី>យើងត្រូវ<តែគោរព>ទៅតាមវិធានរួម ដែល<នឹងគ្រប់គ្រងនីតិវិធីទាំងនេះ។ ប៉ុន្តែអ្វីដែលទើបតែបានកើតឡើងនេះ គឺវាផ្ទុយទាំងស្រុងទៅនឹងអ្វីដែលបានព្រមព្រៀងគ្នានៅក្នុងតុលាការនេះ>។

[០៩:៣១:២៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមឆ្លើយតបដោយសង្ខេបលោកប្រធាន។ ជាទូទៅ គឺថាខ្ញុំមានការភ្ញាក់ផ្អើលណាស់នៅពេលដែលអង្គជំនុំជម្រះប្រើនូវឆន្ទានុសិទ្ធិដែលថាឲ្យដាក់ឯកសារទាក់ទងទៅនឹងសក្ខីកម្មរបស់សាក្សីនៅសប្តាហ៍ក្រោយ <ហើយអ្នកជំនាញនៅ>មួយសប្តាហ៍ខាងមុខទៅទៀត ហើយអង្គជំនុំជម្រះបាន<>រៀបចំហើយនិងកោះអញ្ជើញសាក្សី និងអ្នកជំនាញ <ខ្ញុំពិតជារីករាយដែលធ្វើដូច្នោះ>។ ប៉ុន្តែចំពោះឯកសាររបស់សាក្សីហ្នឹង មិនមែនជាវិធីសាស្ត្រអ្វីស្មុគស្មាញនោះទេ<គ្រាន់តែវាយឈ្មោះគាត់ចូលទៅ *ហ្គូហ្គល*> គឺថាមានឯកសារជាច្រើន<> ទោះបីជាសិស្សសាលាក្មេងៗក៏អាចរកបានតាមប្រព័ន្ធអ៊ីនធឺណេតដែរ។ អ៊ីចឹង<បើសិនវាពិតជាសំខាន់មែន> សំណួរដែលខ្ញុំសួរ<ទៅ>លោកប្រធាន ហើយលោក លោកស្រីចៅក្រម ថាតើ<ហេតុអ្វីបានជាលោក> លោកស្រីចៅក្រម<មិនដាក់ឯកសារនោះដោយខ្លួនឯងទៅ?>។

[០៩:៣២:៣៧]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣៥:៥៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មុននឹងបញ្ចប់ពីការសម្រេច គឺថាអង្គជំនុំជម្រះសូមសង្កត់ធ្ងន់ថា នេះជាករណីពិសេស។ យើងនឹងមិនអនុញ្ញាតឱ្យហេតុការណ៍នេះកើតម្តងទៀតទេ។ <មូលហេតុដែលយើងចាត់ទុកថា> នេះជាករណីលើកលែង ដោយសារថាយើងនៅ<ពេល>ចាប់ផ្តើមនៃរឿងក្តី០០២/<>០២ <ភាគីខ្លះអាច>នឹង<ភ្លេចពី>នីតិវិធីអនុវត្ត។ <>យើង<សង្ឃឹម>ថា <ការដែល>មេធាវីការពារក្តីរបស់លោក នួន ជា <>បាន<>ថ្លែងថា <>គាត់មានចេតនាចង់<>ប្រឆាំងនឹងនីតិវិធី គឺ<វាមិនធ្ងន់ធ្ងរដូចអ្វីដែលគាត់និយាយនោះទេ>។ ហើយ<អ្វីដែលយើងនឹងធ្វើ>នៅក្នុងករណីនេះ<គឺនៅក្នុងករណីនេះ>តែប៉ុណ្ណោះ គឺដូចតទៅនេះ គឺមិនអនុញ្ញាតឱ្យសួរសំណួរណាមួយដែលផ្អែកលើឯកសារ <>ដែលមិនស្ថិតក្នុងសំណុំរឿងឱ្យសួរទេ។ ប៉ុន្តែទោះជាយ៉ាងណាក្តី ដូចដែលថាជាការលើកលែងនុង បើសិនជាមេធាវីការពារក្តីរបស់លោក នួន ជា គិតថាគាត់មានឯកសារដែលបំពេញទៅតាមវិធាន៨៧នោះ ខ្លួននឹងត្រូវដាក់ចូលនៅក្នុងឃ្លាំងឯកសាររួមក្នុងរយៈពេល៤៨ម៉ោង ហើយត្រូវដាក់សំណើមកអង្គជំនុំជម្រះតាមវិធាន៨៧(៤) ដើម្បីអនុញ្ញាតឱ្យអង្គជំនុំជម្រះអាចមើលឯកសារទាំងអស់នេះ ហើយអាចនិងធ្វើសេចក្តីសម្រេចបាន ហើយឱ្យភាគីធ្វើយោបល់។ ហើយបើមានភាពចាំបាច់ <>យើងនឹងអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីដើម្បីឱ្យសួរទាក់ទងនឹងឯកសារទាំងអស់នេះ ឱ្យមេធាវីអាចសួរ បាន។ ដូច្នេះចំពោះក្នុងពេលនេះគឺមិនអនុញ្ញាតឱ្យសួរសំណួរទៅលើឯកសារទាំងឡាយណាដែលមិនទាន់ បានដាក់ចំពោះមុខអង្គជំនុំជម្រះនោះទេ។

[០៩:៣៨:១៤]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រី សុផានី សំណួររបស់ខ្ញុំនុង ខ្ញុំចង់សួរទៅលោកស្រី<គឺ>ថា <>តើលោកស្រីជាសមាជិក<ស្ថាបនិក>របស់សមាគម<>អ្នករងគ្រោះពីសម័យខ្មែរក្រហមហ្នឹងដែរឬទេ?

**លោកស្រី អ៊ុំ សុផានី៖**

**ឆ៖** ចាស។

**ស៖** តើលោកស្រីអាចជម្រាបតុលាការបន្ថែមលម្អិតដែរឬទេអំពីសមាគមនេះ ថាតើមានសមាជិក ឬក៏គណៈនាយក អ្នកណាខ្លះ ហើយភារកិច្ចធ្វើអ្វីខ្លះដែរឬទេ គោលបំណងនោះ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលឆ្លើយតប។

សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទសូមគោរពលោកប្រធាន ខ្ញុំ -- ខ្ញុំមិន -- បញ្ហានេះ ដែលៗសួរទៅលើដើមបណ្ដឹងរដ្ឋប្បវេណីនេះ ខ្ញុំគិតថាមិនមែនជាបញ្ហាដែលពាក់ព័ន្ធទៅនឹងព័ត៌មានសម្រាប់បង្ហាញការពិតទេ។ ហើយខ្ញុំជឿថាលោកមេធាវីរបស់លោក នួន ជា ត្រូវការសួរសំណួរដែល ដើម្បីបញ្ជាក់អំពីសុច្ចរិត -- ភាពជឿជាក់នៃសក្ខីកម្មរបស់លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ក៏ប៉ុន្តែខ្ញុំជឿថា អាចមានព័ត៌មានផ្សេងទៀតដែលជាព័ត៌មានអាចបង្ហាញនូវការពិត ហើយដែលគាត់អាចសួរលើបញ្ហានោះ ដើម្បីសួរ -- ពិនិត្យលើភាពជឿជាក់របស់លោកស្រីនេះ។ បាទ ដូច្នេះ បញ្ហានេះខ្ញុំជឿថាមិនសំខាន់សម្រាប់សវនាការយើងទេ។ សូមអរគុណលោកប្រធាន។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤០:៤៦]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<លោកមេធាវីការពារក្ដី នៅពេលនេះលោកត្រូវបានអនុញ្ញាតឲ្យសួរសំណួរមួយ ឬពីរបន្ថែមទៀត ប៉ុន្តែវាអាចជួយផងដែរ បើយើងបានយល់ភ្លាមៗថា តើសំណួរនោះមានការពាក់ព័ន្ធគ្នាយ៉ាងម៉េច។>

**លោក វ៉ិចទ័រ កូប៉េ៖**

<លោកស្រីសាក្សី តើលោកស្រីនៅចាំសំណួរខ្ញុំទេ?>

**ប្រធានអង្គជំនុំ៖**

លោកៗ កូប៉េ និយាយម្ដងទៀត អត់ៗមានការបកប្រែទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ ខ្ញុំនឹងសួរម្ដងទៀត លោកស្រី សុផានី។ លោកស្រីចាំសំណួរទេ សំណួរខ្ញុំនិយាយអំពីសមាគមជនរងគ្រោះនៅក្នុងប្រទេសកម្ពុជា។ <តើលោកស្រីជាសមាជិកម្នាក់នៅក្នុងសមាគមនោះដែរទេ? បើសិនជាអ៊ីចឹង> តើលោកស្រី<អាចប្រាប់យើងពី>សមាគមមួយនេះ<បន្តិចបាន>ទេ?

**លោកស្រី អ៊ុំ សុផានី៖**

**ឆ៖** ខ្ញុំមិនចាំទេ ប៉ុន្តែខ្ញុំគ្រាន់តែខ្ញុំមានសរសេរកត់ទុកនៅក្នុងសៀវភៅកំណត់ហេតុរបស់ខ្ញុំ។

**សៈ** លោកស្រី តើលោកស្រី<ចង់និយាយថា លោកស្រីមិនមែន>ជា<សមាជិករបស់> សមាគម<នេះ> ឬក៏<>ជាមន្ត្រីណាមួយនៅក្នុងសមាគមនេះ<>ទេ <មែនទេ>?

**ឆៈ** ខ្ញុំគ្រាន់តែសមាជិកនៅក្នុងសមាគម។

**សៈ** លោកស្រីដឹងទេ ថាតើអ្នកណាជាប្រធានសមាគមនេះ?

**ឆៈ** ខ្ញុំសូមមិនឆ្លើយ។ ខ្ញុំសូមមិនឆ្លើយ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៤:៥៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី កូប៉េ លោកប្រធានបានឲ្យ<ខ្ញុំ>សួរទៅលោកដើម្បីឲ្យបញ្ជាក់ ថាតើលោកសួរសំណួរបែបហ្នឹងមានការជាប់ពាក់ព័ន្ធបែបណាដែរបានជាសួរបែបនេះ?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំរីករាយជម្រាបជូនលោកស្រីចៅក្រម។ ខ្ញុំគិតថាដើមបណ្ដឹងរដ្ឋប្បវេណីនិយាយភាសាអង់គ្លេសបានច្បាស់ណាស់។ ខ្ញុំនឹងពន្យល់ទៅលោកស្រី <ដោយមិនបាច់ឲ្យ>ដើមបណ្ដឹងរដ្ឋប្បវេណី <ឮអ្វីដែលខ្ញុំនឹងនិយាយទេ>។

**ប្រធានអង្គជំនុំ៖**

ចូរលោកបង្ហាញពីភាពពាក់ព័ន្ធ លោក -- អង្គជំនុំជម្រះចង់ដឹងថាសំណួរដែលលោកសួរប៉ុន្មានសំណួរចុងក្រោយនេះ វាមានភាពពាក់ព័ន្ធទៅនឹងអង្គហេតុនៃសហករណ៍ត្រាំកក់នៃការ -- គោលដៅនៃការ នៃពុទ្ធសាសនិកជន ហើយនិងកន្លែងសម្លាប់មនុស្សនៅក្រាំងតាចាន់ហ្នឹង នៅក្រាំងតាចាន់ហ្នឹងយ៉ាងដូចម្ដេចខ្លះ ដើម្បីឲ្យយើងសម្រេចថាតើឲ្យលោកសួរសំណួរបន្តទៅទៀត ឬក៏ឲ្យលោកឈប់សួរសំណួរនេះ អាចប្ដូរសំណួរផ្សេងទៀតដែលពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់ឲ្យធ្វើសវនាការ។

[០៩:៤៦:២៥]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ អរគុណលោកប្រធាន។ សំណួរហ្នឹង ទី១គឺសួរដោយផ្ទាល់ដើម្បីចង់ដឹងអំពីភាពគួរឲ្យទុកចិត្តបាននៃដើមបណ្តឹងរដ្ឋប្បវេណី <ទី២>គឺពាក់ព័ន្ធនឹងឧ<ក្រិ>ដ្ឋកម្មនៃអាពាហ៍ពិពាហ៍ដោយបង្ខំជាទូទៅ។ ភាពទូទៅនៃសំណួរទាំងនេះ គឺថាអ៊ីចេះ សាក្សីគឺជាសកម្មជនម្នាក់នៃសមាគមនេះ ហើយនៅខែមិថុនា ឆ្នាំ២០១១ ក្នុងពេលចាប់ផ្តើមសវនាការបឋម ដើមបណ្តឹងរដ្ឋប្បវេណីជាមួយនឹងប្រធានសមាគមធារី សេង បានចេញសេចក្តីប្រកាសព័ត៌មានបញ្ជាក់អំពីរឿងផ្ទាល់ៗខ្លួន របស់សមាជិកក្រុមៗប្រឹក្សាភិបាលនៃសមាគមហ្នឹង <រួមបញ្ចូលទាំងរឿងរ៉ាវផ្ទាល់ខ្លួនរបស់សាក្សីនេះ> ដែលបានបញ្ជាក់<ច្បាស់លាស់>ថាគាត់ត្រូវបានគេរៀបការដោយបង្ខំ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក កូប៉េ បន្តការតាំងសំណួររបស់លោកចំពោះដើមបណ្តឹងរដ្ឋប្បវេណី។ ហើយសូមរំឭកលោកថា លោកគប្បីគិតគូអំពីពេលវេលាសម្រាប់មេធាវីការពារក្តី ខៀវ សំផន ផង។

**សួរដោយលោក រ៉ិចឆ័រ កូប៉េ៖**

**ស៖** លោកស្រី សុផានី ខ្ញុំយល់មិនទាន់ច្បាស់ទេចំពោះសំណួរចុងក្រោយរបស់ខ្ញុំ។ គឺខ្ញុំចង់សួរលោកស្រី ថាតើលោកស្រីអាចពន្យល់ជូនអង្គជំនុំជម្រះនូវអ្វី<ដែលលោកស្រី>បានដឹង<>អំពីសមាគមនោះ ដោយសារលោកស្រីជាសមាជិក ហើយអ្នកណាជាប្រធានសមាគមហ្នឹង? ហើយគោលបំណងរបស់សមាគមហ្នឹងមានគោលបំណងយ៉ាងដូចម្តេចដែរ? សូមលោកស្រីជម្រាបអង្គជំនុំជម្រះ។

**លោកស្រី អ៊ុំ សុផានី៖**

**ឆ៖** ខ្ញុំសុំមិនឆ្លើយ។

**ស៖** ខ្ញុំមិន<>ដឹងថាលោកស្រីបានទទួលប្រឹក្សាយ៉ាងម៉េចពីមេធាវីទេ។ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី <លោកស្រីមានសិទ្ធិមិនឆ្លើយនឹងសំណួរបានតែក្នុងករណីដែលចម្លើយនោះអាចដាក់បន្ទុកលើខ្លួនឯង។ ដូច្នេះសូមលោកស្រីឆ្លើយនឹងសំណួររបស់ខ្ញុំ។>

**ប្រធានអង្គជំនុំ៖**

លោកស្រី ដើមបណ្តឹងរដ្ឋប្បវេណីត្រូវឆ្លើយតបទៅនឹងសំណួរនូវអ្វីដែលលោកស្រីដឹង បើលោកស្រីមិនដឹង គឺលោកស្រីអាចឆ្លើយថាមិនដឹង។

លោកស្រីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិមានការអ្វីទៀតទៅ?

[០៩:៤៩:១៧]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់រំឭកថាដើមបណ្ដឹងរដ្ឋប្បវេណីមិនមែនជាសាក្សីទេ។ គាត់មិនមានកាតព្វកិច្ចឆ្លើយ<សំណួរ>ទេ ហើយពិតប្រាកដណាស់ មិនស្ថិតក្រោមអធិបញ្ញារបស់មេធាវីការពារក្ដី នួន ជាទេ ប៉ុន្ដែគឺស្ថិតក្រោមអធិបញ្ញារបស់លោកប្រធាន។ <>ដើមបណ្ដឹងរដ្ឋប្បវេណីគាត់មានសិទ្ធិ<បដិសេធមិនឆ្លើយសំណួរបាន>។ <> ដូច្នេះអង្គជំនុំជម្រះ គឺជាអ្នកមានសិទ្ធិទាញផលវិបាកចេញពីការនៅស្ងៀមរបស់គាត់។ <ប៉ុន្ដែវាត្រូវតែផ្ដល់សិទ្ធិឲ្យបានល្អ គ្មានអ្វីមួយត្រូវហាមឃាត់ឡើយ>។

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រហែលជាខ្ញុំយល់ច្រឡំទៅលើអង្គច្បាប់ <ប៉ុន្ដែខ្ញុំគិតថា ស្ថានភាពនេះមិនដូចអ្វីដែលបានលើកឡើងនោះទេ>។ <ខ្ញុំគិតថា> យើងមានបុគ្គលដែលត្រូវៗឆ្លើយនៅទីនេះ<> ប្រហែលជា<គាត់>មិនទាន់បានស្បថទេមើលទៅ <ប៉ុន្ដែមិនមានសិទ្ធិ ឬអាទិភាពណាមួយសម្រាប់សាក្សីរូបនេះ ឬដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការឆ្លើយសំណួរឬអត់នោះទេ។> លោកប្រធាន<> ប្រហែលជាសូមឲ្យអង្គជំនុំជម្រះមេត្តាជួយអន្ដរាគមន៍បញ្ហានេះ។

**ប្រធានអង្គជំនុំ៖**

ការចូលរួមអំពីឋានៈដើមបណ្ដឹងរដ្ឋប្បវេណី ចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការមិនមានកាតព្វកិច្ចត្រូវធ្វើសម្បថទេ។ នេះជាឋានៈមួយបែងចែករវាងឋានៈដើមបណ្ដឹងរដ្ឋប្បវេណី ជាមួយនឹងសាក្សី។ សាក្សីត្រូវមានកាតព្វកិច្ចត្រូវធ្វើសម្បថ។ អ៊ីចឹងហើយបានជាប្រធានអង្គជំនុំជម្រះមុននឹងចាប់ផ្ដើមសួរប្រគល់ភារកិច្ចទៅឲ្យមេធាវីភាគីសួរដេញដោលចំពោះសាក្សី អង្គជំនុំជម្រះបញ្ជាក់អំពីការធ្វើសម្បថរបស់សាក្សីនៅចំពោះមុខ ធ្វើសម្បថ ពីព្រោះសាក្សីមុននឹងឆ្លើយតបនូវសំណួរផ្សេងៗរបស់អង្គជំនុំជម្រះ រួមទាំងអ្នកជំនាញផង ប៉ុន្ដែដើមបណ្ដឹងរដ្ឋប្បវេណីអត់ទេ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥២:០០]

លោកស្រី អ៊ុំ សុផានី យើងបានជម្រាបហើយអំមិញ ថាលោកស្រីត្រូវតែឆ្លើយតបទៅនឹងសំណួរដែលសួរ ពីព្រោះយើងប្រើពាក្យថា លោកស្រីស្ដាប់សក្ខីកម្មរបស់លោកស្រីនៅចំពោះមុខអង្គជំនុំជម្រះ។ ប្រសិនបើលោកស្រីមិនឆ្លើយតបទៅនឹងសំណួរដែលសួរទេ គឺថា អង្គជំនុំជម្រះអាចវាយតម្លៃនូវសក្ខីកម្មរបស់លោកស្រីទាំងមូលថាមិនអាចជឿជាក់បានឡើយ។ ដូច្នេះ លោកស្រីគប្បីឆ្លើយនូវអ្វីដែលលោកស្រី

បានដឹង បានឮ បានឃើញ បានកត់សម្គាល់ដើម្បីឆ្លើយតបទៅនឹងខ្លឹមសារនៃសំណួរដែលសួរ។ គ្រាន់តែសូមរំឭកថា គប្បីឆ្លើយតបទៅក្នុងក្របខ័ណ្ឌចាំបាច់ក្នុងការឆ្លើយតបទៅនឹងសំណួរបានហើយ ពេញលេញ ហើយនិងចាំបាច់ប៉ុណ្ណោះ។ កាលណាឆ្លើយវែងអន្លាយហួសពីកម្រិតវិសាលភាពនៃបំណងនៃការសួរនោះ វានឹងអាចបង្កើតជាបញ្ហាផ្សេងៗទៀត។ ហើយក្នុងការឆ្លើយតបនឹងសំណួរយើងបានប្រាប់អម្បាញ់មិញហើយ ក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណីក៏ដោយ ជាសាក្សីក៏ដោយ ជាអ្នកជំនាញក៏ដោយ ប្រសិនបើ ខ្លួន សំណួរឯណាខ្លួនមិនដឹងទេ គឺអាចថា ឆ្លើយថាមិនដឹងទេ។ នេជាក៏ជាចម្លើយដែរ។

[០៩:៥៣:៣៥]

សូមលោកមេធាវី កូប៉េ បន្តការតាំងសំណួរ អាចសួរបញ្ជាក់បន្ថែមទៀតលើសំណួរដែលលោកបានសួរអម្បាញ់មិញនេះ ចុងក្រោយនេះ ហើយនិងនៅបន្តបន្ទាប់ទៀត គ្រាន់តែសូមឲ្យពិគ្រោះពេលវេលាជាមួយនឹងមេធាវីការពារក្ដីលោក ខៀវ សំផន។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំនឹងអនុវត្តទៅតាមការបង្គាប់របស់អង្គជំនុំជម្រះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រី សុផានី ខ្ញុំចង់ឲ្យលោកស្រីជម្រាបជូនអង្គជំនុំជម្រះម្ដងទៀត អំពី<សមាគមជនរងគ្រោះខ្មែរក្រហមនៅកម្ពុជានេះ អំពី>សមាជិកក្រុមប្រឹក្សាភិបាល គោលបំណង តួនាទី ជាដើម ។ល។ របស់សមាគមនេះ បាទ សូមអញ្ជើញ។

**លោកស្រី អ៊ុំ សុផានី៖**

**ឆ៖** បើសិនជាខ្ញុំរៀបរាប់ វាវែងឆ្ងាយ។ ដូច្នេះ ខ្ញុំសូមឆ្លើយខ្លីៗ។ ដំបូងឡើយខ្ញុំមានគំនិតថាពេលដែលខ្ញុំបានរស់រានមានជីវិតនេះ ខ្ញុំតាំងចិត្តថាខ្ញុំចង់បាន ខ្ញុំចង់រកយុត្តិធម៌ឲ្យអ្នកដែលបាត់បង់ជីវិតទៅ មានប្រជាជន ជនរងគ្រោះទូទាំងប្រទេសទាំងឡាយដែលបានស្លាប់បាត់បង់នៅក្នុងសម័យប៉ុលពតនិងមានគ្រួសារខ្ញុំ ក្នុងនោះក៏មានគ្រួសារខ្ញុំមួយចំនួនធំដែរ។ ហើយខ្ញុំឃើញសមាគមនេះ គេថាគេរកយុត្តិធម៌ជូនប្រជាជន។ អ៊ីចឹងខ្ញុំក៏ត្រូវតែ ជាជនរងគ្រោះ ខ្ញុំក៏ត្រូវតែចូលទៅក្នុងសមាគមហ្នឹងនឹងគេដែរ។ ហើយខ្ញុំនៅតែតាំងចិត្តថា ទោះបីជាយ៉ាងម៉េចៗក៏ដោយ ខ្ញុំនៅតែមានបំណងរកយុត្តិធម៌ជូនជនរងគ្រោះដោយៗទី១ ខ្ញុំសរសេរសៀវភៅ ហើយលោកសួរខ្ញុំថាយកសៀវភៅ "ក្រោមដំណក់ទឹកភ្លៀង" នោះមកធ្វើជាសាក្សី។ មិនមែនទេ ខ្ញុំបានជម្រាបតាំងពីដំបូងថា សៀវភៅ"កាលណាយើងជួបគ្នា?" ជាសៀវភៅ

កំណត់ហេតុពិតប្រាកដដែលខ្ញុំសរសេរនៅឆ្នាំ១៩៨០ ដកស្រង់ពីចំណុចខ្លីៗនៃសៀវភៅកំណត់ហេតុរបស់ខ្ញុំដែលខ្ញុំសរសេរនៅឆ្នាំ១៩៧៥។ ដូច្នេះហើយសៀវភៅនោះ ខ្ញុំយកជាគោលការណ៍ហ្នឹងធ្វើជា ហាក់ដូចជាប្រលោមលោក ពីព្រោះខ្ញុំសរសេរថា "ខ្ញុំសរសេរប្រលោមលោក" ប៉ុន្តែក្នុងប្រលោមលោកនោះមាន ៨០ភាគរយ ជារឿងពិតដែលខ្ញុំចុះមូលដ្ឋាននាឆ្នាំ១៩៨៤ ហើយនិងខ្ញុំរំឭកពីអនុស្សាវរីយ៍ដែលខ្ញុំនៅសម័យប៉ុល ពត ហើយខ្ញុំបង្កើតតួបន្តិចបន្តួច ប៉ុន្តែតួបន្តិចបន្តួចហ្នឹងគឺថាជាតួស្វាមីខ្ញុំ ហើយខ្ញុំនិយាយពីចារឹកប្តីខ្ញុំ ខ្ញុំនិយាយ ហើយនិងតួស្រីហ្នឹងគឺតួខ្ញុំតែម្តង ប៉ុន្តែគ្រាន់តែខ្ញុំប្តូរបន្តិចបន្តួច។ ហើយដែលលោកសួរខ្ញុំថា តើការរៀបការដោយបង្ខំមែនឬទេ? គឺពេលនោះខ្ញុំត្រូវបានម្តាយក្មេកបង្ខំឲ្យខ្ញុំឆ្លើយថារៀបការហើយ។ អ៊ីចឹងខ្ញុំក៏ -- អាហ្នឹងដូចជាបង្ខំដែរពីព្រោះពេលហ្នឹងយើងមិនមែនចង់រៀបការអី ព្រោះអីគ្មានបង គ្មានប្អូន គ្មានម៉ែគ្មានអីចូលរួម យើងចង់រៀបការយ៉ាងម៉េច បើប្តីយើងកំពុងឈឺដំបៅងាផង។ បើលោកមើលសៀវភៅខ្ញុំលោកគង់នឹងដឹងហើយ។ អ៊ីចឹងនរណាទៅចង់រៀបការពេលកំពុងឈឺហ្នឹង ឈឺធ្ងន់ទៀត ដំបៅហ្នឹងដើរមិនរួចផងហ្នឹង។ អ៊ីចឹងគឺថាដូចថាជាការបង្ខំអ៊ីចឹង។ អ៊ីចឹងខ្ញុំសូមឆ្លើយ អរគុណ។

[០៩:៥៧:១៣]

**ស៖** បាទ ខ្ញុំសូមសួរសង្ខេបម្តងទៀតអំពីសមាគមមួយនេះ។ លោកស្រីកំពុងតែនិយាយអ្វីមួយដែលខុសពីថ្ងៃសុក្រហើយ ពីព្រោះកាលពីថ្ងៃសុក្រ ខ្ញុំបានអាននូវសារមួយចំនួននៅក្នុងកំណត់ត្រារបស់លោកស្រី លោ<ក>ស្រីថាលោកស្រីរៀបការដោយសប្បាយរីករាយនៅក្នុងខែមិថុនា ឆ្នាំ៧៥ <ជាមួយបុរសដែលលោកស្រីស្រឡាញ់>។ ឥឡូវនេះលោកស្រីនិយាយថា មានគេបង្ខំឲ្យលោកស្រីរៀបការទៅវិញ អ៊ីចឹងតើខ្ញុំយល់ខុស ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំនិយាយថាខ្ញុំសប្បាយរីករាយ ប៉ុន្តែសប្បាយរីករាយនឹងបានប្តីដែលខ្ញុំពេញចិត្តហ្នឹងទេ ប៉ុន្តែ អាដែងបង្ខំនោះ គឺថាម្តាយក្មេកខ្ញុំបង្គាប់ៗខ្ញុំថា "បើគេសួរថារៀបការហើយឬនៅ ត្រូវឆ្លើយថារៀបការហើយ"។ រីករាយ ប៉ុន្តែខ្ញុំមិនសប្បាយចិត្តនឹង -- ចុះយើងគិតមើលធម្មតាធ្វើកូនក្រមុំ កូនកំលោះ ពេលហ្នឹងត្រូវតែដូច សម័យនេះគឺគេការដូចស្តេចអ៊ីចឹង ពេលហ្នឹងគឺគេយកចិត្តទុកដាក់ណាស់ កូនក្រមុំ កូនកំលោះ។ ចុះពេលនោះមាននរណាគេយកចិត្តទុកដាក់! កូនក្រមុំទៅជាន់នំហ្នឹង មិនមែនមានសប្បាយ មានអីរឿងអីសប្បាយ ប៉ុន្តែគ្រាន់ថាបានគូស្វាមីហ្នឹងនៅជួបជុំគ្នាតែប៉ុណ្ណឹងទេ។

**ស៖** លោកស្រី សុផានី ដោយសារតែពេលវេលា ខ្ញុំសូមសួរសង្ខេបខ្លី។ មានបញ្ហាខុសគ្នាយ៉ាងខ្លាំងរវាងម្តាយក្មេករបស់លោកស្រីចង់ឲ្យលោករៀបការហើយ<>និងការបង្ខំដោយរបបខ្មែរក្រហម

លោកស្រីកំពុងតែនិយាយចំណុចមួយណាហ្នឹង? អ្នកណាបង្ខំ?

[០៩:៥៩:០៨]

**ឆ៖** ម្ដាយក្មេកបង្ខំ និងៗ បើយើងមិនៗ -- គាត់មិនបង្ខំត្រូវអង្គការបំបែកយើង ពីព្រោះអីយើងស្ថានភាព ខ្ញុំបាននិយាយហើយថាស្ថានភាពយើងទាំងពីរខុសគ្នា ខុសគ្នាយ៉ាងដូចម្ដេច? ខ្ញុំជាអ្នកភ្នំពេញ ចំណែកស្វាមីខ្ញុំជាអ្នកមករៀននៅភ្នំពេញមែន ប៉ុន្តែគាត់មានឪពុកម្ដាយជាអ្នកមូលដ្ឋាន។ អីចឹងអាហ្នឹងៗវាមានខុសគ្នាអីចឹង។ ចាស សូមអរគុណ។

**ស៖** បាទ ដោយសារតែពេលវេលាខ្ញុំសូមកាត់សំណួរខ្ញុំខ្លីៗ។ តើខ្ញុំយល់ត្រឹមត្រូវទេ បើសិនខ្ញុំនិយាយថាសមាគមដែលលោកស្រីជាសមាជិកគណៈកម្មាធិការនាយក<នោះ> ធ្វើឱ្យពិភពលោកច្រលំថា លោកស្រី<ត្រូវ>បាន<ពួកខ្មែរក្រហម>បង្ខំឱ្យរៀបការនៅក្នុងរបបខ្មែរក្រហម។ តើត្រឹមត្រូវទេ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប។

សូមអញ្ជើញលោកសហព្រះរាជអាជ្ញាអន្តរជាតិ!

[១០:០០:២១]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ <ទង្វើប្រឆាំងនឹងនីតិវិធីសវនាការគឺនៅទីនេះហើយ ដោយ>មេធាវីការពារក្ដីឥឡូវនេះកំពុងតែតាំងសំណួរដោយយោង ទៅលើឯកសារដែលគាត់មិនបានចែករំលែកបញ្ជូនមកឱ្យភាគីនៅឡើយទេ។ គាត់<>បាន<ទទួល>ឱកាស<> ដើម្បីដាក់ឯកសារហ្នឹងជូនជាដំណឹង<ដើម្បីធ្វើការកត់សម្គាល់ និងដើម្បី>ដាក់<>ស្នើសុំ។ ដូច្នេះបើសិនណាជាអង្គជំនុំជម្រះអនុញ្ញាត<គាត់នឹងមានឱកាសសួរសំណួរទាំងនោះ។> ប៉ុន្តែគាត់មិនគួរណាចេះតែសួរបង្វែង<>ទៅលើដើមបណ្ដឹងរដ្ឋប្បវេណីទៅលើឯកសារមួយដែលមិនទាន់បានជូនមកដល់ភាគីនោះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមបញ្ចប់ការតាំងសំណួរ<របស់ខ្ញុំប៉ុណ្ណេះ។ ខ្ញុំគិតថា នៅបន្ទប់ព័ត៌មាន មានអ្នកសារព័ត៌មានពេញទីនោះ> គឺមានកាសែតទាំងភ្នំពេញប៉ុស្តិ៍ <ទាំងខេមបូឌាដេលី>។ ដូច្នេះគេនឹងយល់ថាកិច្ចដំណើរការ<នីតិ>វិធីយ៉ាងណានោះ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិការជូនទៅក្រុមមេធាវីការពារក្តី លោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញ!

[១០:០១:៣៤]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកស្រី អ៊ុំ សុផានី, ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន ខ្ញុំមានសំណួរ<មួយចំនួន>ដើម្បីសួរបំភ្លឺលោកស្រី អាស្រ័យទៅតាមអ្វីដែលលោកស្រីបានឆ្លើយ។ ចំណុចទី១ <ជុំវិញការ>ពិភាក្សាអំពីការជំទាស់<របស់ក្រុម>មេធាវី នួន ជា មេធាវីរបស់លោកស្រីបានឆ្លើយថា លោកស្រីបានសរសេរសៀវភៅជាច្រើន <ហើយក្រោយមក លោកស្រីបានបញ្ជាក់បន្ថែមដោយខ្លួនឯង ថាបានសរសេរសៀវភៅ>ទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ។ តើខ្ញុំយល់នេះត្រឹមត្រូវដែរឬទេលោកស្រី?

**លោកស្រី អ៊ុំ សុផានី៖**

**ឆ៖** សូមគោរពលោកប្រធាន។ ចាសលោកស្រីមេធាវីខាងលោកខៀវ សំផន ត្រឹមត្រូវ។ ខ្ញុំសរសេរសៀវភៅជាច្រើន។ នៅក្នុងសៀវភៅនីមួយៗគឺតែង ខ្ញុំតែងតែរំឭកអំពីសម័យខ្មែរក្រហម។

**ស៖** ជាបឋម ខ្ញុំសូមចាប់អារម្មណ៍ទៅលើសៀវភៅមួយដែលលោកស្រីបានដាក់ជាឧបសម្ព័ន្ធ <នៅក្នុងទម្រង់បែបបទសុំតាំងខ្លួន>ជាដើមបណ្តឹងរដ្ឋប្បវេណី<របស់លោកស្រី> គឺជាឯកសារ D22/3248 ។ <ក្នុងសំណុំរឿង ០០២/០២> នៅក្នុងក្របខ័ណ្ឌជំនុំជម្រះសេចក្តីនេះ លោកស្រីបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយលោកស្រីបានដាក់ឯកសារនេះទៅក្នុងឧបសម្ព័ន្ធ។ អ៊ីចឹងសំណួរទី១របស់ខ្ញុំនោះគឺថា តើលោកស្រីជាអ្នកសម្រេចដាក់សៀវភៅនេះជាឧបសម្ព័ន្ធ<នៅក្នុង>ទម្រង់បែបបទរបស់លោកស្រី <ដើម្បីសុំតាំងខ្លួន>ជាដើមបណ្តឹងរដ្ឋប្បវេណីមែនទេ?

[១០:០៣:៣៧]

**ឆ៖** ចាស មែនប្រាកដហើយ។

**ស៖** ខ្ញុំសូមការបំភ្លឺមួយ ព្រោះថាអម្បាញ់មិញនេះពេលដែលលោកស្រីឆ្លើយទៅនឹងលោកមេធាវី កូប៉េ លោកស្រីបានឆ្លើយថានៅក្នុងសៀវភៅរបស់លោកស្រីមាន ៨០ភាគរយនៃបទពិសោធន៍ផ្ទាល់ខ្លួនលោកស្រី <ខ្ញុំធ្វើការសន្និដ្ឋានថា>២០ភាគរយ<ដែលនៅសល់ គឺជា>ប្រឌិត<>។ តើជាការ

ត្រឹមត្រូវដែរឬទេក្នុងការនិយាយថានៅក្នុងសៀវភៅដែលដាក់ជាឧបសម្ព័ន្ធនៃចម្លើយ ឬក៏ទម្រង់បែបបទដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកស្រីហ្នឹង គឺថាមាន ៨០ភាគរយជាការពិត ហើយ២០ភាគរយជាការប្រឌិតទេ។ តើអ៊ីងមែនទេ ឬក៏ខ្ញុំមានការយល់ច្រឡំទេលោកស្រី ៨០ភាគរយជាការពិត ២០ភាគរយ ជាការប្រឌិត? <ឬក៏ខ្ញុំយល់ខុស?>

**ឆ៖** សៀវភៅដែលខ្ញុំដាក់នៅក្នុងតុលាការគឺការពិត។ សៀវភៅដែលខ្ញុំ -- ក្រោម "តំណក់ទឹកភ្លៀងនោះគឺ៨០ភាគរយ ជាការពិត ១០ -- ២០ភាគរយ ជាការប្រឌិត ពីព្រោះកាលពេលហ្នឹងខ្ញុំសរសេរជាប្រលោម -- គេប្រឡងប្រលោមលោក។ ដូច្នេះបើសិនជាខ្ញុំយកសៀវភៅកំណត់ហេតុហ្នឹង គេថាមិនមែនជាប្រលោមលោកទេ។ ចាស សូមអរគុណ។

**ស៖** អ៊ីចឹង ដើម្បីឲ្យៗច្បាស់លាស់ថាខ្ញុំពិតជាយល់នោះ គឺថាអ្វីដែលលោកស្រីបានដាក់ជាឧបសម្ព័ន្ធនៃ<ពាក្យសុំតាំងខ្លួន>ជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកស្រីនោះ គឺថាវា១០០ភាគរយជាការពិតហើយ។អ៊ីចឹងមែនទេ?

**ឆ៖** ចាស ប្រាកដហើយ គឺថាសៀវភៅដែលខ្ញុំដាក់ជូនតុលាការគឺជាការពិត។

**ស៖** ដោយសារលោកស្រីបានបញ្ជាក់នៅមុខតុលាការ ថាលោកស្រីបានរៀបការដោយសេចក្ដីស្នេហាទេ។ តើលោកស្រីយល់ស្របដែរឬទេ ក្នុងការនិយាយថានៅក្នុងសៀវភៅដែលមិនបានដាក់ចូលក្នុងសំណុំរឿងដែលត្រូវបានលើកឡើងនៅក្នុងពេលលោកស្រីផ្ដល់សក្ខីកម្មនៅទីនេះ តើជាការត្រឹមត្រូវទេ ក្នុងការនិយាយថានៅពេលដែលលោកនិយាយ<អំពី>ការបង្ខំឲ្យរៀបការនៅក្នុងសៀវភៅផ្សេងៗហ្នឹង អាន់នុងគ្រាន់តែជាការប្រឌិតទេនៅក្នុងការសរសេររឿងប្រលោមរបស់លោក<ស្រី ដោយផ្អែកលើបទពិសោធន៍របស់លោកស្រី ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?> តើ<ជាការត្រឹមត្រូវទេដែលនិយាយ>ថា<>សៀវភៅផ្សេងទៀតទាំងអស់ហ្នឹងគឺជារឿងប្រឌិត<>?

[១០:០៦:២៩]

**ឆ៖** ចាស ត្រឹមត្រូវ។ ពីព្រោះដែលខ្ញុំសរសេរថា គេរៀបការដោយបង្ខំហ្នឹង។ ពីព្រោះដែលខ្ញុំចេញពីសម័យប៉ុលពតមក ខ្ញុំឃើញ ដូចថាខ្ញុំស្ដាប់ព័ត៌មានទៅ មានៗរបៀបហ្នឹង បានខ្ញុំលើកពិតនៃសង្គមនៅសម័យនោះ យកមកដាក់នៅក្នុងសៀវភៅ។ ចាស ត្រឹមត្រូវមែន។

**ស៖** នេះជាសំណួរចុងក្រោយរបស់ខ្ញុំលើចំណុចនេះ។ អ៊ីចឹង យើងយល់ស្របគ្នាហើយថាលោកស្រីមិនមែនជាជនរងគ្រោះនៃការរៀបការដោយបង្ខំទេនៅក្នុងរបបខ្មែរក្រហម។ លោកស្រីយល់

ស្របទេ<?> លោកស្រីមិនមែនជាជនរងគ្រោះរបស់របបខ្មែរក្រហមទេ គឺលោកស្រីជាជនរងគ្រោះរបស់ម្ដាយក្មេកទេ ដែលបង្ខំឱ្យលោកស្រីរៀបការនោះ។ តើអ៊ីចឹងជាការត្រឹមត្រូវទេ?

**ឆ៖** ត្រឹមត្រូវ។ ពីព្រោះម្ដាយខ្ញុំក៏មានការកៀបសង្កត់ពីពួកខ្មែរក្រហមដែរ។ បើសិនណាជាម្ដាយក្មេកខ្ញុំមិននិយាយអ៊ីចឹង គឺខ្ញុំនិងប្ដីខ្ញុំត្រូវព្រាត់ប្រាសគ្នា ត្រូវបែកគ្នា។ អ៊ីចឹង ក៏គាត់មានគំនាបពីអង្គការហ្នឹងដែរ មិនមែនថាគាត់ធ្វើដោយចិត្ត បើគាត់មិនបង្ខំគឺខ្ញុំ យើងត្រូវៗស្លាប់ ត្រូវបែកគ្នា ឬក៏ស្លាប់អាចស្លាប់បាន។ ចាស សូមអរគុណ។

**ស៖** ក៏ប៉ុន្តែ បើតាមចម្លើយរបស់លោកស្រីនៅក្នុងសវនាការនេះ គឺថាបុរសដែលលោកស្រីរៀបការជាមួយនោះគឺជាគូដណ្ដឹងតាំងពីភ្នំពេញមកទេ។ <តើខ្ញុំបានប្រមូលព័ត៌មានទាំងអស់បានត្រឹមត្រូវទេ ផ្អែកលើសក្ខីកម្មរបស់លោកស្រីនោះ>?

[១០:០៨:១៤]

**ឆ៖** ចាស ជាគូដណ្ដឹងប្រាកដមែន។

**ស៖** ខ្ញុំសូមអរគុណដែលបានឆ្លើយ។ ឥឡូវនេះ ខ្ញុំសូមចូលទៅ<>សំណួរមួយចំនួនទៀត <ដោយខ្លីៗទេ>។ លោកស្រីបានឆ្លើយនៅទីនេះ ពីរយៈពេលដែលលោកស្រីដេកពេទ្យពេលសម្រាលកូន<>នោះ <> អ៊ីចឹងសូមឱ្យលោកស្រីបញ្ជាក់ចំណុចមួយ <លោកស្រីបាននិយាយថា គេអាចយកសាច់ ឬក៏>លក់សាច់ឱ្យលោកស្រី។ <>អ៊ីចឹងលោកស្រីជួយបញ្ជាក់មើល<>?

**ឆ៖** សូម ខ្ញុំសូមជម្រាបថា មិនមែនលក់ទេសម័យនោះ ពីព្រោះៗគ្មានលុយ គេបំបិតលុយអស់ហើយ ប៉ុន្តែដោយសារថាគាត់ហូបអីក៏មិនឆ្ងាញ់ៗ ឃើញខ្ញុំបរិភោគទទួលទានស្ដៅ ត្រួយស្ដៅជាមួយនឹងកូនកង្កែបតូចៗហ្នឹង គាត់គិតៗថាប្រហែលឆ្ងាញ់។ អ៊ីចឹង គាត់ក៏យកសាច់ឈ្លូសហ្នឹង ប្រហែលជាប៉ុន ធំជាង ធំទ្រើសជាងមេដៃ មកដូរៗយកស្ដៅហ្នឹង យកត្រួយស្ដៅពីខ្ញុំហ្នឹងទៅ យកទៅហូប មិនមែនលក់ដូរទេ ចាស។ ដូរគ្នា។ ហើយស្ត្រីនោះ ជាប្រពន្ធរបស់ -- ខ្ញុំឮគេថាទេ ប៉ុន្តែខ្ញុំអត់ដឹង ព្រោះអីខ្ញុំមកចូលពេទ្យនេះ យើងមែន មិនបានទៅតាមដានថាអ្នកនេះអ្នកនោះអីទេ គ្រាន់ថា អឺ! គេជាប្រពន្ធគណៈស្រុក គណៈៗអ៊ីចឹងណ៎ា អង្គការថ្នាក់លើ។ គ្រាន់ថាដឹងតែប៉ុណ្ណឹង។

[១០:១០:២៨]

**ស៖** តើលោកស្រីចាំឈ្មោះម្នាក់ហ្នឹងទេ?

**ឆ៖** ចាស នៅសម័យនោះគឺ ខ្ញុំមិនបានៗយកចិត្តទុកដាក់ស្គាល់នេះ អ្នកធំអ្នកអីណា មិនចាប់

អារម្មណ៍ទេ។ បើថាជាមេកង ដែលខ្ញុំនៅរាល់ថ្ងៃ អាហ្នឹងខ្ញុំគ្រាន់ស្គាល់ឈ្មោះ។ ក្រៅពីហ្នឹងយើង -- ព្រោះអីគេ ដូចថាម្នាក់ៗនៅរក្សាភាពស្ងៀមស្ងាត់ គ្មានទៅនិយាយពីនេះពីនោះទេ គេឲ្យ -- ដូចថា ធ្វើគ ធ្វើថ្លង់អ៊ីចឹង។ សូមអរគុណ។

**ស៖** បាទ ឥឡូវខ្ញុំសូមត្រឡប់មកតបទៅនឹងចម្លើយអម្បាញ់មិញនេះ។ តើជាការត្រឹមត្រូវទេ ខ្ញុំនិយាយថាលោកស្រី កាលនោះ លោកស្រីមិនដឹងថាអ្នកណាជាប្រធានសហករណ៍ឲ្យច្បាស់លាស់ អ្នកណាជាគណៈស្រុក<>ឬមេឃុំអីនោះទេ ព្រោះលោកស្រីមិនសូវ<ស្គាល់>។ និយាយអ៊ីចឹងត្រូវទេ?

**ឆ៖** ចាស ត្រូវហើយ។

[១០:១១:៤៨]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយបាទ។ បាទ សូមអរគុណ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោកប្រធានសូមអនុញ្ញាតសួរសំណួរមួយ។ អម្បាញ់មិញខ្ញុំបាទបានឮអ្នកស្រីមានប្រសាសន៍ថាអ្នកស្រីធ្វើគធ្វើថ្លង់នៅក្នុងសម័យខ្មែរក្រហម។ អ្នកស្រីអាចជម្រាបអង្គជំនុំជម្រះបានទេថាតើការអនុវត្ត បែបនេះវាមានខ្លឹមសារយ៉ាងណាដែរសម្រាប់អ្នកស្រីនៅក្នុងសម័យនោះ?

**លោកស្រី អ៊ុំ សុផានី៖**

**ឆ៖** នៅក្នុងសម័យនោះគឺគេមិនឲ្យយើង -- សូម្បីតែប្ដីប្រពន្ធហ្នឹងក៏មិនចង់និយាយរកគ្នាផង គ្រាន់តែសម្លឹងៗមុខសម្លឹងអីទេ មិនសូវចង់និយាយអី។ បើនិយាយ ដូចខ្ញុំបានរៀបរាប់មកថាសម្ដីដែលយើងនិយាយគឺថា -- មាត់ដែលយើងមានគឺសម្រាប់តែហូបបាយ ហើយនិយាយកិច្ចការអ្វីដែលចាំបាច់។ ដូចថាគេឆ្លើយថា ដូចដែលយើងថា យើងសុំៗអនុញ្ញាតទៅពេទ្យ ពីព្រោះយើងមិនៗស្រួលខ្លួនអ៊ីចឹង អាហ្នឹង ឬក៏យើងសុំសម្រាកអីហ្នឹង យើងសុំច្បាប់អនុញ្ញាតគេ ពីព្រោះអីយើងមិនចេះតែនិយាយផ្ដេសផ្ដាសទេ។

**ស៖** បាទសូមអរគុណ។ លោកស្រីមានបានទទួលការណែនាំ ឬក៏ការបញ្ជាណាមួយពីថ្នាក់លើរបស់អ្នកស្រីទេ? ឧទាហរណ៍ដូចជាមេក្រុម មេកង ឬក៏ប្រធានសហករណ៍ជាដើម ទាក់ទងទៅនឹងបញ្ហានៃការធ្វើគធ្វើថ្លង់នេះ។

[១០:១៣:៥០]

**ឆ៖** ខ្ញុំមិនបានទទួលការណែនាំពីមេក្រុម មេកងទេ ប៉ុន្តែខ្ញុំទទួលបានអំពីម្ដាយក្មេក ឪពុកក្មេក និងមាមីងដែលនៅក្នុងភូមិហ្នឹងគាត់ថា "កុំនិយាយច្រើន ស្រុកៗគេនេះ"។ ហើយកុំស្និទ្ធស្នាលនឹងស្វាមីអីដូច -- ពីព្រោះខ្ញុំ -- ឧទាហរណ៍ទៅតាមផ្លូវ គ្រាន់តែខ្ញុំ ប្ដីខ្ញុំគាត់គេងកើយលើភ្លៅ ហើយខ្ញុំរកចៃឲ្យគាត់ ស្រាប់តែយប់ឡើងគេប្រជុំ ប៉ុន្តែខ្ញុំអត់ឮ ប៉ុន្តែឮបងស្រីខ្ញុំៗ ប្អូនស្រីខ្ញុំប្រាប់ថា គេប្រជុំនិយាយថាអ្នកភ្នំពេញយក គេហៅថាយកវប្បធម៌អាសអាភាសមក។ អ៊ីចឹង ខ្ញុំដឹងតាមៗផ្លូវខ្លះ គេប្រជុំ។ អ៊ីចឹងៗបានសេចក្ដីថាកន្លែងភូមិមួយដែលៗខ្ញុំឃាត់ខ្លួនហ្នឹង គឺត្រូវអង្គការហ្នឹងគេប្រជុំនិយាយអ៊ីចឹង។ អ៊ីចឹងបានសេចក្ដីថាអង្គការបាននិយាយដែរ។ ប៉ុននៅក្នុងភូមិឃុំខ្ញុំ គឺឪពុកម្ដាយក្មេកខ្ញុំ និងសាច់ញាតិហ្នឹង គាត់ប្រាប់ថាកុំឲ្យនិយាយអី កុំឲ្យស្និទ្ធស្នាលជាមួយប្ដី កុំឲ្យស្និទ្ធស្នាលជាមួយបងប្អូន ជាមួយឪពុកម្ដាយ។ អ៊ីចឹងខ្ញុំគិតថាប្រហែលជាគាត់បានដឹង បានក្ដាប់ផែនការអំពីអង្គការ។ ពីព្រោះគាត់ធម្មតាៗ គាត់មិនមែនដឹងដោយខ្លួនគាត់ទេ ទាល់តែមានការកៀបសង្កត់ពីអង្គការថាអ៊ីចឹង បានគាត់យកប្រាប់ខ្ញុំដែលជាប្រជាជនថ្មី។ ចាស សូមអស់យោបល់។

[១០:១៥:១៥]

**ស៖** បាទ សូមអរគុណ។ អ្នកស្រីមានធ្លាប់បានការចូលរួមមតិពីអ្នកធ្វើការជាមួយផ្សេងទៀតក្រៅពីម្ដាយ បងប្អូនជាពិសេសខាងម្ដាយក្មេករបស់អ្នកស្រី និយាយប្រាប់អ្នកស្រីអំពីការឲ្យនៅស្ងៀមកុំនិយាយច្រើន ធ្វើគ ធ្វើថ្លង់ ដែលអាចថាមិនមែនជាការងារ ជាភារកិច្ចរបស់អ្នកស្រី ដែលថាការងារណាមិនមែនជាការងាររបស់អ្នកស្រី អ្នកស្រីអាចមិនធ្វើដឹង មិនធ្វើឮក្នុងសម័យនោះ។ អ្នកស្រីបានទទួលព័ត៌មាននេះពីអ្នកផ្សេងទៀតក្រៅពីឪពុកម្ដាយឬទេ?

**ឆ៖** មាន ចាស ពីព្រោះអ្នកថ្មីៗដូចគ្នា លបប្រាប់ស្ងាត់ៗហ្នឹងដែរ ថាកុំឲ្យមាត់ព្រោះ -- កុំឲ្យនិយាយច្រើន កុំឲ្យមាត់។

**ស៖** បាទ សូមអរគុណ។ ចុះអ្នកដទៃទៀតនោះ ដែលអ្នកស្រីបានប្រាស្រ័យជាមួយនោះ គេអនុវត្តយ៉ាងម៉េចដែរ ចំពោះការធ្វើគ ធ្វើថ្លង់នេះ?

**ឆ៖** ចាស គេដូចៗខ្ញុំដែរ គ្រាន់តែថាបើគេលួច និយាយប្រាប់ស្ងាត់ទៅ រួចទៅគេនៅស្ងៀមៗទៅ។

[១០:១៦:៥៤]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកស្រី។ លោកប្រធានខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរមួយចំនួន<>មិនពាក់ព័ន្ធ<នឹងប្រធានបទដែលខ្ញុំបានសួរពីមុននោះទេ។> <ដោយសារ>ខ្ញុំព្រួយបារម្ភពីពេលវេលារបស់មេធាវី ខៀវ សំផន ទើបបានខ្ញុំផ្អាកមុន។ អ៊ីចឹងខ្ញុំសួរទៅលោកស្រី សុផានី អំពីកំណត់ហេតុប្រចាំថ្ងៃរបស់លោកស្រី។ សំណួររបស់ខ្ញុំគឺសួរដូចខាងក្រោមនេះ៖

**ស៖** ថាតើនៅក្នុងកំណត់ហេតុប្រចាំថ្ងៃកាលចុះនៅថ្ងៃទី២៦ មិថុនា ២៧, ២៨, ២៩ មិថុនា ERN 00 -- <អង់គ្លេស> 01036460, ខ្មែរ <01032950> <ខ្ញុំសូមដកស្រង់៖> “នៅថ្ងៃព្រហស្បតិ៍ ថ្ងៃទី២៦ ខ្ញុំសម្រាកមួយថ្ងៃ។ ថ្ងៃសុក្រ ២៧ ថ្ងៃខ្ញុំមានជំងឺហឺត ខ្ញុំមិនទៅធ្វើការទេ។ ថ្ងៃសៅរ៍២៨ ខ្ញុំមានហឺត <ខ្ញុំមិនបានទៅធ្វើការទេ។ អេស.អិន បានប្រសើរហើយ។> ហើយថ្ងៃទី២៩ ថ្ងៃអាទិត្យ ខ្ញុំមិនបានទៅធ្វើការទេ”។ នៅថ្ងៃសុក្រ នៅទំព័របន្ទាប់ ERN 01036461 <អង់គ្លេស>, ខ្មែរ <01032951> “ថ្ងៃ<សុក្រទី>១៨ ថ្ងៃ១០កើត ខ្ញុំបានសម្រាក<កន្លះ>ថ្ងៃ <ព្រោះ>ខ្ញុំមិនស្រួលខ្លួន”។ នៅ<ទំព័រ> បន្ទាប់មកគឺ ERN 01036462 <ខ្មែរ> <01032952>, “<ថ្ងៃទី១២ ខែធ្នូ>ហើយខ្ញុំបានសម្រាកមួយថ្ងៃ បានហូបនំបញ្ចុក”។ លោកស្រី សុផានី តើអាចប្រាប់អង្គជំនុំជម្រះបន្ថែមបន្តិចបានទេ <អំពីការ>សម្រាក<របស់លោកស្រី ឬក៏ការ>ត្រូវការ<សម្រាកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។> <>បើថា<លោកស្រី>សុខភាពមិនល្អ ឬក៏មានជំងឺហឺតវាធ្វើទុក្ខ គឺថាអាចសម្រាកបានទេ ឬក៏សុំគេសម្រាក អ៊ីចឹងបានដូចដែលលោកស្រីកត់ទេ។ តើត្រឹមត្រូវទេ ខ្ញុំយល់បែបនេះ?

**លោកស្រី អ៊ុំ សុផានី៖**

**ឆ៖** ចាស ពីព្រោះអង្គការ ផែនការគេល្អណាស់ គោលការណ៍គេគឺថា “គេមិនប្រើអ្នកឈឺទេ” គេថាអ៊ីចឹង។ ដូច្នេះ ខ្ញុំប៉ានដោយសារតែគោលការណ៍ល្អអ៊ីចឹង ខ្ញុំក៏ខ្ញុំក៏សុំ។ ប៉ុន្តែ បើយើងទៅអត់រួចហើយ បើលោកដឹងថាជំងឺហឺតហ្នឹងរបៀបម៉េច? ជំងឺហឺតហ្នឹងគឺសូម្បីតែគេនិយាយគ្នាហ្នឹងក៏ហត់ដែរ។ អ៊ីចឹងបានជាខ្ញុំសុំសម្រាក ហើយទៅវាអត់រួចផង ទៅវាអត់រួច ព្រោះអីធម្មតាតែមនុស្សយើងតែឈឺខ្លាំងហើយ ទៅលែងរួចហើយ គឺថាត្រូវតែសុំច្បាប់ឈប់ហើយ បង្ខំយ៉ាងម៉េចក៏អត់ទៅកើតដែរ។ សូមអស់យោបល់ គឺខ្ញុំសរសេរអ៊ីចឹងមែន។

[១០:២០:១៩]

**ស៖** តើត្រឹមត្រូវដែរទេ បើខ្ញុំសរុបថានៅពេលដែលលោកស្រីមិនស្រួលខ្លួនហើយសុំគេឈប់ ហើយជាទូទៅគេបានអនុញ្ញាតឱ្យឈប់សម្រាក តើអ៊ីចឹងដែរឬទេនៅពេលថាឈឺ<> គេមិនបង្ខំឱ្យធ្វើការទាំងឈឺទេ។ តើអ៊ីចឹងត្រូវឬទេ?

**ឆ៖** ត្រូវ ប៉ុន្តែទាល់តែយើងសុំច្បាប់អនុញ្ញាត គេមិនមែន -- មិនមែនធ្វើដោយចិត្តយើងទេ។ បើគ្មានការអនុញ្ញាតគឺយើងអត់បានឈប់ទេ ទាល់តែអង្គការគេអនុញ្ញាតដែរ។

**ស៖** សូមអរគុណលោកស្រី សុផានី ខ្ញុំមានសំណួរចុងក្រោយមួយទៀតជាសំណួរបន្ត។ <> លោកស្រីបាននិយាយថាលោកស្រីធ្វើជាគ ជាថ្លង់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយខ្ញុំព្យាយាមរកខ្លឹមសារដែលថាបញ្ជាក់ពីអាកប្បកិរិយា អំពើដែលលោកស្រីធ្វើនៅក្នុងកំណត់ហេតុលោកស្រី ប៉ុន្តែរកមិនឃើញទាល់តែសោះ ថាតើលោក<ស្រីអាចប្រាប់យើងបានទេ> តើលោកស្រីចាំទេ ហេតុអ្វីបានជា<លោកស្រី>មិនបានចុះនៅក្នុងសៀវភៅកំណត់ហេតុថា ធ្វើជាគ ជាថ្លង់ហ្នឹង? <>

[១០:២១:៤៨]

**ឆ៖** ខ្ញុំចាំថាមាន។ ខ្ញុំមានកត់នៅក្នុងកំណត់ហេតុ ពីព្រោះខ្ញុំយល់ថាមាត់សម្រាប់តែទុកហូបបាយ ហើយនិងនិយាយភាសា -- កិច្ចការចាំបាច់។ អ៊ីចឹងហាក់ដូចជាធម្មតាខ្ញុំនិយាយច្រើនណាស់ ខ្ញុំនិយាយច្រើនមែនទែន។ ហើយខ្ញុំចូលចិត្តច្រៀង ដល់ពេលអ៊ីចឹងគេបង្អាក់ គេមិនឱ្យយើងនិយាយតាមចិត្តយើង។ អានេះខ្ញុំមិនដឹងថាមនុស្សម្នាក់ៗហ្នឹងគេ អ្នកខ្លះចូលចិត្តយ៉ាងម៉េចទេ ប៉ុន្តែខ្ញុំនិយាយច្រើន។ អ៊ីចឹងការដែលខ្ញុំនិយាយតិចហ្នឹង ខ្ញុំថាខ្ញុំហ្នឹងអត់មានសិទ្ធិសេរីភាពក្នុងការនិយាយបាត់ទៅហើយ បើខ្ញុំនិយាយតិចអ៊ីចឹង។

**ស៖** ហើយខ្ញុំសួរបន្ថែមខ្លីមួយ លោកស្រី សុផានី តើលោកស្រីអាចណែនាំថាតើនៅក្នុងកំណត់ហេតុប្រចាំថ្ងៃនៅកន្លែងណាដែលនិយាយថាលោកស្រី ធ្វើគ ធ្វើថ្លង់ ឬក៏សំណួរនេះវាពិបាកពេក?

**ឆ៖** ខ្ញុំអត់បានយកកំណត់ហេតុមកជាប់នឹងដៃខ្ញុំទេ ប៉ុន្តែខ្ញុំដឹងថាខ្ញុំមានសរសេរថា "មានភ្នែកសម្រាប់តែមើល មានភ្នែកសម្រាប់មើល ហើយមានត្រចៀកសម្រាប់ស្តាប់តែប៉ុណ្ណឹង ហើយនិងមានមាត់សម្រាប់តែហូបបាយៗ ហើយនិងនិយាយអ្វីដែលភាសាចាំបាច់ ដែលថាកិច្ចការចាំបាច់"។ ខ្ញុំបានសរសេរអាហ្នឹង។

**ស៖** ហើយខ្ញុំចង់ឱ្យលោកស្រី សុផានី ប្រាកដថាតើបាត់មួយទំព័រ ឬក៏កន្លែងណាមួយឬក៏

កំណត់ហេតុប្រចាំថ្ងៃដែលលោកស្រីដាក់ជូនតុលាការហ្នឹងពេញទាំងស្រុងទាំងអស់ ឬយ៉ាងដូចម្ដេច បានជាខ្ញុំរកឃ្លាដែលលោកស្រីនិយាយហ្នឹងមិនឃើញ?

[១០:២៣:៥៣]

**លោក យឹគាំង លូ៖**

សូមអនុញ្ញាតលោកប្រធាន ខ្ញុំឃើញថាគឺជាខ្លឹមសារនិយាយចេញពីពាក្យសៀវភៅរបស់គាត់ដែលថា “កាលណាយើងជួបគ្នា?” <> ខ្ញុំនឹងអាចជួយ ERN បានឃ្លាដែលគាត់និយាយពាក្យនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ហើយខ្ញុំគិតថាមិនចាំបាច់ទេគឺថាមានចែង នៅក្នុងសៀវភៅហ្នឹងគឺមានមែន។ ប៉ុន្តែខ្ញុំសួរទៅលោកស្រីគឺថា សួរពាក្យហ្នឹងនៅក្នុងកំណត់ហេតុប្រចាំថ្ងៃរបស់គាត់។

[១០:២៥:០០]

**លោក យឹគាំង លូ៖**

លោកប្រធានគឺ ដើមបណ្ដឹងរដ្ឋប្បវេណីគាត់អាចភ័ន្តច្រឡំ<ទាក់ទងនឹងបញ្ហានេះ ពីព្រោះ>គាត់ឆ្លើយនឹងសំណួររបស់ខ្ញុំ<ពីមុនមកហើយ> ហើយគាត់បានអានខ្លឹមសារមួយនៅក្នុងសៀវភៅនោះគឺ ERN ខ្មែរ 00562857, អង់គ្លេស <01037338> ហើយបារាំង <01037346> បាទ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ ហើយនូវការកត់សម្គាល់នេះ ហើយជាបន្តទៅនេះលោកស្រី អ៊ុំ សុផានី លោកស្រីក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណីអាចថ្លែងរៀបរាប់ដល់អង្គសវនាការស្ដាប់អំពីរឿងហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលនាំលោកស្រីតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីប្ដឹងទាមទារសំណងជំងឺចិត្ត និងជាសមូហភាពពីជនជាប់ចោទ។ ស្ថានភាពព្យសនកម្មដែលអាចមានចំពោះលោកស្រីដូចជាការខូចខាតខាងរាងកាយ សម្ភារៈ ឬស្មារតី ជាផលវិបាកផ្ទាល់ដោយបទឧក្រិដ្ឋ ព្យសនកម្មផ្ទាល់ខ្លួន និងបានកើតមានពិតប្រាកដរហូតដល់បច្ចុប្បន្ននេះ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។

[១០:២៦:៣១]

**លោកស្រី អ៊ុំ សុផានី៖**

ចាស ខ្ញុំសូមរៀបរាប់បញ្ហាខ្លះៗជូនដល់អង្គសវនាការនាថ្ងៃនេះ។ សូមគោរពលោកប្រធានតុលាការ លោក លោកស្រីសហព្រះរាជអាជ្ញា លោកមេធាវី ព្រមទាំងអ្នកចូលរួមទាំងអស់ដែលមានវត្តមាននៅក្នុងអង្គសវនាការនេះ។ ខ្ញុំសូមជម្រាបលោកប្រធានថា ខ្ញុំមិនដឹងថាមានអ្នកណាទៀតទេ ក្រៅពីខ្ញុំដែលបាន -- ដែលជាសាក្សីរស់ម្នាក់ ពិតជាបានសរសេរកំណត់ហេតុក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះមែន។ គំនិតនេះបានមកពីការណែនាំរបស់បងស្រីទី២ ឈ្មោះ អ៊ុំ ណារ៉ាត ថាបើខ្ញុំចង់ក្លាយជាអ្នកនិពន្ធទាល់តែសរសេរកំណត់ហេតុ។ ឥឡូវនេះ ខ្ញុំឃើញច្បាស់នឹងភ្នែកថា កំណត់ហេតុនេះបានក្លាយជាភស្តុតាងជាក់ស្តែង ពីព្រឹត្តិការណ៍នៃរបបខ្មែរក្រហម ដែលបានសម្លាប់រង្គាលប្រជាជនអស់រាប់លាននាក់ប្រាកដមែន។ ឧក្រិដ្ឋជនទាំងពីររូបនេះមានបេះដូងជាអ្វី បានជាបំផ្លិចបំផ្លាញធនធានមនុស្ស សម្បត្តិវប្បធម៌ទាំងរូបិយនិងអរូបិយ ដែលជាគ្រឹះនៃប្រទេសជាតិមួយ ព្រមទាំងរចនាសម្ព័ន្ធទាំងឡាយដែលមានស្រាប់ឱ្យរលាយសូន្យសុងស្ទើរអស់គ្មានសល់ រួចហើយគេចាប់ផ្តើមកសាងប្រទេសពីចំណុចសូន្យទៅវិញ។ សកម្មភាពទាំងនេះហើយដែលបញ្ជាក់ថាមិនមែនជាជនស្នេហាជាតិ និងមិនសមជាបញ្ញវន្តទេ។ មុនឆ្នាំ១៩៧៥ ទាំងខ្ញុំ ទាំងអ្នកដទៃទៀតកំពុងរស់នៅជួបជុំក្រុមគ្រួសារយ៉ាងមានសេចក្តីសុខ ព្រមទាំងបានទទួលការរៀនសូត្រចេះដឹងពីសង្គមជាតិ ស្រាប់តែនៅពេលរបបកម្ពុជាប្រជាធិបតេយ្យចូលមកកាន់កាប់ភ្លាម របបនេះបានបង្កើតវិនាសកម្មតែមួយពព្រិចភ្នែក ដែលខ្ញុំពុំអាចថ្លែងរៀបរាប់ឱ្យបានអស់គ្រប់ជ្រុងជ្រោយទាំងគេ ទាំងខ្ញុំ ត្រូវបានអង្គការបង្ខំឱ្យចេញពីផ្ទះសម្បែង នៅតាមផ្លូវខ្ញុំបានឃើញផ្ទាល់ភ្នែកនូវសាកសពដែលដេកស្លាប់ក្នុងថ្លុកឈាមពេញផ្លូវ បញ្ចេញក្លិនអសោចពាសពេញបរិយាកាសហាក់ដូចជាយើងស្ថិតនៅក្នុងឋាននរកអវិចី។ ខ្ញុំពុំបានដឹងពីផែនការដែលអង្គការប្រមូលអ្នករដ្ឋការ ទាហាន និងមន្ត្រីជំនាញផ្សេងៗទៀត ចូលទៅទីក្រុងវិញ ដើម្បីបំពេញបម្រើការងារជូនរដ្ឋ ប៉ុន្តែក្រោយមកទើបខ្ញុំដឹងថានេះគ្រាន់តែជាលេសរបស់អង្គការដើម្បីបញ្ឆោតប្រជាពលជនឱ្យមកប្រមូលផ្តុំ រួចយកទៅសម្លាប់ទាំងហ្វូងៗ បញ្ចូលទៅក្នុងស្រះនិងប្រឡាយ ពីព្រោះប្រជាជនមានចំនួនច្រើនពេក រកពេលនឹងជីករណ្តៅពុំទាន់ក៏ធ្វើតាមវិធីនេះទៅ។ ពេលដែលខ្ញុំទៅដល់ឃុំត្រពាំងធំខាងត្បូងបានតែប៉ុន្មានថ្ងៃ បងថ្លៃខ្ញុំ ឈ្មោះ ហុក ហេង ជាអ្នកបើកបរយន្តហោះ និងស្រីប្អូនជាច្រើនទៀតដែលខ្ញុំធ្លាប់ស្គាល់ ដែលមានស្វាមីជានាយទាហាន និងគ្រូបង្រៀនសុទ្ធតែត្រូវបានអង្គការបដិវត្តន៍យកទៅរៀនសូត្រ។ អង្គការបានប្រមូលស្រីទាំងនោះ ដាក់ម្តុំ រួចដាក់ឈ្មោះថា "កងស្រីមេម៉ាយ"។ ពាក្យនេះសបញ្ជាក់ថា អង្គការបានប្រហារជីវិតស្វាមីពួកគេហើយ។ ក្រោយមក ទើបខ្ញុំបានដឹងថា បងថ្លៃទី៦ ក៏ឃ្លាតទៅរហូត អត់វិលត្រឡប់មកវិញ។

ឯបងថ្លៃទី៥ ឈ្មោះ ស៊ូ ណែម ហៅ ស៊ូ សូត្រ ដែលជាវេជ្ជបណ្ឌិតមកពីខេត្តបាត់ដំបងក៏ត្រូវបានអង្គការសម្លាប់នៅក្នុងគុកទួលស្លែង(ស-២១)។ សូមអានសៀវភៅគុកទួលស្លែង បោះពុម្ពដោយក្រសួងឃោសនាការ និងវប្បធម៌ ត្រង់ទំព័រ៣៧។

[១០:៣០:៥២]

ចំណែកស្វាមីខ្ញុំក៏អង្គការរកលេសចោទប្រកាន់ដើម្បីធ្វើទារុណកម្មជាទម្ងន់បំណាងឲ្យបាត់បង់ជីវិតដែរ។ ឯពិធីរៀបការនាសម័យនោះ ពាក្យ "បដិវត្តន៍ ហៅថា ប្ដេជ្ញា"។ ថ្វីដ្បិតតែខ្ញុំបានរៀបការមែន ប្ដេជ្ញាមែន ប៉ុន្តែជាពិធីដ៏សោះកក្រោះ ខ្ញុំរកភាពរីករាយមិនឃើញទេ ក្នុងស្ថានភាពដែលប្ដីខ្ញុំកំពុងតែកើតជំងឺដំបៅងាជាទម្ងន់ និងគ្មានមាតាបិតា ព្រមទាំងបងប្អូនញាតិមិត្តខាងខ្ញុំមកចូលរួម។ នៅពេលដែលខ្ញុំសម្រាលកូនដំបូង ពួកពេទ្យបដិវត្តគ្មានបទពិសោធន៍គ្រប់គ្រាន់ ពុំលទ្ធភាពជួយអ្វី ក្រៅតែពីឲ្យខ្ញុំប្រឹងទាំងមិនយល់ ហើយពោលពាក្យតែមួយឃ្លាថា "ការប្រឹងនេះខុសហើយ"។ ពួកគេពុំបានពន្យល់ថា ការប្រឹងកើតកូននោះ វាមានលក្ខណៈយ៉ាងណាៗទេ គឺទុកឲ្យអ្នកជំងឺនៅក្រៀមកំប៉ឹត តាំងពីព្រលឹមថ្ងៃទី១ រហូតដល់ជិតភ្លឺថ្ងៃទី២។ ទោះបីជាពេទ្យនោះ បានមកមើល ក៏គ្មានអ្វីក្រៅពីពោលពាក្យថា "កូននោះស្លាប់ហើយ"។ ខ្ញុំថា "បើស្លាប់ហើយ សូមប្រញាប់យកចេញទៅ" ប៉ុន្តែពេទ្យអសមត្ថភាព គ្មានបច្ចេកទេសពុំបានធ្វើតាមសំណូមពរខ្ញុំទេ។ ទុកឲ្យខ្ញុំផ្សងកើតកូននោះទៅតាមយថាកម្មទៅវិញ។ ឯស្ត្រីកើតកូនរួចហើយ គេយកទៅដាក់ក្នុងបន្ទប់រួម មានផ្សែងភ្លើងដែលគេដុតកំដៅខ្លួនឲ្យហុយទ្រុបទ្រុលពេញបន្ទប់ស្ទើរតែថប់ដង្ហើមទាំងកូនង៉ា រួមទាំងម្ដាយក្មេង ទាំងម្ដាយសរសៃខ្ចីផង។ ពេលមានស្ត្រីកើតកូនមកស្លាប់ គេយកដាក់សាកសពស្ត្រីនោះ ដាក់លើគ្រែក្នុងបន្ទប់រួម ហើយគ្របក្រណាត់ស។ ពួកគេពុំយល់ពីអារម្មណ៍នៃសមនុស្សសរសៃខ្ចីឡើយថា គ្នាមានការភ័យខ្លាចយ៉ាងណាទៅ! ចំណែកឯថ្នាំវិញ មានតែថ្នាំមូលៗដូចជាលាមកទន្សាយ និងសេរ៉ូមមិនដឹងជាធ្វើអំពីទឹកអ្វីទេ ដាក់នៅក្នុងដបទឹកក្រូច បេ.ហ្សេ.អ៊ី។

[១០:៣៣:០៧]

ចំពោះការហូបចុក ដោយសេចក្ដីស្រេកឃ្លានខ្លាំងពេក ស្វាមីខ្ញុំ និងអ្នកធ្វើការរួមក្រុមរបស់គាត់លួចបរិភោគផ្លែសក់សេះ ទោះជាដឹងថាពុលក៏ដោយ ក៏នៅតែលួចហូបទៀត។ នេះគឺហើយមកពីសេចក្ដីស្រេកឃ្លានខ្លាំងពេក ដល់ពុលមានម្នាក់ក្នុងចំណោមអ្នកទាំងនោះ ស្លាប់ភ្លាមមួយរំពេច។ ចំណែកឯខ្ញុំវិញ ក៏លួចហូបផ្សិតដែរ មិនដឹងថាជាផ្សិតពុល ឬមិនពុលទេ ព្រោះតែសេចក្ដីឃ្លានពេក ក៏ហូបទៅ។ ស្រាប់តែខ្ញុំក្អួតផង រាកផង ស្ទើរស្លាប់ ស្ទើររស់ ខ្ញុំក៏ត្រូវបានអង្គការឲ្យផឹកទឹកអ្វី ខ្ញុំមិនដឹង។ ក្រោយមក

ទើបខ្ញុំដឹងថា ជាលាមកគោ លាយជាមួយស្កររត្នោត។ របបមហាលោតផ្លោះ មហាអស្ចារ្យរបស់កម្ពុជាប្រជាធិបតេយ្យ នៅទីបំផុតមានតែការរលត់រលាយអស់រលីង។ នេះហើយដែលគេហៅថា ការធ្វើបដិវត្តន៍គ្មានគោលជំហរច្បាស់លាស់។ គ្មានគំនូសដៅពិតប្រាកដ គឺធ្វើទៅតាមមហិច្ឆតាលោភលន់ និងការសងសឹក ដោយសារតែការច្រណែនឈ្នានីសតែតាមគំនិតពាលខ្លៅ អត់ពិចារណារកហេតុផលអ្វីឡើយ។ ទាំងជិវិតមនុស្សក៏បាត់បង់ ទាំងទ្រព្យសម្បត្តិក៏ហិនហោច ទាំងមនុស្សនៅរស់មានរានមានជីវិត ក៏ទ្រុឌទ្រោមអស់សមត្ថភាព ទាំងរូបរាងកាយ និងទាំងផ្លូវចិត្ត គ្មានឃើញចម្រើនដល់សង្គមជាតិលើចំណុចណាមួយទាល់តែសោះ។

នៅទីបញ្ចប់ នាងខ្ញុំជឿជាក់ថា តុលាការនេះនឹងខិតខំប្រឹងប្រែងស្វះស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ និងវែកមុខរកជនល្មើស និងអ្នកពាក់ព័ន្ធទាំងឡាយ ឲ្យឃើញជាក់ជាមិនខាន។

សូមអរគុណ។ សូមគោរពលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកស្រីមានអីទៀតទេ?

**លោកស្រី អ៊ុំ សុផានី៖**

ចាស លោកប្រធាន ខ្ញុំអត់មានអ្វីទៀតហើយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីតំណាងនាំមុខដើមបណ្តឹងរដ្ឋប្បវេណី!

[១០:៣៥:៤៧]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំ<មិន>ដឹងថាឥឡូវនេះ <ជាពេលវេលាសមស្របសម្រាប់>ធ្វើការកត់សម្គាល់របស់ខ្ញុំ<ឬយ៉ាងណាទេ> ក៏ប៉ុន្តែយើងបានផ្ញើអ៊ីម៉ែលមួយទៅអង្គជំនុំជម្រះ ហើយចម្លងជូនដល់ភាគីផងដែរ ពីបញ្ជីសំណួរចំនួនបីដែលចង់ចោទសួរទៅជនជាប់ចោទ ហើយនិងសំណើដែលយើងចង់ធ្វើ។ សំណួរទាំងនេះចង់ -- យើងចង់អានសំណួរទាំងអស់នេះនៅក្នុងសវនាការ។ នេះនៅក្នុងសំណើរបស់យើង អ៊ីចឹងសូមឲ្យអនុវត្តយ៉ាងដូច្នេះ។ គឺថាសំណួរដែលយើងចង់សួរ <ត្រូវ>អាននៅទីនេះ ហើយបញ្ចូលក្នុងកំណត់ហេតុតុលាការ។ បើទោះបីជាខាងជនជាប់ចោទឆ្លើយ ឬមិនឆ្លើយ ក៏មិនបញ្ហាដែរ។ តែទោះបីយ៉ាងណា សូមឲ្យដាក់<ប្រយោគទាំងអស់នេះ>ចូល<ក្នុង>កំណត់ត្រាតុលាការ <ដោយសារ វាមានសារៈសំខាន់

សម្រាប់>ដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខនេះក៏ដោយ  អ្នកទាំងខាងក្រោយទៀតក៏ដោយ<ទាំងនៅក្នុង និងនៅក្រៅសាលតុលាការ និយាយទូទៅគឺ>ដើម្បីឲ្យសាធារណជនដឹងផងដែរ ឲ្យឃើញថាដើមបណ្ដឹងរដ្ឋប្បវេណីមានបំណងចង់សំណួរ ហើយទោះបីខាងជនជាប់ចោទគាត់មិនចង់ឆ្លើយក៏មិនជាបញ្ហាអ្វីដែរ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីមេធាវីការពារក្ដីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ សំណួរដែលៗថាទាក់ទងថាការសុំអានសំណួរនៅទីនេះ យើងពុំមានការជំទាស់អីទេ។ ក៏ប៉ុន្តែផ្ទុយទៅវិញ <>យើងយ៉ាង<>ត្រូវតែព្យាយាមជៀសវាង គឺថាកុំឲ្យចោទសំណួរ<>ទៅជនជាប់ចោទ<ដែលមានលក្ខណៈជាប្រព័ន្ធ គឺ>ថាចង់ឆ្លើយនឹងសំណួរឬក៏អត់នោះព្រោះគាត់ បានប្រាប់តាំងពីដើមទីហើយ ថាគាត់រក្សាសិទ្ធិមិនឆ្លើយតប។ អ៊ីចឹងបើសិនជាសំណួរមិន--បើអ៊ីចឹងសូម កុំចោទសំណួរអ៊ីចឹងថា លោកចង់ឆ្លើយនឹងសំណួរហ្នឹងអត់? បើនៅតែសួរសំណួរអ៊ីចឹងដដែលៗទៅកាន់  ជនជាប់ចោទទេរាល់ដងទេថាគឺជាការដាក់សម្ពាធទៅលើពួកគាត់ហើយលោកប្រធាន។ អ៊ីចឹងសំណូមពរ តែប៉ុណ្ណឹងទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការកត់សម្គាល់របស់លោកស្រីមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន។

សូមអញ្ជើញលោកស្រី អ៊ុំ សុផានី!

**លោកស្រី អ៊ុំ សុផានី៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន!

ខ្ញុំមានចម្រៀងមួយបទ ខ្ញុំ -- ការខូតខាតនៃទ្រព្យសម្បត្តិហ្នឹង ប្រជាជនកម្ពុជាទូទៅមិនមែនតែចំពោះខ្លួនខ្ញុំមួយ គឺទូទៅៗសុទ្ធតែខាត។ បើសិនជាខ្ញុំសំណូមពរពីការសងសំណងផ្ទាល់ខ្លួន ក៏ខ្ញុំ ក៏អង្គសវនាការមិនអាចអនុញ្ញាតបានដែរ។ ដូច្នេះ ខ្ញុំសំណូមពរតែមួយគត់ គឺថាខ្ញុំសំណូមពរឲ្យអង្គសវនាការសូមមេត្តាសម្រេចថា ខ្ញុំចង់ឲ្យចម្រៀងខ្ញុំហ្នឹងមានជាបទភ្លេង មានជាអ្នកចម្រៀងត្រឹមត្រូវតាមផ្លូវការ។ ហើយទុកចាក់ស្ដាប់ទុករាល់ដែលពេលថាមានបញ្ហារឿងខ្មែរក្រហមខ្មែរអីហ្នឹង។

[១០:៣៩:០១]

**ប្រធានអង្គជំនុំ៖**

ដំណាក់កាលហ្នឹងដូចជាផុតហើយ។ អំមិញហ្នឹងបាន អង្គជំនុំជម្រះបានផ្ដល់ឱកាសជូនលោកស្រី ឲ្យរៀបរាប់អំពីទុក្ខសោកវេទនាអំពីមូលហេតុទាំងឡាយដែលនាំឲ្យលោកស្រីតាំងខ្លួនជាដើមបណ្ដឹងរដ្ឋ-ប្បវេណី។ ឱកាសនោះចប់ហើយ។ ឱកាសចុងក្រោយនេះ គឺសំណួរដែលលោកស្រីមានបំណងសួរទៅជនជាប់ចោទ។ អ៊ីចឹងមិនច្របូកច្របល់រវាងសេចក្ដីថ្លែងចុងបញ្ចប់នៃបង្ហាញព្យសនកម្មជាមួយនឹងសំណួរទេ។ អ្វីដែលយើងចង់អនុញ្ញាតនាពេលនេះ គឺអនុញ្ញាតថាបើលោកស្រីមានបំណងចង់សួរទៅជនជាប់ចោទដែរឬទេ ក្នុងខណៈពេលដែលទាំងអស់គ្នាសុទ្ធតែដឹងថាជនជាប់ចោទបានរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ ប្រសិនបើលោកស្រីនៅតែរក្សាសិទ្ធិក្នុងការសួរ យើងអនុញ្ញាតឲ្យតាំងសំណួរនោះ។ យើងនឹងសម្រេចលើបញ្ហានេះថាដូចម្ដេច អាស្រ័យទៅលើស្ថានភាពជាក់ស្ដែងដែលអង្គជំនុំជម្រះបានដំណើរការកន្លងមករហូតដល់ពេលនេះ លើរឿងក្ដី០០២/០២នេះ។

**លោក យីគាំង លួ៖**

ខ្ញុំសូមអនុញ្ញាតលោកប្រធាន។ <ខ្ញុំគិតថា>ដើមបណ្ដឹងរដ្ឋប្បវេណី គាត់ភ័ន្តច្រឡំដែលថា ដែលតុលាការសួរគាត់នោះថាឲ្យសួរសំណួរ ឬក៏ឲ្យស្នើសំណើ។ ដូច្នេះគាត់ច្រឡំជាមួយនឹងសំណើសងសំណង។ ដូច្នេះខ្ញុំសូម<>តុលាការអនុញ្ញាតឲ្យគាត់សួរសំណួរទៅជនជាប់ចោទតាមរយៈលោកប្រធាន គឺមិនមែនឲ្យគាត់លើកជាសំណើសុំសំណងទេ។ ដូច្នេះ សូមលោកប្រធានអង្គជំនុំជម្រះមេត្តាអនុញ្ញាតបាទ។

[១០:៤១:១០]

**ប្រធានអង្គជំនុំ៖**

យើងបញ្ជាក់ច្បាស់លាស់ហើយអំមិញណ៎ះ! ពេលវេលាសម្រាប់ធ្វើសំណើផ្សេងៗចប់ហើយ នៅតែការតាំងសំណួរទេ។ តើប្រើសិទ្ធិក្នុងការតាំងសំណួរចំពោះជនជាប់ចោទដែរឬទេ? នេះគឺជាសំណួរចុងក្រោយ។ ប្រសិនបើលោកស្រីមិនឆ្លើយតបទេ អង្គជំនុំជម្រះនឹងបញ្ចប់ការស្ដាប់សក្ខីកម្មរបស់លោកស្រីត្រឹមនេះឥឡូវហើយ។

**លោកស្រី អ៊ុំ សុផានី៖**

ចាស ខ្ញុំមានសំណួរទៅជនឧក្រិដ្ឋទាំងពីររូប គឺថា ឧក្រិដ្ឋជនទាំងពីរនេះជាជនជាតិកម្ពុជា ចុះហើយដូចម្ដេចក៏ធ្វើបដិវត្តន៍បំផ្លិចបំផ្លាញប្រពៃណីទំនៀមទម្លាប់ល្អរបស់ប្រទេសនេះទៅវិញ? សំណួរ

ទី១ ។ សំណួរទី២ ហេតុអ្វីក៏ពួកខក្រិដ្ឋជនធ្វើបដិវត្តន៍បំផ្លាញប្រព័ន្ធអប់រំ? តាមគំនិតអ្នក តើយើងអាចអភិវឌ្ឍន៍ប្រទេសដោយគ្មានការអប់រំបានដែរឬទេ? ពីព្រោះពេលនោះ គ្មានសាលា គ្មានមហាវិទ្យាល័យអីទេ គ្មានសាលាទេ។ ទី៣ ចំពោះប្រជាជនកម្ពុជា សមាជិកគ្រួសារមានសារៈសំខាន់ណាស់សម្រាប់ពួកយើង។ ចុះហេតុដូចម្ដេចក៏បដិវត្តន៍របស់គាត់ទៅជាបំបែកបំបាក់យើងពីក្រុមគ្រួសារ ហើយទៅឲ្យយើងហូបចុះ និងរស់នៅជាសហគមន៍ទៅវិញ? នេះគឺជាសំណួររបស់ខ្ញុំ។ សូមអស់យោបល់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី អ៊ុំ សុផានី អង្គជំនុំជម្រះកត់សម្គាល់ថា នៅពេលចាប់ផ្ដើមធ្វើសវនាការពិនិត្យភស្តុតាងកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ក្រោយពីបានសួរបញ្ជាក់ជនជាប់ចោទទាំងពីរនាក់អំពីជំហររក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ជនជាប់ចោទទាំងពីរនាក់ នៅតែរក្សាជំហររបស់ខ្លួនបន្តអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល លើកលែងតែ និងរហូតដល់ពេលណាដែលអង្គជំនុំជម្រះសាលាដំបូងទទួលបានព័ត៌មានជាក់ច្បាស់ផ្សេងពីជនជាប់ចោទ ឬពីសហមេធាវីការពារក្ដីឲ្យជនជាប់ចោទ។

ហេតុដូច្នេះ ជនជាប់ចោទ និងសហមេធាវីការពារក្ដីឲ្យជនជាប់ចោទ មានកាតព្វកិច្ចទទួលខុសត្រូវក្នុងការជូនដំណឹងដល់អង្គជំនុំជម្រះឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព បើសិនជាជនជាប់ចោទលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប។ រហូតមកដល់ពេលនេះ អង្គជំនុំជម្រះនៅមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្ដូរជំហររបស់ជនជាប់ចោទ អំពីការសម្រេចលះបង់សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតប ទៅជាការយល់ព្រមឆ្លើយតបទៅនឹងសំណួរឡើយ។

[១០:៤៤:០៣]

លោកស្រី អ៊ុំ សុផានី អង្គជំនុំជម្រះសូមអរគុណចំពោះលោកស្រី ដែលបានជួយមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ រហូតដល់ពេលនេះ ការស្ដាប់សក្ខីកម្មរបស់លោកស្រីក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីបានចប់ហើយ វត្តមានរបស់លោកស្រីនៅបន្ទប់សវនាការនេះលែងមានភាពចាំបាច់ទៀតហើយ លោកស្រីអាចវិលត្រឡប់ទៅលំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ។ សូមលោកស្រីវិលត្រឡប់ -- ធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនដើម-បណ្ដឹងរដ្ឋប្បវេណីនេះ ត្រឡប់ទៅលំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់ត្រឡប់ទៅវិញចុះ។

ហើយឥឡូវនេះ ដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤៤ នាទី ដល់ម៉ោង ១១:០២ នាទី)*

[១១:០២:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនៅក្នុងសវនាការបន្តនេះ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-238។

សូមអញ្ជើញ លោកមេធាវី គង់ សំអុន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមអនុញ្ញាតធ្វើការកត់សម្គាល់ខ្លីមួយទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី។ ដោយខ្ញុំបាទព្យាយាមមិនកាត់អ្នកស្រី នៅពេលដែលអ្នកស្រីធ្វើសេចក្តីថ្លែង និងតាំងសំណួរមកជនជាប់ចោទតាមរយៈលោកប្រធាន។ ដោយខ្ញុំបាទបានស្តាប់ឮ បីបួនសាន្ទូវពាក្យដែលអ្នកស្រីបានប្រើ ដោយហៅជនជាប់ចោទថាជា "ឧក្រិដ្ឋជន"។ ហើយចំណុចនេះដែលធ្វើឲ្យមានការភ័ន្តច្រឡំពីព្រោះថា នៅក្នុងដំណាក់កាលនេះ ទោះបីជាលោក ខៀវ សំផន ត្រូវបានតុលាការសាលាដំបូងរកឃើញថាមានពិរុទ្ធភាពក៏ដោយ ក៏ប៉ុន្តែសាលក្រមនោះ យើងនៅកំពុងធ្វើការប្តឹងសាទុក្ខនៅឡើយ។ ដូច្នេះ ការហៅលោក ខៀវ សំផន ថាជាឧក្រិដ្ឋជន វាអាចធ្វើឲ្យមានការយល់ច្រឡំ ហើយដែលមើលឃើញថា ជាការមានទោសជាមុនរួចទៅហើយ។ ដូច្នេះ ខ្ញុំសូមលោកប្រធានមេត្តាដកពាក្យនេះចេញ ឬក៏ណែនាំដើមបណ្តឹងរដ្ឋប្បវេណីក្រោយៗទៀត នៅពេលដែលថ្លែងទៅកាន់ជនជាប់ចោទមិនគួរហៅជនជាប់ចោទថា ជាឧក្រិដ្ឋជនបែបនេះទេ។ សូមអរគុណបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ នូវការកត់សម្គាល់ដ៏ល្អរបស់មេធាវីការពារក្តីលោក ខៀវ សំផន។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-238 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១១:០៦:៥៥]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្រីឈ្មោះអី?

**លោកស្រី ជូ គឹមឡូន ៖**

**ឆ៖** ឈ្មោះ ជូ គឹមឡូន ចាស។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី ជូ គឹមឡូន។ យើងសូមណែនាំបន្ថែមលើមន្ត្រីរដ្ឋបាលបានណែនាំលោកស្រីអំមិញថា នៅក្នុងកិច្ចដំណើរការសវនាការនេះយើងប្រើប្រព័ន្ធបែងចែកសំឡេងរបស់លោកស្រីហ្នឹងទៅគ្រប់ភាគីពាក់ព័ន្ធ ហើយនិងអង្គភាពគាំពារក្នុងការបកប្រែភាសា និងកិច្ចការបម្រើផ្សេងៗទៀតនៅក្នុងសាលសវនាការដ៏ធំនេះ។ ហើយដូច្នេះទេ ហើយម្យ៉ាងទៀត គឺចាំបាច់ក្នុងការបកប្រែភាសា ដូច្នេះសូមលោកស្រីពេលដែលមុននឹងឆ្លើយ សូមមើលក្បាលមីក្រូហ្វូន ឬក៏ខាងក្រោមនេះ ដែលពេលមានភ្លើងឲ្យសញ្ញាក្រហម សូមលោកស្រីឆ្លើយ ដើម្បីឲ្យមានសំឡេងរបស់លោកស្រីចូលទៅក្នុងប្រព័ន្ធចែកចាយសំឡេងនៅក្នុងទីនេះ ហើយជាពិសេសទៅដល់អ្នកបកប្រែភាសា។ សង្ឃឹមថាលោកស្រីនឹងអនុវត្តបានល្អប្រសើរនៅទីនេះ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ហើយលោកស្រីកើតនៅថ្ងៃ ខែ ឆ្នាំណា? លោកស្រីចាំទេ?

**ឆ៖** ចាស ឯកសារខ្ញុំដាក់តាំងពីមុននោះ យូរហើយមិនដឹងឆ្នាំណា តាំងពីស្វែងរកការពិត។ រួចដាក់ម្តងទៀត ២០១០។

**ស៖** លោកស្រីកើតនៅឆ្នាំណា ចាំទេ?

**ឆ៖** --

**ស៖** ឆ្លើយៗ អំមិញឆ្លើយហើយខ្ញុំអត់ឮទេ ខ្ញុំក៏អត់ឮដែរណា។ លោកស្រីកើតនៅឆ្នាំណា?

**ផ៖** ចាស កើតនៅឆ្នាំ១៩៥១។

**ស៖** បាទល្អណាស់លោកស្រី ជូ គឹមឡេង។ ហើយលោកស្រីមានទីកន្លែងកំណើតនៅទីកន្លែងណា?

**ផ៖** ទីកន្លែងកំណើតៗពីសង្គមរាស្ត្រនិយមនៅឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមួយពាន់ប្រាំបួន -- មុន១៩៧៥ នៅទីក្រុងភ្នំពេញខាងលិចផ្សារដេប៉ូ។

**ស៖** ទីកន្លែងកំណើតតែមួយកន្លែងទេ។ កន្លែងកើត កន្លែងៗលោកស្រីកើតហ្នឹងនៅកន្លែងណា? ណ៎ះ! អត់មានកន្លែងពីរកន្លែងទេ កើតពីរកន្លែងទាល់តែកើតយ៉ាងម៉េចទៅបានពីរកន្លែងកើតណ៎ះ! អ៊ីចឹងកើតនៅត្រាំកក់ខេត្តតាកែវ អ៊ីចឹងមែនទេ?

[១១:០៩:៥០]

**ផ៖** កើតនៅ កាលខ្ញុំប្រាប់ដំបូង នៅឃុំលាយបូរ ភូមិធ្នង់រលើង ស្រុកត្រាំកក់ ខេត្តតាកែវ។

**ស៖** បាទ អរគុណ។ ហើយចុះលំនៅដ្ឋានបច្ចុប្បន្នរបស់លោកស្រីនៅទីកន្លែងណា?

**ផ៖** បច្ចុប្បន្ននៅកន្លែងហ្នឹងដដែលចាស។ នៅភូមិធ្នង់រលើង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។

**ស៖** ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ៧៩ តើលោកស្រីរស់នៅទីកន្លែងណា? ហើយប្រកបមុខរបរអ្វី?

**ផ៖** នៅ -- កាលយើងរំដោះបានៗ រំដោះបានឆ្នាំ៧៩ហ្នឹង--

**ស៖** មុនៗហ្នឹង ចន្លោះ៧៥ – ១៩៧៥ – ១៧ មេសា ៧៥ រហូតដល់ថ្ងៃ០៦ មករា ៧៩។ ពាក្យសាមញ្ញគេហៅថា របប -- ជំនាន់របបប៉ុល ពតណ៎ះ! លោកស្រីរស់នៅទីកន្លែងណា?

**ផ៖** ចាស ខ្ញុំសង្គម ប៉ុល ពត -- ខ្មែរក្រហម ខ្ញុំរស់នៅឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវដដែល។

**ស៖** ហើយលោកស្រីធ្វើអី? គេឲ្យធ្វើអី?

**ផ៖** ការងារខ្ញុំអត់មានប្រកាន់មុខសញ្ញា គេប្រើធ្វើចល័តគ្រប់មុខទាំងអស់។ ទៅដំបូងហ្នឹងគេប្រើឲ្យធ្វើ -- ដាំស្រូវ អស់ពីដាំស្រូវ ស្ទូងចាស។

**ស៖** អរគុណ។ ហើយឪពុកបង្កើតរបស់លោកស្រីគាត់ឈ្មោះអី?

**ផ៖** ចាស ឪពុកខ្ញុំបង្កើតឈ្មោះ ជូ ទឹម ម្ដាយ ប៉ាន់ លឹម។

**ស៖** ចុះប្តីរបស់លោកស្រីគាត់ឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ប្តីខ្ញុំឈ្មោះ -- ឈ្មោះគាត់ធ្វើការ លោក សួស ឌឹម ហើយដល់ឈ្មោះហៅជាធម្មតាសាមញ្ញ កុត នួន។ ចាស ហើយគាត់ធ្វើការជាពេទ្យទាហាន ប៉ុន្តែគាត់ពីសង្គមរាស្ត្រនិយមប៉ូលិស ហើយដល់មកសង្គមលន់ នល់ ធ្វើពេទ្យទាហានវិញចាស។

**ស៖** លោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ចាស កូនខ្ញុំ -- កូនបងខ្ញុំគាត់ស្លាប់ទៅ ខ្ញុំចិញ្ចឹមកូនគាត់បួននាក់ ហើយតែខ្ញុំមានកូនតែមួយទេ ពោះធំពេលបែកពីភ្នំពេញទៅហ្នឹង ពោះធំបីខែ។

[១១:១២:៥០]

**ប្រធានអង្គជំនុំ៖**

លោកស្រី ជូ គឹមឡូន ក្នុងនាមលោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណី ជាចុងក្រោយនៃការផ្តល់សក្ខីកម្មរបស់លោកស្រីៗ អាចមានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។ ហើយដោយអនុវត្តតាមវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះផ្តល់វេទិកាជូនសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន មុនភាគីដទៃទៀតនៃរឿងក្តី។

សូមបញ្ជាក់ថា សហមេធាវីនាំមុខរួមទាំងសហព្រះរាជអាជ្ញាមានរយៈពេលកន្លះថ្ងៃក្នុងការសួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញលោកមេធាវីនាំតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១១:១៣:៥៧]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៏៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៏៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ លោកស្រីបានឆ្លើយថា លោកស្រីរស់នៅលាយបូរ នៅចន្លោះថ្ងៃទី១៧ មេសា ៧៥ ទៅដល់ឆ្នាំ៧៩។ សំណួរទី១របស់ខ្ញុំ ចង់សួរលោកស្រីថា លោកស្រីទៅដល់ត្រាំកក់ហ្នឹងនៅពេលណា?

**លោកស្រី ជូ គឹមឡូន៖**

**ឆ៖** ចាស ខ្ញុំទៅដល់ត្រាំកក់ដល់អង្គតាសោម។ អង្គតាសោមហ្នឹង ស្រុកត្រាំកក់ ដល់អង្គតាសោមហ្នឹងដើរទៅពីភ្នំពេញទៅអស់រយៈពេល២២ថ្ងៃ។ ដើរទៅដល់ហ្នឹង ក៏ពួកខ្មែរក្រហមគេមកទទួលយើងឲ្យទៅនៅពោធិ៍(ព្រះ)សង្ឃនៅខាងលិច ផ្សារអង្គតាសោមហ្នឹង។ នៅខាងផ្សារអង្គតាសោមប្រហែលជា ២គីឡូ។ ចាស ហើយបានគេមិនទាន់ឲ្យធ្វើការងារថ្ងៃទៅដំបូង គេមិនទាន់ប្រមូលកម្លាំងដែលយើងទៅធ្វើការ គេនៅពិនិត្យអង្កេតសិនចាស។

**ស៖** សូមអរគុណលោកស្រី។ តើលោកស្រីទៅ<>ដល់ត្រាំកក់ហ្នឹងជាមួយនរណាខ្លះនៅក្នុងគ្រួសារ?

[១១:១៥:២៣]

**ឆ៖** ចាស ខ្ញុំទៅត្រាំកក់ជាមួយនឹងឪពុកខ្ញុំ ប្អូនប្រុសខ្ញុំ បងប្រុសខ្ញុំ និងកូនគាត់តូចៗ ហើយនិងខ្ញុំគ្រួសារខ្ញុំក៏កូន ក៏មានកូនតូចដែរ ពោះធំទៀតចាស។

**ស៖** លោកស្រីអាចបញ្ជាក់ពីចំនួនកូនរបស់បង<លោកស្រី>ដែលថាទៅជាមួយលោកស្រីហ្នឹងដែរឬទេ?

**ឆ៖** ចាស កូនគាត់៧ បួននាក់ ស្រីពីរ ប្រុសពីរ។

**ស៖** ហើយចុះ<>លោកស្រី មាន<ធ្វើដំណើរ>ជាមួយ<ប្ដី>លោកស្រីទេ?

**ឆ៖** ចាស ទៅជាមួយគ្នាទាំងអស់។ ហើយឪពុកខ្ញុំចាស់ជរាទៀត ម្ដាយខ្ញុំចាស់ដែរ ទៅទាំងអស់។

**ស៖** អម្បាញ់មិញលោកស្រីឆ្លើយជូនលោកប្រធានថា បានចិញ្ចឹមកូនបួននាក់។ អ៊ីចឹងកូនទាំងបួននាក់ហ្នឹងទៅជាមួយលោកស្រីទៅត្រាំកក់ហ្នឹងទេ?

**ឆ៖** ចាស ទៅៗជាមួយគ្នាទាំងអស់ចាស។

**ស៖** តើលោកស្រី<>ពេលទៅដល់ហ្នឹងលោកស្រីមានស្ថានភាពផ្ទាល់ខ្លួនយ៉ាងម៉េចដែរ?

**ឆ៖** ទៅដល់មុនដំបូងហ្នឹង យើងទៅតាមផ្លូវទៅតាមផ្លូវ២០ថ្ងៃ អង្ករយើងដាក់ទៅ ហើយឆ្នាំងយើងត្រូវដាំបាយហូបអស់ហើយ។ ទៅដល់នោះគេចែកឲ្យស្រូវភោគសាលីអីនោះ ដូចពោត ក្រហមៗដាំបាយហូប ហូបអត់ដាច់ទេ រឹង ហើយហូបពោតសាលីហ្នឹងយូរទៅខូចក្រពះពោះវៀនរហូតដល់ឥឡូវនៅស្គមអត់ព្រមធាត់ ថ្នាំហូបរហូតចាស។ ហើយគេឲ្យប្ដី ឲ្យប្ដីខ្ញុំហ្នឹងទៅធ្វើសង់ជារោងៗ ដើម្បីយក

អាអ្នកថ្មីៗទៅឲ្យនៅ នៅខាងជើងសាលាឃុំលាយបូរ ទៅពីពោធិ៍(ព្រះ)សង្ឃទៅធ្វើរោងបានប្រហែលពីរខែ ធ្វើរោងនៅកន្លែងសាលាឃុំលាយបូរហ្នឹង ហើយយកពួកយើងអ្នកថ្មី១៧បែកពីភ្នំពេញហ្នឹង យកទៅដាក់នៅខាងជើងៗ សាលាឃុំលាយបូរហ្នឹង ឲ្យនៅខ្ទមៗហ្នឹង ហើយទៅដល់ហ្នឹង បានគេមកចាប់ប្ដីខ្ញុំទៅចាស យកទៅពេលយប់។

[១១:១៨:២៧]

**ស៖** សូមអរគុណលោកស្រី។ លោកស្រីបានលើកឡើងពីពាក្យថាប្រជាជនថ្មី។ អ៊ីចឹងតើលោកស្រី ហើយនិងគ្រួសារលោកស្រីហ្នឹងត្រូវបានគេចាត់ទុកថាប្រជាជនថ្មីដែរឬទេ?

**ឆ៖** ចាស គេចាត់ទុកយើងប្រជាជនថ្មី ជាអ្នកថ្មី អត់មានសិទ្ធិៗដើរលេង អត់មានសិទ្ធិជំនុំគ្នា គេអ្នកចាស់គេមានសិទ្ធិ ហើយគេមានបាយហូប ហើយយើងហូបអាស្រូវភោគសាលីចាស។ ហើយដល់ពេលយប់ហ្នឹង ថ្ងៃដែលគេយកប្ដីខ្ញុំទៅហ្នឹង គេយកទៅម៉ោងប្រាំបួន ខ្ញុំកំពុងនឹងលួងកូនឲ្យដេក។ គេមកហៅគាត់ទៅប្រជុំរៀនសូត្រ ហើយខ្ញុំបានតវ៉ានឹងគេទៀតថា "ម៉ោងប្រាំបួនហើយប្រជុំអីទៀត?" ថា "អត់ទេ តាវិត ឲ្យហៅទៅប្រជុំ ប្រជុំរៀនសូត្រ"។ ហើយគាត់ក៏ឡើងលើកអាវពាក់ ហើយស្លៀកអត់បានស្លៀកខោទេ ថាប្រជុំមួយភ្លែតទេ គាត់ក៏លើកអាវពាក់ហើយស្លៀកក្រមាដើរចេញទៅ។

[១១:២០:០០]

**ស៖** សូមអរគុណលោកស្រី។ តើលោកស្រីអាចពន្យល់ជូនតុលាការអំពីអ្វីដែលបានកើតឡើងនៅពេលក្រោយមកទៀតទេ គឺក្រោយពេលដែលប្ដីរបស់លោកស្រីត្រូវបានចាប់ខ្លួននោះ។ តើមានរឿងអ្វីកើតឡើងទៀត?

**ឆ៖** ដល់គេចាប់ប្ដីខ្ញុំទៅបាត់។ ខ្ញុំពេលដែលចាប់ចេញទៅ ខ្ញុំបានលបមើលទៀត។ គេយក គេដើរទៅដល់លិច គេបណ្ដើរដើរដល់លិច គេកាន់ដែសងខាង បណ្ដើរដល់លិច។ ម៉ែគាត់ហ្នឹង គាត់លបមើល ឃើញគេយកខ្សែគោចង ចងស្លាបសេកទៅ។ ហើយម៉ែគាត់ ឪពុកគាត់ ជាអ្នកចាស់ទាំងអស់ ហើយខ្ញុំមកពីភ្នំពេញ ខ្ញុំមកពឹងគាត់អ្នកចាស់ មកពឹងគាត់អ្នកចាស់ ហើយដល់ហើយ គាត់ហ្នឹងជួយអត់បានទេ ថា៖ "ក្បាលអាណាសក់អាហ្នឹង" អត់មានជួយបាន កូនបង្កើតអត់ជួយបានទេ។ គេសួរថា៖ "មានអ្នកណាគាំទ្រលោកហ្នឹងទេ?" ថា៖ "អត់ប៉ានទេ។ ក្បាលអាណាសក់អាហ្នឹង"។ គេយកគាត់ទៅបាត់។ ទៅបាត់រហូតដល់ ប្រហែលជាមួយម៉ោងកន្លះ មួយម៉ោងកន្លះ ឬពីរម៉ោងទេ ស្រាប់តែឮសូរស្នូរកាំភ្លើងបាញ់បីគ្រាប់។ ពេលទៅហ្នឹងស្ពាយកាំភ្លើងមួយដើម ចាស។ អាពួកឈ្លបបីនាក់មកយកទៅហ្នឹង

មានប្រធានភូមិ និងឈ្លបឃុំ គេស្ពាយកាំភ្លើងមួយដើម យកគាត់ទៅហ្នឹង។ ហើយបន្ទាប់មក ស្អែកឡើងៗ ពីបានមួយថ្ងៃគេបញ្ជូនខ្ញុំចេញពីហ្នឹងហើយ ពីខាងជើងសាលាឃុំហ្នឹង គេបញ្ជូនចេញទៅហើយ។ គេបញ្ជូនខ្ញុំឱ្យទៅនៅកងផ្សេង ភូមិផ្សេង ខាងត្បូងសាលាឃុំៗលាយបូរម្ដង ចាស។ ហើយប្រើធ្វើការអ្វីៗគ្រប់មុខជាទម្ងន់។

[១១:២២:០៣]

**ស៖** ចុះក្រោយមកទៀត លោកស្រីមានបានទទួលព័ត៌មានពាក់ព័ន្ធនឹងជោគវាសនាប្ដីរបស់លោកស្រីទេ?

**ឆ៖** ទទួលព័ត៌មានបានអ្នកចាស់។ អ្នកចាស់ទាំងពីរបីនាក់ គេប្រាប់តាំងពីយប់ហ្នឹង។ គេមកប្រាប់ថាប្ដីឯងគេសម្លាប់ហើយ យកទៅសម្លាប់ហើយនៅឯក្រោយវត្តលាយបូរ នៅខាងលិចវត្តលាយបូរ នៅកន្លែងព្រៃ។ ចាស ទទួលព័ត៌មានអ៊ីចឹង។ ហើយម្ដាយក្មេកខ្ញុំ និងឪពុកក្មេកខ្ញុំ គាត់ជួយកូនអត់បាន។ គាត់ឈឺចិត្ត ឈឺចុកចាប់ គាត់ឈឺហូបបាយអត់ចូល អត់អីចូល រហូតដល់ស្លាប់។ ឪពុកក្មេក និងម្ដាយក្មេកហ្នឹងទៀត ចាស។ ទទួលព័ត៌មានបានថាស្លាប់ ថាអ៊ីចឹង ចាស ទទួលស្លាប់ហើយ។ ខ្ញុំធ្វើការនៅកងបី ខាងត្បូងសាលាឃុំ វាចាប់ខ្ញុំទៅនៅនឹង។ វាប្រើខ្ញុំច្រូត ខ្ញុំឆ្លងទន្លេ។ ឆ្លងទន្លេបាន ២៧ថ្ងៃ គេប្រើខ្ញុំច្រូតច្រូតស្រូវ។ ស្រែមិនឆ្ងាយពីផ្ទះទេ ស្រែជិតផ្ទះ ហើយឡើងកូនអឹម នៅសរសៃខ្ចី នៅមិនទាន់រឹងដៃរឹងជើងទេ។ គេអ្នកចាស់ គេអត់មានច្រូតទេ គេឱ្យយើងអ្នកថ្មីច្រូត។ ព្រោះយើងជាបុគ្គលដែលគេយកប្ដីទៅសម្លាប់។ គេត្រូវធ្វើទារុណកម្ម ឆ្លងទន្លេនៅៗផ្ទះហ្នឹងអត់មានឆ្មប -- អ៊ំ! មានពេទ្យទេ មានឆ្មប។ ឆ្មបយើងនៅជនបទហ្នឹង ភូមិហ្នឹង គេមកប្រសូត្រកូនឱ្យយើង ហើយអត់មានថ្នាំសង្កូវអីទាំងអស់។

**ស៖** សូមអរគុណ។ ដើម្បីឱ្យបានច្បាស់លាស់ ខ្ញុំគិតថាប្រហែលជាអាចមានបញ្ហាបកប្រែ។ តើលោកស្រីមានវត្តមានទេ នៅពេលដែលគេចាប់ខ្លួនប្ដីលោកស្រីនោះ?

[១១:២៤:១៩]

**ឆ៖** ចាស ខ្ញុំមានវត្តមាននៅសម្រាន្តជាមួយគ្នាហ្នឹង លួងកូនឱ្យដេកៗ សម្រាន្តជាមួយគ្នា ខ្ញុំតវ៉ាជាមួយគេហ្នឹងថា៖ "យប់ម៉ោងប្រាំបួនហើយហ្នឹង ប្រជុំអីទៀត ក្រែងប្រជុំចប់តាំងពីម៉ោងប្រាំបីនុ៎ង"។ ខ្ញុំតវ៉ាជាមួយគេ ហើយគេថា៖ "អត់ទេ នៅគាត់។ គេយកគាត់ទៅប្រជុំរៀនសូត្រ"។ ដល់ច្បាស់អ៊ីចឹង ខ្ញុំតវ៉ាជាមួយគេទៀតណា។ ហើយគេស្រែកដាក់ខ្ញុំថា៖ "គាត់ យកគាត់ទៅប្រជុំរៀនសូត្រ" ហើយកូនឃុំគេថា៖ "នាំកូនដេកទៅ កុំបាច់សួរសាកអី នាំកូនដេកទៅ"។ ហើយអ៊ីចឹង គេយកគាត់ទៅបាត់ទៅ

ហើយគេអត់ឲ្យយើងសួរសាក។ ខ្ញុំដេញដោលថាប្រជុំចប់ហើយ យកទៅប្រជុំអីទៀត។ គេប្រជុំចប់ប្រជុំ តាំងពីម៉ោងប្រាំមួយកន្លះដល់ម៉ោងប្រាំបីកន្លះ គេប្រជុំចប់។ ដល់ម៉ោងប្រាំបួនគេមកយក ចាស។ គេយកទៅវាយចោលតែម្តង អត់មានប្រជុំ អត់មានរៀនសូត្រអីទេ។ យកទៅវាយចោល ខ្ញុំទៅតាម -- ដល់បែកហើយ ខ្ញុំទៅតាមទៅមើលរណ្តៅទៀត ពេលបែកហើយ ទៅមើលរណ្តៅ កន្លែង -- គេដឹងថាកប់នៅកន្លែងហ្នឹង ចាស។ អ៊ីចឹងបានដឹងថាកម្សត់ៗណាស់។

**ស៖** សូមអរគុណលោកស្រី។ ចុះបើតាមលោកស្រីយល់ ហេតុអីបានគេចាប់ខ្លួនប្តីលោកស្រី?

**ឆ៖** មូលហេតុមកពីគាត់ហ្នឹងជាមន្ត្រីរាជការ តាំងពីសង្គមរាស្ត្រនិយមមករហូត។ គាត់ពាក់ស័ក្តិ មានស័ក្តិច្រើន គេឆែកៗខោអាវមួយបង្វិចៗម្នាក់ហ្នឹង ឆែកទៅយកអាអាវយកមកពាក់ គេឲ្យចេញមកហ្នឹង យកអាអាវមកពាក់មានរូបថតនៅក្នុងហោប៉ៅ។ រូបថតក្នុងហោប៉ៅហ្នឹងមានសក្តិ ហើយឃើញស័ក្តិហ្នឹង គេយកទៅហ្មង ចាស គេយកទៅរៀនសូត្រហ្មង ចាស។

**ស៖** សូមអរគុណ។ កាលពីមុនហ្នឹងបន្តិច លោកស្រីថាលោកស្រីមានផ្ទៃពោះនៅក្នុងសម័យខ្មែរក្រហម។ ដូច្នេះ ខ្ញុំចង់សួរពាក់ព័ន្ធទៅនឹងកូនដែលកើតនៅត្រាំកក់ ហើយនិងកូនដែលលោកស្រីនិយាយថាទៅជាមួយនឹងលោកស្រីទៅត្រាំកក់ហ្នឹង។ លោកស្រីបាននិយាយអំពីការសម្រាលកូន។ តើក្រោយពីសម្រាលហើយនោះ តើលោកស្រី<>បានមើលថែទាំកូនហ្នឹង<>ផ្ទាល់ដៃដែរទេ?

[១១:២៧:០៤]

**ឆ៖** បានថែតែកូនពៅមួយតូចទេ។ កូនបងៗគេទៅដើរកង អាយុ១៤, អាយុ១២, អាយុ១០ឆ្នាំ គេទៅកងអស់ហើយ ចាស។ នៅថែតែអាតូចហ្នឹង អាតូចជាងគេហ្នឹង ប៉ុនដល់យើងអត់បាយហូប ហូបអត់ឆ្អែត គេចែកបាយបបរហ្នឹង អាហ្នឹងទៅបានយូរមកបន្តិច បានគេបាយរួម។ មុនដំបូងគេចែកពោត ដល់ឆ្នាំ១៩៧៥ហ្នឹង ដល់ខែណាទេ គេចែកៗឲ្យហូបរួមហើយ។ ៧៥ហ្នឹងទៅបានយូរខែបន្តិច គេចែកបាយហូបរួម អាកូនហ្នឹងក៏ហូបអត់ឆ្អែត ហើយវាតែចេះវាររើសសម្បកក្តាម សម្បកខ្យងនៅក្រោមកន្លែងសម្រាន្តហ្នឹង គេធ្វើជារានឫស្សីៗឲ្យអ្នកថ្មីសម្រាន្ត។ ហើយផ្ទះអ្នកចាស់ គេខ្ពស់ចេះ ហើយយើងតសំយាបពីផ្ទះគេអ្នកចាស់ហ្នឹង មកនៅកៀនសំយាបផ្ទះគេ គេស្រណុកតាមដានយើងអីៗម៉េចៗ គេអ្នកចាស់ ចាស។ ហើយអ៊ីចឹងទៅ កូនខ្ញុំឈឺ អាកូនៗតូចហ្នឹងឈឺ ចាស ដល់ឈឺអ៊ីចឹងទៅ កូនហ្នឹងក៏ -- អ៎! ដល់ខ្ញុំសម្រាលកូនហើយ បានកូនហ្នឹងស្លាប់។ ដល់ពេលខ្ញុំសម្រាលបានកូនមួយហើយ បានកូនមួយធំហ្នឹងស្រីស្លាប់ អត់បាយហ្នឹង។ ដូចថាយើងកូនមានកូនតូចផង ហើយណាមួយអាហារយើងត្រូវហូប

ច្រើន ព្រោះយើងពោះធំ អំ! យើងសម្រាលកូនហើយ។ ហើយអ៊ីចឹងយើងហូបអត់ឆ្អែត ហើយដល់កូនតូចហ្នឹងវាអត់មានអីហូប ដូចជាហូបអត់ឆ្អែតអ៊ីចឹង វាឈឺ ឈឺជ្រុះសក់អស់រលីង ជ្រុះធ្មេញអស់រលីង ហើយឈឺស្លាប់ទៅ។ ចាស អាហ្នឹងកូនដែលចិញ្ចឹមហ្នឹង ហើយអាបងៗនៅគេកង ចាស។ នៅកងហ្នឹងមានស្លាប់ម្នាក់។

[១១:២៩:០៦]

**ស៖** សូមអរគុណ។ ដើម្បីឲ្យមានភាពច្បាស់លាស់នោះ ខ្ញុំចង់សួរបញ្ជាក់។ លោកស្រីថាទៅដល់ត្រាំកក់នោះជាមួយកូនបួននាក់ ហើយលោកស្រីក៏មានផ្ទៃពោះដែរពេលហ្នឹង។ ប្រសិនបើខ្ញុំស្តាប់មិនច្រឡំទេ កូនពីរនាក់<> ដែលទៅជាមួយលោកស្រីបានស្លាប់ដោយអត់អាហារ <និងខ្វះជីវជាតិ>។ តើ<ខ្ញុំយល់បានត្រឹមត្រូវទេ ចំពោះអ្វីដែលលោកស្រីបានប្រាប់យើងនៅថ្ងៃនេះ>?

**ឆ៖** អាកូនមួយតូចស្លាប់ដោយអត់អាហារ អាមួយកូន អាមួយធំអាយុ១៣នោះ វាទៅនៅកងកុមារ ហើយលួចដកដំឡូងគេហូប។ ហើយកងកុមារហ្នឹងមិនមែននៅលាយបូរជាមួយនឹងខ្ញុំទេណា។ កងកុមារហ្នឹង នៅខាងកើតផ្ទះតាម៉ុក ចាសនៅខាងកើតផ្ទះតាម៉ុក កងកុមារហ្នឹង។ ហើយលួចដកដំឡូងគេហូប ក៏គេយកវាទៅសម្លាប់ចោលទៅ ហើយបងខ្ញុំប្រាប់ថា គេមានវះពោះវះអីណាទៀត។ សម្លាប់ហ្នឹងឃោរឃៅព្រៃផ្សៃ មហាឃោរឃៅ ហើយកប់នៅរណ្តៅដូង។

**ស៖** សូមអរគុណ។ ដូច្នេះមានន័យថា កូនតូចស្លាប់ដោយអត់អាហារ ហើយកូនរាងធំបន្តិចហ្នឹង គឺធ្វើការនៅកងឆ្ងាយពីផ្ទះលោកស្រី <> គឺថា<កូនបងនោះ>ស្លាប់<ដែរ>អ៊ីចឹងមែនទេ?

**ឆ៖** ចាស ស្លាប់ដែរ។ ចាស បញ្ជាក់ហើយ ស្លាប់ដែរ ដោយគេសម្លាប់ដោយយើងលួចដកដំឡូងគេហូប។ ក្មេងវានៅហេរ នៅឃ្លាន ហូបបាយអត់ឆ្អែត វាលួចដកដំឡូងគេយកមកដុតហូប ហើយគេដឹង គេឃើញដុតហូបអ៊ីចឹង គេចាប់ចងយកទៅសម្លាប់ចោល។ បងខ្ញុំនៅខាងកើតផ្ទះតាម៉ុក នៅត្រសក់ផ្អែមហ្នឹង នៅជាមួយក្មួយខ្ញុំដែរហ្នឹង គាត់ប្រាប់ខ្ញុំ ខ្ញុំនៅខាងត្បូងសាលាឃុំលាយបូរ វិហារខ្ពស់ ហើយបងខ្ញុំគាត់ប្រាប់ គាត់ៗលួចល្អបមកប្រាប់ ពេលថ្ងៃលួចឆ្នក់មកពេលបាយ សម្រាកហើយ គាត់មកប្រាប់ថា អាវណ្ណារ៉ា គេសម្លាប់ហើយ។ លួចដកដំឡូងគេស៊ី វានៅកងកុមារដែរ មិនទាន់យុវជនទេ អាយុ១៣-១៤កាលនុ៎ង។

[១១:៣១:៤៧]

**ស៖** សូមអរគុណលោកស្រី។ ដើម្បីបញ្ចប់ពាក់ព័ន្ធនឹងបញ្ហាកូនរបស់លោកស្រីនេះ លោកស្រី

បានបញ្ជាក់ថា ពេលទៅដល់ត្រាំកក់ហ្នឹងមានផ្ទៃពោះ ហើយកើតកូននៅត្រាំកក់ហ្នឹង។ អ៊ីចឹងតើលោកស្រីអាច ពេលកើតហើយហ្នឹង អាចមើលថែកូនដែលទើបនឹងកើតដែរទេ ទារកដែលទើបនឹងកើតហ្នឹង?

**ឆ៖** ចាស ដូចខ្ញុំជម្រាបអ៊ីចឹង ទារកទើបនឹងកើតហ្នឹងបាន២៧ថ្ងៃ ចេញច្រូត។ ច្រូតស្រែជាប់ៗផ្ទះ ជាប់ៗរបងផ្ទះហ្នឹង ជុំវិញហ្នឹង គេឲ្យយើងច្រូត។ ច្រូតអ៊ីចឹងទៅបើកូនយំ ម្ដាយខ្ញុំស្រែកហៅ មកឲ្យកូនបៅ អ៊ីចឹងឲ្យកូនបៅហើយ យើងត្រូវច្រូតមួយសន្ទុះទៀត មកម៉ោងដប់កន្លះបានគេឲ្យយើងឡើងមក។ ចាស ឡើងមកអ៊ីចឹងទៅ ម្ដាយខ្ញុំគាត់អ្នកទៅយកបាយ គាត់យកបាយឲ្យខ្ញុំហូប។ ខ្ញុំអត់មានដើរទៅហូបបាយទេ។

**ស៖** សូមអរគុណលោកស្រី។ ឥឡូវនេះ ខ្ញុំចង់ចោទសំណួរមួយចំនួនពាក់ព័ន្ធនឹងសមាជិកគ្រួសារ ដែលលោកស្រីបានឆ្លើយនៅមុននេះបន្តិចនេះ។ ជាពិសេសបងរបស់លោកស្រី ដែលមកពីភ្នំពេញជាមួយគ្នា ហើយទៅដល់ត្រាំកក់។ តើគេធ្វើអ្វីដែរចំពោះបង<>លោកស្រីដែលទៅជាមួយលោកស្រីហ្នឹង?

**ឆ៖** បងប្រុសទៅជាមួយខ្ញុំ បងប្រុសៗ។ បងប្រុសដែលឈ្មោះ ជូ តេង ហ្នឹងទៅជាមួយខ្ញុំ។ បងស្រីអត់មានទៅជាមួយទេ។ បងស្រីគេទៅផ្លូវជាតិលេខ១។ បងប្រុសខ្ញុំហ្នឹង ទៅជាមួយខ្ញុំហ្នឹង ទៅចែកភូមិគ្នានៅ គាត់ទៅនៅភូមិពីរខាងលិចសាលាឃុំលាយបូរ ខាងលិចអង្គរាយហ្នឹង។ ភូមិកង៦ បងស្រីខ្ញុំទៅនៅកង៦ ហើយខ្ញុំនៅកាច់ត្រក កង៣ នៅជិតសាលាឃុំហ្នឹង កង៣។ ហើយបងស្រីហ្នឹងនៅអីកង៦ ខុសគ្នា ចាស។ បងប្រុសៗ និងបងថ្លៃស្រីមានកូនបួននាក់។

[១១:៣៤:២៧]

**ស៖** តើមានរឿងអីកើតឡើងចំពោះ<>បងប្រុសនុ៎ង<>?

**ឆ៖** ចំពោះបងប្រុសហ្នឹង គាត់ធ្វើការជាកងភ្លូរ ហើយគាត់ដឹងខ្លួនថា គេចុះឈ្មោះគាត់ហើយចុះឈ្មោះយកទៅវៃចោល បើមិនមុននិងក្រោយ ហើយគាត់ក៏ដើរបបួលគ្នា អាហ្នឹង១៩៧៧ណ៎ា គាត់នៅកងភ្លូររហូតមកដល់១៩៧៧ហ្នឹង គាត់ -- គេដើរ គាត់ដើរបបួលហៅគ្នាបះបោរចូល រត់ទៅវៀតណាម។ ហើយគាត់មកលាឪពុក លាម្ដាយខ្ញុំ លាឪពុកម្ដាយខ្ញុំហើយ គាត់មានស្បៀងអាហារគាត់ដាក់ទៅហើយក៏ទៅបានចំនួនបីថ្ងៃបានដឹងដំណឹងថា គេចាប់គាត់បាន គេសម្លាប់គាត់ យកមកសម្លាប់នៅភ្នំសន្លុង។ ហើយយកមកសហករណ៍មួយទៀត។

**ស៖** សូមអរគុណលោកស្រី។ តើលោកស្រីអាចឆ្លើយឲ្យបានលម្អិតបន្តិចទេ ថាតើគាត់ចេញ

ទៅហ្នឹងយ៉ាងម៉េច? <តើគាត់>ចេញទៅវៀតណាមហ្នឹង<យ៉ាងម៉េច>ដូចដែលលោកស្រីបានឆ្លើយអម្បាញ់មិញហ្នឹង? គាត់ទៅ<ដល់ទីនោះ>យ៉ាងម៉េច? ហើយទៅជាមួយនរណាខ្លះ? <តើគាត់អាចរត់គេចខ្លួនបានតាមវិធីណា?>ហើយហេតុអ្វីបានជាលោកស្រីដឹងថាគេចាប់គាត់សម្លាប់ចោលនោះ? <នេះជាអ្វីដែលលោកស្រីទើបតែបាននិយាយនៅថ្ងៃនេះ។>

**ឆ៖** ខ្ញុំដឹងៗដោយសារខ្ញុំនៅផ្ទះ យាយអ្នកមូលដ្ឋានគាត់ជាអ្នកសហករណ៍ដាំបាយនៅកង១ ជាកងគំរូ។ ដាំបាយឲ្យកម្មាភិបាលហូបនៅសហករណ៍លាយបូរហ្នឹង សាលាឃុំលាយបូរហ្នឹង គេសហករណ៍កង១ ជាសហករណ៍គំរូ សហករណ៍លេខ១គេ ហើយគេហ្នឹងដាំបាយគាត់ទៅផ្ទះ គាត់ទៅប្រាប់ម្ដាយខ្ញុំថា៖ “យាយអ៊្នា! កូនយាយគេតាមទាន់ហើយ ឥឡូវគេចាប់បាន គេសម្លាប់ចោលអស់ហើយ”។ ហើយយកមកម្នាក់ មកវ៉ៃបញ្ឆកទឹកត្រីហ្នឹងនៅកន្លែងសហករណ៍កង១ នៅកន្លែងដំដែក កន្លែងជាងដំដែក គេយកមកវ៉ៃបញ្ឆកទឹកត្រីហ្នឹង តែយាយហ្នឹងគាត់អត់ដឹងថា បងខ្ញុំហ្នឹងមុខយ៉ាងម៉េចទេ។ គាត់ថា៖ “កូនយាយឯងហ្នឹង គេចាប់បានហើយយកមកវ៉ៃ បញ្ឆកទឹកត្រី”។ អាហ្នឹងខ្ញុំអត់មានបានឃើញទេ ព្រោះរត់ទៅគេយកទៅសម្លាប់នៅភ្នំសន្ទុងខ្លះ។ ហើយគេយកមក មួយមកវ៉ៃបញ្ឆកទឹកត្រីឲ្យជាគំរូ កុំឲ្យមានអ្នករត់ទៅទៀត។ ចាស ខ្ញុំដឹងប៉ុណ្ណឹងចាស។

[១១:៣៧:២៩]

**ស៖** សូមអរគុណលោកស្រី។ ដូច្នេះ គឺលោកស្រីស្ដាប់ឮទេ លោកស្រីមិនបានឃើញផ្ទាល់ភ្នែកអំពីការសម្លាប់បងប្រុសនោះទេ។ អ៊ីចឹង<ហេតុអីបានជា>លោកស្រី<>គិតថា គាត់រត់ចេញទៅ<>? លោកស្រីមានព័ត៌មានទេ ថាគាត់រត់ចេញផុតពីត្រាំកក់ហ្នឹងដោយរបៀបម៉េចដែរ?

**ឆ៖** ចាស រត់ចេញហ្នឹងគាត់មានស្បៀងអាហារគាត់។ មានដុតម្សៅនំបញ្ចុកនោះបីដុំ ហើយនិងអង្ករច្រកក្នុងទៃ ហើយនិងកាម៉េលមួយសម្រាប់ដាំបាយហូបក្នុងព្រៃ។ ហើយគាត់ទៅហ្នឹង ព័ត៌មានដែលយាយហ្នឹងប្រាប់ខ្ញុំ យាយនៅសហករណ៍កង១ ប្រាប់ខ្ញុំថា គាត់មានដណ្ដើមកាំភ្លើងពីឈ្លបម្នាក់ៗ ធ្វើជាកងទ័ពខ្មែរក្រហមដូចគេដែរដើម្បីធ្វើដំណើរទៅកាន់ប្រទេសវៀតណាម។ ហើយគេតាមពីភូមិ ទៅបាត់ បាត់មនុស្ស គេតាមទៅទាន់ៗ គេចាប់មកសម្លាប់ចោល។ ដូចយាយហ្នឹងប្រាប់ខ្ញុំអ៊ីចឹងចាស។ គេតាមទាន់។

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះលោកស្រីនិយាយអំពីបងប្រុសម្នាក់ទៀត។ លោកស្រីអាចបញ្ជាក់បានទេ ថាមានរឿងអីកើតឡើងចំពោះបងប្រុសម្នាក់ទៀតនោះ?

[១១:៣៩:១៦]

**ឆ៖** បងប្រុសខ្ញុំម្នាក់ទៀត ធ្វើទាហាននៅខេត្តតាកែវ នៅជិតអូរតែលខេត្ត បន្ទាយស៊ុប។ គាត់ធ្វើទាហានយូរដែរហើយ គាត់មានបុណ្យស័ក្តិ។ ហើយពេលបែកពីតាកែវទៅដល់វត្តចំប៉ា គេចាប់គាត់ចងចងច្រើនគ្នាបណ្តើរទៅ យកទៅរៀនសូត្រ។ រៀនសូត្របាត់រហូតមិនដឹងជារៀនសូត្ររបៀបម៉េចទេបាត់រហូត។ ចាស ហើយបងថ្លៃខ្ញុំ ក៏គាត់ចាំប្តីគាត់អត់ឃើញវិលមកវិញ ទៅរៀនអត់ឃើញវិលមកវិញគាត់ក៏មកប្រាប់ម៉ែខ្ញុំ គាត់ទៅស្រុកគាត់ ទៅស្រុកគាត់នៅជិតភ្នំជីសូរ។ គាត់ទៅស្រុកគាត់ហ្នឹងវិញទៅបងថ្លៃខ្ញុំហ្នឹង។ ចាស ហើយបន្ទាប់ទៀត ទៅដល់ស្រុកហ្នឹងហើយ កូនគាត់មួយដែលថាធ្វើលោកហ្នឹងធ្វើលោកហ្នឹងកូនប្រុសច្បងបង្អស់បួសធ្វើលោក ជាអ្នកចាស់ អ្នកមូលដ្ឋាន។ អ្នកមូលដ្ឋានហ្នឹង គេឲ្យផ្សឹក១ ផ្សឹកដើម្បីស្ពាយកាំភ្លើងដើម្បីបាញ់បំបែកតាកែវ បំបែកភ្នំពេញហ្នឹង។ ដល់បាញ់បំបែកហើយអ៊ីចឹងដល់ពេលបែកហ្នឹងស្រាប់តែគេដឹង គេដឹងថា ក្មួយខ្ញុំហ្នឹងកូនខ្មាំង ឪពុកវាធ្វើទាហានពាក់ស័ក្តិច្រើនហើយដឹងអ៊ីចឹងក៏គេឲ្យប្រពន្ធ។ អាហ្នឹងគេផ្សឹកហើយ គេធ្វើទាហានហ្នឹង គេប្តេជ្ញា១ជាមួយពេទ្យស្រីពេទ្យស្រីនៅម្តុំជិតភ្នំជីសូរ ខាងត្បូងភ្នំជីសូរ ប្តេជ្ញាជាមួយពេទ្យស្រីហ្នឹងហើយ ពេលដឹងថា ហ្នឹងជាកូនខ្មាំង ឪពុកធ្វើទាហានស័ក្តិធំតាកែវ ជាទ័ពសាហាវ ទ័ពខ្លាំងអ៊ីចឹង គេឲ្យប្រពន្ធហ្នឹង ប្រពន្ធធ្វើពេទ្យ ពេទ្យស្រីហ្នឹងវះ វះពោះប្តីយកប្រមាត់ យកទៅធ្វើថ្នាំអីតទៅទៀត អ៊ីចឹងណ៎ះ! ធ្វើថ្នាំតទៀត។ បែក៧៥ហើយហ្នឹង គេដឹង១ថា ឪពុកកូនហ្នឹងជាមន្ត្រីធ្វើធំ គេឲ្យប្រពន្ធហ្នឹងចាប់ផ្តើមសម្លាប់ប្តី។ នុំងគេសួរថា៖ “ហ៊ានសម្លាប់អត់?” គេថា៖ “ហ៊ាន”។ ហ៊ានអ៊ីចឹងដើម្បីគេឡើងបុណ្យស័ក្តិ តែមានសម្លាប់មានអ៊ីចឹងគេឡើងបុណ្យស័ក្តិទៀត។

[១១:៤១:៥៤]

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំសូមត្រឡប់មកនិយាយអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោកស្រី ទុករឿងគ្រួសារចោលមួយឡែកសិន។ ខ្ញុំចង់សួរពាក់ព័ន្ធពីបទពិសោធន៍នៅត្រាំកក់។ តើលោកស្រីអាចដើរហើរបានដោយសេរីទេនៅស្រុកត្រាំកក់ហ្នឹង?

**ឆ៖** យើងដើរហើរបានតែពេលសម្រាកម៉ោងដប់មួយ ដល់ម៉ោងមួយជាងយើងត្រូវដល់ផ្ទះវិញយើងចង់ទៅសួរសុខទុក្ខបងប្អូន។ យើងដើរបានតែពេលបាយហើយ សម្រាក លៃយ៉ាងណាកុំឲ្យហួសពេលធ្វើការ តែហួសពេលធ្វើការ គេកសាងយើង ស្តីប្រដៅយើងទៀត។ អត់មានដើរហើយបានទេ។ដើរហើរដោយលួចលាក់។ ហ្នឹងហើយដែលដើរហើរមិនបានហ្នឹង គេហៅថា “គុកអត់ជញ្ជាំង” ហ្នឹងមិន

ងាយដើរបានទេ។ គុកអត់ជញ្ជាំងហើយ ធូន់ទៀត អម្រែកឡើងធូន់ទៀត បាក់កទៀត ចាំស មិនងាយទេ។

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំសូមត្រឡប់មកចម្លើយចុងក្រោយអម្បាញ់មិញពាក់ព័ន្ធនឹងបញ្ហាលំបាក។ តើលោកស្រីអាចរៀបរាប់បានទេអំពីការងារផ្សេងៗដែលគេឲ្យលោកស្រីធ្វើ បន្ទាប់ពីទៅដល់ត្រាំកក់នោះ?

[១១:៤៣:២៥]

**ឆ៖** ការងារផ្សេងៗ ខ្ញុំចាំទាំងអស់ អត់មានភ្លេចទេ អាការឈឺចាប់ហ្នឹងខ្ញុំចាំទាំងអស់។ ខ្ញុំស្ទូងខែស្ទូង ស្ទូង គេឲ្យខ្ញុំធ្វើអី ធ្វើកើតទាំងអស់ បើអ៊ីចឹងខ្ញុំស្លាប់បាត់ហើយ គ្មាននៅទេ។ ខ្ញុំប្រពន្ធខ្មាំងប្រពន្ធអីឯណា ហើយកូន ក៏កូនអ្នកមន្ត្រីរាជការចាស់ទៀត ហើយគេឲ្យខ្ញុំទៅស្ទូង ស្ទូងអង្កាល់ គេឲ្យខ្ញុំកាយអាចម៍ហាល ខ្ញុំកាយកើត។ ចិញ្ច្រាំទន្ទ្រានខែត្រដាក់គ្រលុក កាយអាចម៍ហាល យកទៅចាក់ចូលគ្នាហើយលុប ហើយដល់ខែរែក រែកដាក់ស្រែ យើងរែក ហើយខ្ញុំដឹកប្រឡាយ។ ជីប្រឡាយជី ហើយខ្ញុំស្ទូង១ហិកតាប្រាំពីរនាក់ ១ហិកតាខ្ញុំស្ទូងកើត ចុះខ្ញុំធ្លាប់នៅលាយបូរហ្នឹង ខ្ញុំមនុស្សធ្លាប់ចេះស្ទូង។ ចាសហើយប៉ុនដល់ពាក់ព័ន្ធដល់ឆ្នាំ១៩៧៧ បានខ្ញុំជួបតា។ ចាស ឲ្យខ្ញុំនិយាយអត់?

**ស៖** សូមអរគុណ អម្បាញ់មិញនេះលោកស្រីបញ្ជាក់អំពីពេលវេលាច្បាស់ គឺថាម៉ោងដប់កន្លះ<យប់>។ អ៊ីចឹងលោកស្រីអាចបញ្ជាក់ពីម៉ោងឲ្យបានច្បាស់ទេ តើធ្វើការពីម៉ោង<ប៉ុន្មានដល់>ម៉ោង<ប៉ុន្មាន>? ហើយគេមានផ្លាស់ប្តូរដែរឬទេ ពីមួយឆ្នាំទៅមួយឆ្នាំហ្នឹង ម៉ោងធ្វើការមានប្រែប្រួលដែរឬទេ? សូមជម្រាបជូនតុលាការ<ពីគំនិតលោកស្រី ចំពោះម៉ោងធ្វើការនោះ>។

**ឆ៖** ចាស ខ្ញុំកូនតូច គេឲ្យឡើងមកម៉ោងដប់កន្លះ ហើយដល់ពេលយើងកូនធំទៅ ឡើងសុទ្ធតែម៉ោងមួយដណ្តប់ ៗលើស អត់មានដប់កន្លះទៀតទេ។ ខ្ញុំកូនធំដើរធ្វើការទៅឆ្ងាយៗឡើងសុទ្ធតែម៉ោងដប់មួយ ដប់មួយកន្លះ។ ចាសហើយធ្វើការផ្លាស់ប្តូរគ្រប់លេណដ្ឋានទាំងអស់ តាមកន្លែងណាគេត្រូវការគេបញ្ជូនទៅកន្លែងហ្នឹង កន្លែងណាគេត្រូវសម្រុក បញ្ជូនទៅកន្លែងហ្នឹងរហូត។

**ស៖** សូមអរគុណ។ ព្រឹកមិញនេះ ឬក៏ម្សិលមិញយើងបានស្តាប់ឮសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតដែលថា នៅពេលដែលគាត់ឈឺ <ឬអស់កម្លាំង>អ៊ីចឹងគាត់មិនអាចធ្វើការបាន គាត់អាចសម្រាកបាន <មិនបាច់ធ្វើការទេ>។ អ៊ីចឹង ដូចលោកស្រីអ៊ីចឹងទេ ពេលដែលដូចថាមិនសូវស្រួលខ្លួន ឬក៏ឈឺអ៊ីចឹងអាចសុំគេសម្រាកបាន?

[១១:៤៥:០៣]

**ឆ៖** ចាស ពេលខ្ញុំទៅស្ទូង ពេលខ្ញុំទៅស្ទូងហ្នឹងដូចថាយើងសម្រុកស្ទូងខ្លាំងពេក ហើយណាមួយ កូនអឹមផង អ៊ីចឹងយើងត្រូវអស់កម្លាំង ទន់ដៃទន់ជើងដូចយើងស្ទូងអ៊ីចឹងទៅ ក្នុងទឹក វាអាចអស់កម្លាំងទៅវាអាចដួល។ អាចដួលអ៊ីចឹងទៅក៏គេឲ្យយើងឡើងមកកោសខ្យល់។ ឡើងកោសខ្យល់ហើយដល់យើងកោសខ្យល់ គេឃើញយើងដូចថាកោសខ្យល់នេះ បានគេឲ្យទៅផ្ទះ ចាស។ ហើយបើថាយើងសុំឈប់ កូនឈឺ។ បើថាយើងសុំឈប់កូនឈឺ យកកូនទៅពេទ្យ កូនឈឺអីត្រូវការម្ដាយនៅថែអី ព្រោះអីកូនវាអឹមទឹកដោះក្ដៅ យើងដើរធ្វើការនុះ។ អឹមទឹកដោះក្ដៅអ៊ីចឹងកូនហ្នឹងត្រូវឈឺ ត្រូវរាកអាចម៍ ត្រូវក្ដៅរងារ សុំគេឈប់ ដល់ពេលយើងទៅយកបាយនៅសហករណ៍គេថាយើង ឈ្មោះយើងទៅយកបាយនៅកង គេអត់ឲ្យបាយយើងទេ គេអត់ឲ្យបាយយើងហូបទេ។ ហើយដូច្នេះយើងត្រូវហូបរបបរបស់កូនរបស់ម្ដាយដែលម្ដាយនៅផ្ទះអ្នកមើលហ្នឹង ត្រូវចែករំលែករបបហ្នឹងមកហូប ឲ្យតែរួចៗមួយពេលទៅ។ ដល់តែស្អែកឡើងយើងទៅធ្វើការបានគេចែករបបទៀត ចាស។ អ៊ីចឹងរបបគេតឹងរ៉ឹងណាស់ យើងអត់ធ្វើការ គេត្រូវបង្អត់បាយយើង។ ត្រូវហូបរបបរបស់កូន។

**ស៖** ត្រឡប់មកឃ្លាចុងក្រោយអម្បាញ់មិញនេះ គឺថាបើអត់ធ្វើការអត់ឲ្យហូបទេ។ អ៊ីចឹងលោកស្រីអាចពន្យល់ជូនតុលាការបានទេថាៗមានផលវិបាកអ្វីខ្លះប្រសិនបើយើងអត់ទៅធ្វើការ? ក្រៅពីគេអត់ឲ្យហូបហ្នឹង តើ<>មាន<ផលវិបាក>អីទៀត?

**ឆ៖** គេមានធ្វើអីទៀតដល់យើង -- ព្រឹកឡើងយើងទៅធ្វើធម្មតាទៅ ធ្វើការឲ្យធម្មតាទៅគេចែកបាយហូបវិញ ហើយធ្វើការឲ្យធម្មតា ហើយកូនយើងទោះបីជាមិនទាន់ជាក៏យើងត្រូវតែធ្វើការដែរ យើងឈប់បានតែមួយកំណាត់ថ្ងៃអ៊ីចឹងទៅ ហើយក៏មួយថ្ងៃអ៊ីចឹងទៅ។ ត្រូវទៅធ្វើការវិញ មិនទាន់ជាក៏ត្រូវតែទៅដែរ តែឈប់យូរគេថាយើងសតិអារម្មណ៍ៗហ្នឹង គេយកយើងវៃចោល អត់ហ៊ានឈប់យូរទេ។

[១១:៤៨:៥០]

**ស៖** សូមអរគុណ។ ពីរដងរួចមកហើយដែលលោកស្រីនិយាយអំពីការភ័យខ្លាចក្នុងការ គេសម្លាប់ចោលពេលដែលអត់ធ្វើការ។ លោកស្រីអាចពន្យល់ជូនតុលាការបានទេថា ហេតុអ្វីក៏ខ្លាចគេយកទៅសម្លាប់ចោល?

**ឆ៖** គេថាពួកយើងពួកអ្នក១៧ហ្នឹង ពួកអ្នកនៅទីក្រុងខ្ជិល មិនចេះធ្វើអី សុទ្ធតែអ្នកធ្លាប់

ស្រណុក ហើយអ៊ីចឹងហើយគេចង់កម្ទេចចោលឱ្យអស់ ពួកដែលខ្ជិល ពួកដែលធ្វើមានជាប់ៗពាក់ព័ន្ធនឹងអ្នកធ្វើមន្ត្រីរាជការពីសង្គមចាស់ សង្គមលន់នល់ហ្នឹង គេត្រូវកម្ទេចចោលឱ្យអស់។ ហើយម្ល៉ោះហើយយើងអ្នក១៧ថ្មីហ្នឹង ចេះតែភ័យខ្លាចគេសម្លាប់ចោល គេប្រើអីធ្វើហ្នឹង កើតទាំងអស់ គឺប្រើអីធ្វើហ្នឹងកើតទាំងអស់។ អ៊ីចឹងបានៗរស់ដល់សព្វថ្ងៃ ចាស។

**ស៖** សូមអរគុណលោកស្រី។ មុននេះបន្តិចលោកស្រីបាននិយាយថាប៉ុន្មានខែក្រោយពីទៅដល់ត្រាំកក់ លោកស្រី<>ហូបរួម។ អ៊ីចឹងលោកស្រីអាចពន្យល់បានទេថា ការហូបរួមហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** ចាស ការហូបរួម យើងខំស្ទូងៗស្រែបានស្រូវខៀវងងឹតល្អស្គុះស្គុល ពេញស្រែទាំងអស់។ ច្រូតស្រូវពេញស្រែទាំងអស់ ក្រហមឆ្អិនឆ្អៅពេញស្រែ។ ដល់ពេលយើងហូបរួម គឺបាយបបរមួយវែកត្រឡោក។ បបរមួយវែកត្រឡោកហ្នឹងឆ្នាំងសម្លមួយដាក់កណ្តាល ហើយតុយើងហូបប្អូននាក់។ មួយវែកៗម្នាក់ហ្នឹងអស់ប៉ុណ្ណឹងឈប់ហើយ អត់មានអីថែមទៀតទេ។ ហើយអ៊ីចឹងទៅយើងអត់ស្លូវឆ្អែតដល់យើងសម្រុកការងារ តែមានភ្លាត់មាត់ថា "ហូបបាយអត់ឆ្អែត ហេវហាត់" គេត្រូវចាប់យកទៅរៀនសូត្រហើយ មិនដឹងរៀនសូត្រម៉េច រៀនសូត្រទៅបាត់រហូតៗ។ ប្រុសៗបានមានហូបអត់ឆ្អែត យើងស្រីអត់ស្លូវហ៊ានថា មានស្រីថាដែរៗ មានស្រីថាពីរនាក់ ថាហូបអត់ឆ្អែត ហ្នឹងគេយកវៃចោលបាត់។ រៀនសូត្របាត់។ ឥឡូវ ខ្ញុំចង់និយាយស្រីៗពីរនាក់ហ្នឹង។ ចាស បានទេ?

[១១:៥១:៣២]

**ប្រធានអង្គជំនុំ៖**

លោកស្រីឆ្លើយតែក្របខ័ណ្ឌតបចាំបាច់តបទៅនឹងសំណួរដែលសួរបានហើយ។ កុំឆ្លើយឱ្យហួសពីក្របខ័ណ្ឌចាំបាច់នៃការឆ្លើយតបទៅនឹងសំណួរ។ ហ្នឹងហើយ ឱ្យពេញលេញ ហើយនិងចាំបាច់សមល្មមទៅនឹងសំណួរដែលសួរហ្នឹងបានហើយ។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំមានសំណួរផ្សេងទៀត ដើម្បីសួរបន្តទៅនឹងចម្លើយរបស់លោកស្រី។ បើតាមការចងចាំនោះ ចាប់ពីពេលដែលលោកស្រីហូបរួមមក តើកម្រិតនៃការហូបហ្នឹងរបបនៃការហូបចុកហ្នឹងមានថយចុះទេ? ពេលដែល<>លោកស្រីហូបរួមហ្នឹង<> តើមានការបន្ថយរបបអាហារទេ?

**លោកស្រី ជូ គឹមឡួន៖**

**ឆ៖** ចាស មានបន្លយ។ ដល់ពេលណាពាណិជ្ជគេអត់បញ្ជូនអង្ករមក យើងត្រូវមានអង្ករទេ អត់មានអង្ករ។ អ៊ីចឹង គេត្រូវបន្ថយ ត្រូវបបរវាវ ហើយដាក់ដំឡូងលាយ។ ដាក់ដំឡូងចូលក្នុងរបបហ្នឹង ហើយដួសចែកមួយវែកម្នាក់ដូចដើម។ តែគេបញ្ចូលដំឡូង ចាស។ ជួនកាលគេបញ្ចូលដំបូងផ្លា ជួនកាលគេបញ្ចូលដំឡូងមី។ ចាស ហ្នឹងដល់របបអង្ករអត់មាន។ អត់មានស្រូវ អត់មានអង្ករអី ដាក់ដំឡូងវិញ។

[១១:៥៣:១៤]

**ស៖** សូមអរគុណ។ ជាថ្មីម្តងទៀត តើលោកស្រីចាំទេថា ប្រជាជនថ្មីទទួលបានរបបអាហារហ្នឹងដូចអ្នកមូលដ្ឋានដែរ ឬក៏មានការបែងចែកខុស<>?

**ឆ៖** ហូប អ្នកចាស់គេហូបជាមួយយើងមែនពិតនៅសហករណ៍មែនពិត តែក្នុងផ្ទះគេៗមានរបបគេនៅក្នុងផ្ទះ គេមានអង្ករគេនៅក្នុងផ្ទះសម្រាប់ស្រគួរហូបបន្ថែមពេលព្រឹក។ គេអាចពេលព្រឹក វាអាចដាំហូបបន្ថែមគេចេញទៅធ្វើការបាន។ តែយើងអ្នកថ្មីអត់មានទេ យើងហូបតែក្នុងសហករណ៍ហ្នឹងទេ។ អ៊ីចឹងហើយបានមានអ្នកហេវ អ្នកហត់ត្លួញហ្នឹង បានមានគេយកទៅវៃចោល។

**ស៖** សូមអរគុណ។ ដើម្បី<ឲ្យកាន់តែ>ច្បាស់។ តើនៅក្នុងរយៈពេលប៉ុន្មានឆ្នាំហ្នឹងលោកស្រីឃ្លានណាស់មែនទេ?

**ឆ៖** ចាស ឃ្លានហ្នឹងហួសពីនិស្ស័យឃ្លានហើយ ព្រោះពោះប្រហោងពោះផង ឃ្លាន។ ដូរ ប៉ុន្តែមានដូរដែរ មានសារុងអី ដោយទៅមួយ ដោយទៅពីរអ៊ីហ្នឹងយកទៅដូរគេអ្នកមូលដ្ឋានហ្នឹង ផ្ទះយើងនៅជាមួយជិតហ្នឹង ដូរអ្នកមូលដ្ឋានហើយយើងអាចលួចដាំបាយ លួចដាំបាយហូបបានខ្លះ។ តែអត់ប៉ានដាំផ្ទាំងទេ ដាំៗពេលយប់ ដាំកាំសៀវទឹកទៀត យ៉ឺស! ហួស។ ដាំៗហូប ពេលព្រឹកយើងចេញទៅសម្រុកការងារចាស។

[១១:៥៥:០៤]

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះលោកស្រីឆ្លើយអំពីការងារដែលលោកស្រីបានធ្វើនៅពេលទៅដល់ត្រាំកក់។ លោកស្រី<លើកឡើង>ថា<បាន>ស្ទូងស្រូវ ប្រមូលអាចម៍ ហើយនិងការងារ<ចុងក្រោយ>មួយទៀតនោះ គឺជីកប្រឡាយ។ លោកស្រីអាចពន្យល់ឲ្យបានលម្អិតបន្តិចទេ អំពីការជីកប្រឡាយហ្នឹង ថានៅពេលណា? ហើយនៅកន្លែងណា លោកស្រីបានចូលរួមក្នុងការជីកប្រឡាយហ្នឹង?

**ឆ៖** ចាស ជីកប្រឡាយតាំងពីយើង៧៦ រហូតដល់៧៧ ខែប្រាំង ឲ្យតែខែប្រាំងយើងច្រូតហើយយើងត្រូវជីកប្រឡាយ។ ចាស ជីកប្រឡាយតាមប្រព័ន្ធភ្លឺនៅតាមជនបទ ហើយនិងប្រឡាយធំៗ

គឺប្រឡាយថ្មល់ តថ្នល់ទៅតាកែវ ចាស ជីកទៅដល់ស្ពានីយបូមទឹកអូរចំបក់។ អាហ្នឹងប្រឡាយធំហើយ អាហ្នឹងកងមុខ កងចល័តអីទៅហ្នឹងអស់ហើយ កម្លាំងធំៗហ្នឹង។ ជីកៗហ្នឹង ដាក់កងនៅហ្នឹងប្រហែលជាជាងកន្លះខែ បានជីកហើយបានដកចេញ។ ហើយពេលដែលជីកប្រឡាយហ្នឹងហើយ ដែលខ្ញុំបានជួបមេដឹកនាំខ្មែរក្រហមនៅសង្គមខ្មែរក្រហម សង្គមអីធិបតេយ្យអីហ្នឹង ខ្ញុំជួបនៅពេលហ្នឹង។ កាលខ្ញុំជីកប្រឡាយនៅ១៩៧៧ហ្នឹង ហើយខ្ញុំឈរមើលគាត់ គាត់ដើរគ្នាគាត់បីនាក់ហ្នឹង ហើយ តាម៉ុកម្នាក់ទៀត បួននាក់ ចាស។ ឃើញគាត់នៅពេលហ្នឹង ហើយគាត់ក៏ឈរនិយាយថា ឲ្យពួកយើងអ្នកជីកប្រឡាយហ្នឹង ពលករហ្នឹង ជីកសម្រុក ដើម្បីធ្វើបូមទឹកពីស្ពានីយអូរចំបក់ហ្នឹង ពីបឹងអូរចំបក់ហ្នឹងទៅធ្វើស្រែនៅម្តុំខាងលិចថ្នល់រទេះភ្លើង ១ហិកតា៣តោន ទៅ៦តោន ឲ្យសម្រុកពលកម្ម។ ហើយដើម្បីឈានធ្វើស្រូវបានល្អ ដើម្បីឈានទៅរកភាពសម្បូររុងរឿងហូបបាយហូបបាយស្រួយៗ សម្បូររុងរឿង ដើម្បីបានៗមានកម្លាំងពលំ តែតាមពិតអត់មានឃើញឲ្យបានស្រួយទេ។ គាត់ -- អត់មានបានបាយស្រួយទេ តាំងពីជីកប្រឡាយហ្នឹងហើយ ធ្វើស្រូវល្អយ៉ាងណា ក៏អត់បានបាយស្រួយហូបទេ។ ហើយអ្នកជីកប្រឡាយហ្នឹងមិត្តភក្តិខ្ញុំមានបីនាក់ ដែលត្រូវបាត់ខ្លួនដោយសារត្អូញត្អែរថា "ហូបបាយអត់ឆ្អែត"។ ហើយ គាត់គាត់ថា គាត់មានតែប៉ុណ្ណឹងហូបបាយអត់ឆ្អែតបាត់ខ្លួនទាំងបីនាក់។

[១១:៥៨:៤៣]

**ស៖** សូមអរគុណលោកស្រី។ ដើម្បីឲ្យយល់ច្បាស់អំពីលំដាប់លំដោយនៃហេតុការណ៍លោកស្រីបានបញ្ជាក់ថា <លោកស្រីនិយាយថា នៅពេលទៅដល់>លោកស្រីចាប់ផ្តើមជីកប្រឡាយហើយនិងទំនប់ហ្នឹង<។> <>នៅឆ្នាំ៧៧ <តើលោកស្រីបាននិយាយថា> នៅកន្លែងធ្វើការហ្នឹងលោកស្រីបានឃើញមេដឹកនាំខ្មែរក្រហមមួយចំនួន<មែនទេ? តិច ឬច្រើន> តើលោកស្រី<អាច>ចាំទេថា នៅឆ្នាំណាដែរឲ្យប្រាកដថាលោកស្រីបានឃើញមេដឹកនាំខ្មែរក្រហមទាំងអស់ហ្នឹង?

**ឆ៖** ចាស ឆ្នាំ១៩៧៧ហ្នឹង ខ្ញុំដើរកងមុខទៅឆ្ងាយ ៧៧ហ្នឹង ប៉ុន្តែខែមិនដឹងខែណាខ្ញុំចាំមិនច្បាស់ មិនដឹងជាខែ២ ខែ៣ ឬក៏ខែ៤ ខែ៥ ខ្ញុំចាំខែអត់ច្បាស់ទេ ព្រោះវា -- យើងវាយូរ អត់ច្បាស់។ ហើយមេដឹកនាំទាំងបីនាក់ហ្នឹងគាត់ជិះឡានទៅ។ ជិះឡានទៅឈប់នៅកន្លែងស្ពានីយគល់ស្ពានអូរចំបក់ហ្នឹង គាត់ចុះដើរមើលពួកខ្ញុំរែកដី ដើរអ៊ីចឹងទៅលិចទៅ ហើយមេកង មេគណៈឃុំអីទៅតាមទាំងអស់។ ដើរទៅតាមជាមួយគាត់ទាំងអស់។ ហើយបន្ទាប់មក បានមួយថ្ងៃពីរថ្ងៃ បានមានបាត់មិត្តភក្តិខ្ញុំអស់បីនាក់ ចាស។

[១២:០០:៣២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកថ្ងៃត្រង់ចាប់ពីពេលនេះតទៅ រហូតម៉ោងមួយសាមសិបនាទីរសៀលនេះ ក៏សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនេះ រូបនេះ ឈប់សម្រាកនៅក្នុងអំឡុងពេលឈប់សម្រាក ហើយនិងឱ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ ឲ្យមុនពេលដែលអង្គជំនុំជម្រះចូលមកកាន់បន្ទប់សវនាការ។ ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំង លោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការ នៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលឱ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០១ នាទី ដល់ម៉ោង ១៣:៣៤នាទី)*

[១៣:៣៤:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនិងផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

បង្អន់សិន លោកស្រីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

សូមអញ្ជើញលោក រ៉ិចទ័រ កូប៉េ។

**លោក រ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរទាក់ទងទៅនឹងការដាក់ឯកសារព្រឹកនេះ ដាក់មកពីការិយាល័យសហព្រះរាជអាជ្ញា។ យើងពិនិត្យឃើញថាយើងបានចម្លើយថ្មីនៅក្នុងរឿងក្តី០០៤ ខ្ញុំមាន

សំណួរពីរ។ ទី១ ថាតើចម្លើយនេះនឹងផ្សព្វផ្សាយទៅឲ្យភាគី តើវាមានភាពពាក់ព័ន្ធទៅនឹងសាក្សីនេះដែរ ឬអត់ ឬក៏សាក្សីបន្ទាប់ដែរឬអត់ទេ? សំណួរទី២ ខ្ញុំចង់សួរថា តើចម្លើយកំណត់ហេតុទាំងបួននេះគឺថា ការដាក់មកឲ្យភាគីនេះ តើតែប៉ុណ្ណឹង ឬក៏អាចនឹងមានកំណត់ហេតុ ឬក៏ព័ត៌មានឯកសារបន្ថែមទៀត មុននឹងឈានទៅវគ្គខាងមុខនោះ បាទ?

[១៣:៣៥:៤៦]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមអភ័យទោសដែលខ្ញុំឆ្លើយ<ពីជួរទី២>។ ចម្លើយគឺថាកំណត់ហេតុទាំងបួននេះគឺមិនទាក់ទងទៅនឹងវគ្គសាក្សីនេះ ឬក៏ដើមបណ្ដឹងរដ្ឋប្បវេណីបន្ទាប់ទេ។ <ចម្លើយទៅនឹងសំណួរផ្សេងទៀត> គឺនៅ<មានការ>ស៊ើបអង្កេតកំពុងបន្ត ហើយក៏មានកំណត់ហេតុថ្មីៗទៀត ហើយតាមដែលខ្ញុំដឹង គឺមិនមានពាក់ព័ន្ធនឹងការសាក្សីដែលជំនុំជម្រះទេ គឺយើងបានដាក់សំណើ។ កាលណាមានការអនុញ្ញាតឲ្យដាក់ចូលកំណត់ហេតុទាំងអស់នេះ យើងនឹងប្រកាសឲ្យភាគីបានដឹង។ <ប៉ុន្តែវាមិនពាក់ព័ន្ធនឹងសាក្សីដែលជំនុំជម្រះទេ។ បើតាមខ្ញុំចាំ ដូចជាមានចំនួនតិចទេ> ប៉ុន្តែ<ក្នុងចំណោមកំណត់ហេតុទាំងបួននោះ មានកំណត់ហេតុបីមានពាក់ព័ន្ធនឹងសាក្សីជំនុំជម្រះ ប៉ុន្តែពួកគេមិនមែននៅក្នុងក្រុមដែលនឹងមកជំនុំជម្រះនៅបី ឬបីសប្ដាហ៍ក្រោយនោះទេ>។

**ប្រធានអង្គជំនុំ៖**

បាទ វាច្បាស់លាស់ហើយអ៊ីចឹងបាទ។ សូមអញ្ជើញសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី!

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** សូមអរគុណលោកប្រធាន។ សួស្ដីលោកស្រី ហើយខ្ញុំនឹងបន្តសួរលោកស្រីបន្តទៀត ហើយនិងនាំលោកស្រីមកនិយាយពីរយៈកាលឆ្នាំ១៩៧៧ ខែកុម្ភៈ មីនា មេសា <ឬខែឧសភា។> <> កាលពីព្រឹកមិញ<លោកស្រីបានប្រាប់យើងថា> លោកស្រីបានឃើញអ្នកដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមបានមកធ្វើទស្សនកិច្ចនៅកន្លែងដែលលោកស្រីធ្វើការ គឺនៅត្រាំកក់។ លោកស្រីបាននិយាយផងដែរ<កាលពីព្រឹក>អំពីឈ្មោះតាម៉ុក។ អ៊ីចឹងចង់ដឹងថាតើបើតាមលោកស្រីចាំ តើមានអ្នកដឹកនាំផ្សេងទៀតទេ ដែលអមតាម៉ុក នៅថ្ងៃនុ៎ង?

**លោកស្រី ជូ គឹមឡន៖**

**ឆ៖** ចាស នៅសង្គមកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហម គឺលោក អ៎! តាម៉ុក គាត់បានអមមេ

ដឹកនាំខ្មែរក្រហមបីរូប ដែលមានជិះរថយន្តទៅ ឈប់នៅទីនោះ លោក ប៉ុល ពត, ខៀវ សំផន, នួន ជា ហើយនិង តាម៉ុក។ តាម៉ុក គាត់ជិះឡានគាត់ដោយខ្លួន ចាស។ គាត់ទៅទស្សនកិច្ចនៅការដ្ឋានប្រឡាយកន្លែងជីកប្រឡាយអូរចំបក់ ដើម្បីបូមទឹកនៅបឹងអូរចំបក់ចុះទៅស្ពានីយ ចុះទៅខាងលិចថ្នល់រទេះភ្លើង ដើម្បីធ្វើស្រែឲ្យបានបីដងក្នុងមួយឆ្នាំ ចាស។

[១៣:៣៨:៤៥]

**ស៖** សូមអរគុណលោកស្រី។ លោកស្រីបានឲ្យឈ្មោះ លោក ខៀវ សំផន ហើយនួន ជា។ អ៊ីចឹងខ្ញុំចង់ដឹងថាតើលោកស្រីស្គាល់លោក ខៀវ សំផន មើលទៅស្គាល់ថាជា ខៀវ សំផន តាមរបៀបណា?

**ឆ៖** ចាស ខ្ញុំស្គាល់ដោយសារ ខ្ញុំនៅធ្វើការហ្នឹងជាមួយនឹងមេកង មេក្រុម មេកង ប្រធានកង ប្រធានកងគេថា "អូ៎! លោក ប៉ុល ពត មកហើយ ខៀវ សំផន" ហើយខ្ញុំឈរមើលៗ ញញឹមដាក់គាត់ទៀត ហើយគាត់ -- ហើយគេ -- ហើយខ្ញុំក៏ស្រវារែកដីកាប់ដីធ្វើការឲ្យសកម្ម។ ហើយគាត់ដើរទៅលិចដើរបង្ហួសទៅលិចផុតប្រឡាយហ្នឹង ហើយមិនដឹងជាគាត់ទៅណាទៀត ខ្ញុំរែកដីបន្តទៅទៀត។ ចាស ខ្ញុំស្គាល់គាត់ច្បាស់ ចាស។

**ស៖** តើមុនថ្ងៃនុ៎ង តើលោកស្រីធ្លាប់បានឃើញលោក ខៀវ សំផន ទេ?

**ឆ៖** ខ្ញុំធ្លាប់ឃើញតាំងពីសង្គមរាស្ត្រនិយម ព្រោះអីមានកាសែតបិទរូបតំណាងរាស្ត្រ ហើយខ្ញុំបានអាន បានស្គាល់ឈ្មោះគាត់តាំងពីសង្គមរាស្ត្រនិយម ជំនាន់មុន។ ហើយបាន -- ដល់ពេលហ្នឹងគាត់ចុះទៅក៏ខ្ញុំបានស្គាល់គាត់។ ចាស ហើយគាត់បានដើរហៅមេកង មេក្រុម ប្រធានភូមិ គណៈឃុំអីដើរតាមគាត់ហ្វូងទៅៗ ហើយខ្ញុំរែកដីបន្ត ចាស។ ហើយគាត់ទៅដល់ ថ្ងៃហ្នឹងគាត់ទៅដល់សហករណ៍ កង១ទៀត។ បងខ្ញុំនៅខាងជើងសហករណ៍កង១ គាត់បានឃើញដែរ ឃើញមេដឹកនាំខ្មែរក្រហមទាំងបីនាក់ដើរទៅដល់ម្តុំ ហួសសហករណ៍កង១ បន្តិចចាស។

**ស៖** សូមអរគុណលោកស្រី។ លោកស្រីក៏បាននិយាយអំពីឈ្មោះ នួន ជា ដែរអម្បាញ់មិញនេះ។ អ៊ីចឹងខ្ញុំចង់ដឹងថា តើហេតុអីក៏លោកស្រីដឹងថាថ្ងៃនោះគឺលោក នួន ជា ដែលទៅធ្វើទស្សនកិច្ចនោះ?

[១៣:៤១:៣០]

**ឆ៖** ចាស អ្នកមូលដ្ឋាន គេអ្នកចាស់ មេកងគេធ្លាប់ចេញចូលប្រជុំជាមួយបានគេស្គាល់ចាស។

គេមេកង គណៈស្រុក គណៈឃុំ ហើយគេស្គាល់ គេនិយាយប្រាប់មេកង។ មេកងខ្ញុំស្គាល់និយាយប្រាប់ខ្ញុំថា៖ “ប្រមុខរដ្ឋកម្ពុជាចុះមកទស្សនកិច្ច។ ព្រោះគាត់ជាប្រមុខរដ្ឋដឹកនាំប្រទេសកម្ពុជា កាច់ចង្កូតនាវាប្រទេសកម្ពុជា អ្វីៗគឺគាត់អ្នកនាំមុខ” ចាស។

**ស៖** សូមអរគុណ។ លោកស្រីក៏បានថាមាន តាម៉ុក ផងដែរនៅក្នុងគណៈប្រតិភូហ្នឹង។ ហើយខ្ញុំចង់ដឹងថាមុនហ្នឹង មុនថ្ងៃទស្សនកិច្ចហ្នឹង លោកស្រីធ្លាប់បានឃើញ តាម៉ុក ទេ?

**ឆ៖** ធ្លាប់ឃើញជាញឹកញាប់ ព្រោះខ្ញុំនៅជិតអូរចំបក់ ជិតផ្ទះតាម៉ុក ចាស។ គាត់ឧស្សាហ៍ មកឃុំលាយបូរ។ ខ្ញុំឃើញគាត់ញឹកញាប់។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមត្រឡប់មកនិយាយព័ត៌មានមួយដែលលោកស្រីបានផ្តល់កាលពីមុនសម្រាកនេះ។ លោកស្រីបាននិយាយអំពីក្មួយម្នាក់ដែលជាព្រះសង្ឃ ដែលត្រូវបានគេបង្ខំឲ្យសឹក។ អ៊ីចឹង ខ្ញុំសូមឲ្យលោកស្រីពន្យល់ឲ្យបានលម្អិតអំពីរឿង<រ៉ាវពាក់ព័ន្ធនឹង>ក្មួយលោកស្រី<> ដោយពន្យល់ឲ្យច្បាស់ថាតើ លោកស្រីជាប់សាច់ឈាមអ្វីហ្នឹងគាត់? <សូមលោកស្រីជួយប្រាប់ផងថាតើមានអ្វីកើតឡើងចំពោះរូបគាត់ក្រោយមកទៀត?>

**ឆ៖** ចាស ក្មួយខ្ញុំជាក្មួយបង្កើត។ ឪពុកក្មួយហ្នឹងជាបងប្រុសខ្ញុំបង្កើត។ ហើយក្មួយហ្នឹងសង្គមរដ្ឋលន់នល់ហ្នឹង ម្តាយខ្ញុំបញ្ជូនចៅគាត់ឲ្យទៅនៅខាងព្រៃកប្បាស ជិតភ្នំជីសូរហ្នឹង។ ត្រង់ហ្នឹងគេ យាយតាគេជាមូលដ្ឋាន អ្នកចាស់។ ហើយក៏យកទៅក៏បួស ខ្លាចចៅគាត់ហ្នឹងគេបញ្ជូនទៅច្បាំង ក៏បំបួសៗ។ ដល់ពេលបួសហើយគេចង់វ៉ៃសម្រុកឲ្យបែកតាកែវ គេផ្សឹក។ ផ្សឹកហើយប្តេជ្ញា ចាស ប្តេជ្ញាជាមួយពេទ្យភូមិគេហ្នឹង ប្តេជ្ញាៗ អ៊ីចឹងទៅដល់ពេលគេវ៉ៃបែកទីក្រុងភ្នំពេញ និងបែកទីក្រុងតាកែវ គេដឹងប្រវត្តិរូប។ គេថាប្រវត្តិរូបក្មួយខ្ញុំហ្នឹងជាកូនមេទាហាននៅបន្ទាយស៊ុប។ ហើយគេក៏ហៅប្រពន្ធហ្នឹងមកពិភាក្សាឲ្យសម្លាប់ប្តីចោល។ ថា “តើបានឬអត់?” អាហ្នឹង៧៦ហើយណ៎ះ! ៧៦ យើងបែកពីភ្នំពេញមក គេសម្លាប់នៅ៧៦ ហ្នឹងហើយ។ ចាស ដល់ពេលបែកហើយនេះ បែកយើងរំដោះបាន បានជីដូនជន្លួងម៉ែខ្ញុំ គាត់មកប្រាប់ពីរឿងរ៉ាវដែលមានវះពោះ វះអីហ្នឹង។ ចាស ដឹងដោយសារជន្លួងជាយាយយាយបង្កើតរបស់ចៅហ្នឹង ជន្លួងម្តាយខ្ញុំ។

[១៣:៤៥:២៧]

**ស៖** ខ្ញុំសូមអរគុណ កាលព្រឹកមិញ លោកស្រីបានលើកឡើងផងដែរ តាមរយៈការបកប្រែនេះឮពាក្យថា “ការរៀបការ” លោកស្រីបានប្រើពាក្យអំមិញហ្នឹង “ប្តេជ្ញា” ដែរ។ អ៊ីចឹង ខ្ញុំចង់ឲ្យលោកស្រី

ពន្យល់ទៅតុលាការថា <តើ>ក្ដួយរបស់លោកស្រីហ្នឹងបានរៀបការ<ទេ> ហើយក្នុងលក្ខខណ្ឌយ៉ាងដែរ ពេលដែលគេឲ្យគាត់រៀបការនោះ?

**ឆ៖** ចាស សូមទោស "ប្ដេជ្ញា" មិនមែនរៀបការ។ ប្ដេជ្ញាៗនៅមុនយើងបែក យើងបែកទីក្រុងភ្នំពេញចាស។ ប៉ុល ពត គេឲ្យប្ដេជ្ញា ហើយប្រពន្ធហ្នឹងធ្វើពេទ្យសង្គមកិច្ច។ ចាស ដល់ពេលបែកទីក្រុងតាកែវ បែកទីក្រុងភ្នំពេញ ដឹងថាប្ដីហ្នឹងជាកូនខ្មាំង គេថាកូនខ្មាំង។ កូនខ្មាំងធំអ៊ីចឹង គេឲ្យប្រពន្ធហ្នឹងវះពោះយកប្រមាត់ធ្វើថ្នាំសង្គមកិច្ចគេទៀត។ ចាស មូលហេតុហ្នឹងបានថា ជីដូនហ្នឹងមក ដល់តែពេលបែកហើយគាត់មកយំសស្រិកសស្រាក់អាណិតចៅ។ អាណិតចៅគាត់អត់មាននៅភូមិកន្លែងហ្នឹងទៀតទេ។ គាត់សុំគេនិរទេសខ្លួនចេញទៅនៅឆ្ងាយ នៅកន្លែងហ្នឹង គាត់នៅអត់បានទេ គាត់អាណិតចៅ ចាស ប៉ុណ្ណឹង។

[១៣:៤៧:០០]

**ស៖** ខ្ញុំនៅសល់សំណួរមួយទៀត។ តាមពិតខ្ញុំអត់សូវយល់ពីព្រឹត្តិការណ៍ហ្នឹងទេ ពិបាកយល់។ តើក្ដួយរបស់លោកស្រី ដែលក្រោយមកជាលោកសង្ឃ ហើយក្រោយមកគេផ្សឹកហ្នឹង បន្ទាប់មកគាត់ហ្នឹង គេរៀបការគាត់<ទេ>នៅ<ជំនាន់>របបខ្មែរក្រហម<?> អ៊ីចឹងខ្ញុំយល់អត់សូវច្បាស់ <សូមលោកស្រីជួយបញ្ជាក់ផង។>

**ឆ៖** បួសជាលោកសង្ឃ ហើយគេផ្សឹក។ ដល់គេផ្សឹកហើយ គេចាប់ឲ្យប្ដេជ្ញា។ ចាប់ឲ្យប្ដេជ្ញាហើយបំពាក់អាវុធ ធ្វើកងទ័ពខ្មែរក្រហម ដើម្បីមកបាញ់ទីក្រុងតាកែវ។ ចាស បាញ់ទីក្រុងតាកែវបែកបានហើយ គេដឹងថាកូនមេទាហាន។ ក្ដួយខ្ញុំហ្នឹងជាកូនមេទាហានបន្ទាយស៊ុបតាកែវ គេក៏ឲ្យនាងជាស្រីហ្នឹង ប្រពន្ធហ្នឹង "ហ៊ានសម្លាប់ប្ដីឬអត់ កូនខ្មាំង?" ប្រពន្ធហ្នឹងគេឆ្លើយថា "ហ៊ាន"។ គេហ៊ានសម្លាប់ គេសម្លាប់ខ្មាំងដើម្បីគេបដិវត្តន៍គេ។ គេក៏ហ៊ានសម្លាប់ចងឆ្កាង គេវះពោះ។ វះពោះហើយ គេយកប្រមាត់យកទៅធ្វើថ្នាំ សង្គមកិច្ចគេ។ ចាស រឿងហ្នឹងប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

សំណួរដដែលៗនេះ គឺទំនងតែមានពាក្យមួយទេ ដែលលោកស្រីឆ្លើយហ្នឹង អត់យល់។ អង្គជំនុំជម្រះ ក៏ដូចជាមេធាវីសួរលោកស្រី មិនយល់អំពីលោកស្រីប្រើពាក្យ "ប្ដេជ្ញា" តើប្ដេជ្ញាហ្នឹងទៅធ្វើកងទ័ពដើម្បីទៅធ្វើសង្គ្រាមជាមួយនឹងទាហានលន់ នល់ ឬក៏ប្ដេជ្ញាហ្នឹងមានន័យថា រៀបការជាមួយនឹងគ្រូពេទ្យ? អាហ្នឹងញែកឲ្យដាច់ថា ប្ដេជ្ញាហ្នឹងមានន័យថា បកស្រាយថា លោកស្រីយល់ថាតើគាត់ប្ដេជ្ញា

ដើម្បីចូលទៅធ្វើបម្រើកងទ័ពដើម្បីវាយរំដោះទីក្រុងតាកែវ ឬក៏ប្ដេជ្ញាហ្នឹងគឺមានន័យថា រៀបយកស្ត្រីដែលជាគ្រូពេទ្យភូមិហ្នឹងធ្វើជាប្រពន្ធ? ឆ្លើយបានទេ? ឲ្យច្បាស់លាស់ចំណុចនេះ តែប៉ុណ្ណឹងទេ មិនបាច់ឲ្យវែងទេ។

**លោកស្រី ជូ គឹមឡន៖**

**ឆ៖** ប្ដេជ្ញាយកគ្រូពេទ្យសង្គមហ្នឹងជាប្រពន្ធ! ចាស។

**ប្រធានអង្គជំនុំ៖**

តទៀត សូមអញ្ជើញតទៀតលោកស្រីមេធាវី!

[១៣:៤៩:៤៥]

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៖**

**ស៖** អឺចឹងខ្ញុំសូមចោទសំណួរបន្តមួយទៀត។ តើលោកស្រីអាចពន្យល់ពីលក្ខខណ្ឌ ឬក៏កាលៈទេសៈនៃការរៀបការហ្នឹងទេ <គេធ្វើយ៉ាងម៉េចដែរ?> លោកស្រីដឹងពី<បរិបទ>នៃការរៀបការហ្នឹងទេ?

**លោកស្រី ជូ គឹមឡន៖**

**ឆ៖** រៀបការក្មួយហ្នឹងខ្ញុំអត់ដឹងទេ ព្រោះគេនៅស្រុកព្រៃកប្បាស ខ្ញុំនៅលាយបូរ។ ដល់សង្គមប៉ុល ពត បានខ្ញុំបានឃើញអ្នកប្ដេជ្ញា ដែលនៅកន្លែងខ្ញុំនៅ អាហ្នឹងបានមាន។ នោះ ខ្ញុំអត់ដឹងទេ។ ដឹងដោយសារជីដូន ជីដូនអ្នកនៅជាមួយក្មួយខ្ញុំហ្នឹងចាស ត្រូវជាចៅ ចៅម្ដាយខ្ញុំ ដឹងតាមជីដូនហ្នឹងទេ។

**ស៖** ខ្ញុំសូមអរគុណដែលបានឆ្លើយបំភ្លឺ។ ឥឡូវនេះ ខ្ញុំសូមសួរបន្តទៅនឹងអ្វីដែលលោកស្រីបានឆ្លើយទៅតុលាការហ្នឹង។ លោកបាននិយាយថា បាន<ឃើញ>ពិធីការនៅក្នុង<>ឃុំរបស់លោកស្រី<>។ តើអឺចឹង តើលោកស្រីធ្លាប់ឃើញគេរៀបការនៅ<>នៅក្នុងឃុំលោកស្រី<ផ្ទាល់ទេ នៅពេលនុ៎ង>?

[១៣:៥១:០៨]

**ឆ៖** ខ្ញុំឃើញគេប្ដេជ្ញាតាមភូមិខ្ញុំដែរ កងខ្ញុំដែរ ប៉ុន្តែវាតិចគូទេ។ ដល់ពេលប្អូនប្រុសខ្ញុំ ប្អូនប្រុសមានយុវជនពីរនាក់ ប្ដេជ្ញានៅសហករណ៍កង១ អាហ្នឹងច្រើន។ តាម៉ុក អ្នកមកប្ដេជ្ញា។ តែតាមភូមិឃើញតិចគូទេ បីបួនគូទេចាស។

**ស៖** បើសិនជាខ្ញុំ<មិន>យល់ច្រឡំទេ គឺថាលោកស្រីធ្លាប់បានធ្វើជាសាក្សីនៃការរៀបការនៅ

ក្នុងឃុំរបស់លោកស្រី គឺថាមានតែពីរបីគូទេការនៅពេលហ្នឹង។ ហើយលោកស្រីបានឮគេនិយាយថា នៅក-១ នោះ គឺថាមានការរៀបការច្រើនជាងហ្នឹង អ៊ីចឹងមែនទេ? តើអ៊ីចឹងមែនទេ ដែលលោកស្រីចង់រៀបរាប់ទៅតុលាការនេះ?

**ឆ៖** ចាស នៅ ក-១ ហ្នឹង កន្លែងសហករណ៍កង១ កងគំរូហ្នឹង ប្អូនខ្ញុំដែរ ចាស វាត្រូវប្ដេជ្ញាៗហ្នឹងដែរ។ គេចាត់មកតាមភូមិ ទៅពីភូមិទៅវាប្ដេជ្ញា។ ៣០គូ ឬក៏៣២ទេ ប្អូនខ្ញុំទៅប្ដេជ្ញាហ្នឹង។ ប្ដេជ្ញាហើយអត់បាននាំប្រពន្ធហ្នឹងមកផ្ទះទេចាស។ ប្ដេជ្ញាហើយគឺប្រពន្ធហ្នឹងទៅកង នៅធ្វើការតាមកង កងកសិករ។ កាលពីមិនទាន់ប្ដេជ្ញា នៅកងយុវជន ដល់ពេលយើងមានគ្រួសារប្ដេជ្ញាប្រពន្ធហើយ គេឲ្យកងកសិករ រែកដី ជីកប្រឡាយធម្មតាដូចយើងអ៊ីចឹងដែរ ដូចអ្នកអីៗ ស្ត្រីមេម៉ាយ មានគ្រួសារ តាមកង។

[១៣:៥៣:០៥]

**ស៖** ត្រង់ចំណុចនេះ ខ្ញុំសួរសំណួរចុងក្រោយមួយ។ តើអ្នកណាជាអ្នករៀបចំពិធីរៀបការនេះ បើតាមលោកស្រីដឹង?

**ឆ៖** តាមខ្ញុំដឹងគឺ គេថាអង្គការបក្សត្រូវឲ្យប្ដេជ្ញា។ ឲ្យប្ដេជ្ញាៗជាប្ដីប្រពន្ធអ៊ីចឹង ប៉ុន្តែឃើញតែតាម៉ុក ទេមកណ៎ា។ ហើយអង្គការគេ តាម៉ុក ហើយ តាម៉ុក មិនដឹងជាគាត់ទទួលបានផែនការហ្នឹងពីណាទៀត។ តែគាត់មករៀបចំការប្ដេជ្ញាហ្នឹង ក្នុងសហករណ៍កង១ មុខពាណិជ្ជ អ៎! សាលាឃុំលាយបូរ ។

**ស៖** ខ្ញុំសូមអរគុណ។ ឥឡូវខ្ញុំសូមត្រឡប់មកនិយាយពីព្រឹត្តិការណ៍មួយ ដែលលោកស្រីបាននិយាយកាលពីព្រឹកមិញ។ លោកស្រីបានពន្យល់ថា បងប្រុសរបស់លោកស្រីបានព្យាយាមរត់ទៅវៀត-ណាម។ ខ្ញុំចង់ឲ្យយល់ច្បាស់ពីចំណុចនេះ អ្វីដែលលោកស្រីបានឃើញ។ តើលោកស្រីពិតជាបាននិយាយកាលពីព្រឹកមិញថាបងប្រុសរបស់លោកស្រីត្រូវបានគេចាប់មកវិញ ដោយខ្មែរក្រហមចាប់មកវិញ ហើយគេ<>បានជះទឹកត្រីលើគាត់។ តើលោកស្រីបាននិយាយអ៊ីចឹងមែន ឬក៏ខ្ញុំយល់ច្រឡំទេលោកស្រី?

**ឆ៖** ចាស ខ្ញុំនិយាយអ៊ីចឹង ជាការពិត។ ចាស ខ្ញុំនិយាយអ៊ីចឹងជាការពិតមែន។

[១៣:៥៤:៥៨]

**ស៖** ខ្ញុំសូមអរគុណច្រើន។ ដើម្បីឲ្យច្បាស់ពីព្រឹត្តិការណ៍នេះ ខ្ញុំសូមរំឭកលោកស្រី ហើយលោកស្រីចាំឆ្លើយតប។ មានឯកសារមួយគឺឯកសារ E3/5469, ERN ជាភាសាបារាំងគឺ 00822246,

ERN ជាភាសាអង់គ្លេស <00746219>, ERN ជាភាសាខ្មែរគឺ 00506465។ នៅក្នុងឯកសារនេះ មានលើកឡើងឈ្មោះ រិន។ អ៊ីចឹងខ្ញុំចង់ដឹងថាតើឈ្មោះ រិន ហ្នឹង លោកស្រីស្គាល់ទេ? ហើយលោកស្រីអាចពន្យល់ជូនតុលាការថា រិន ហ្នឹងជានរណា? ហើយមានរឿងអីកើតឡើងចំពោះឈ្មោះ រិន ហ្នឹង?

**ឆ៖** ឈ្មោះ រិន ហ្នឹងជាមិត្តភក្តិបងខ្ញុំ ផ្ទះនៅជិតគ្នាជាប់គ្នា ហើយគាត់ពីរនាក់ហ្នឹងគាត់អ្នកដើរទៅបបួលគ្នាបានប្រាំមួយ-ប្រាំពីរនាក់ហ្នឹង រត់ទៅវៀតណាម ហើយទៅដល់ឆ្ងាយបន្តិចមិនដឹងភូមិណាទេ គាត់បានដណ្តើមកាំភ្លើងពីឈ្លបគេមួយដើម បានស្លាយទៅ ហើយយាយដែលគាត់មកប្រាប់ម៉ាក់ម៉ែខ្ញុំហ្នឹង គាត់អត់ដែលស្គាល់មុខបងខ្ញុំទេ។ គេថា "កូនយាយឯងហ្នឹងត្រូវគេចាប់បានយកមកហើយ ចង វ៉ៃ ធ្វើបាបសួរចម្លើយហើយជះទឹកត្រីដាក់"។ ហើយខ្ញុំទាំងម្តាយខ្ញុំក៏នាំគ្នាយំ។ គាត់រត់ទៅបានជាមិនដឹងប្រាំថ្ងៃ ក៏ប្រាំមួយថ្ងៃ ឬប៉ុន្មានថ្ងៃទេ។ ខ្ញុំវាអត់ចាំ ដឹងតែគេចាប់បានយកមកវាយធ្វើបាបចាស។

[១៣:៥៦:៤៩]

**ស៖** ខ្ញុំសូមអរគុណលោកស្រី។ តើលោកស្រីធ្លាប់បានឮពាក្យ -- អង្កាល់ដែលលោកស្រីនៅត្រាំកក់<អំឡុងពេលនោះ> លោកស្រីធ្លាប់ឮពាក្យ "ការខុសសីលធម៌" – ពាក្យ "ខុសសីលធម៌" ធ្លាប់ឮពាក្យហ្នឹងទេ?

**ឆ៖** ខ្ញុំឮពាក្យហ្នឹងជាញឹកញាប់ ហើយបានឃើញជាញឹកញាប់ទៀត។ ខុសសីលធម៌គេ អ្នកណាដែលខុសសីលធម៌គេចាប់យកទៅរែកដី។ ដាក់រែកដីក្នុងមួយថ្ងៃឲ្យហើយប៉ុន្មានម៉ែត្រៗអ៊ីចឹងទៅ។ ហើយយើងដើរទៅរែកដីដែរយើងគ្រាន់តែងាកមើលអ៊ីចឹងទៅ ឃើញគេរែកដីពីរគូ ខុសសីលធម៌ពីរគូ ដាក់ឲ្យរែកដីក្នុងមួយប្រឡាយហ្នឹង ពីរគូហ្នឹងចាស។

**ស៖** តើលោកស្រីដឹងទេ <>ថា<ការ>ខុសសីលធម៌<ប្រភេទណា>ដែលគូទាំងពីរគូបានប្រព្រឹត្តកាលនោះនោះ<>?

**ឆ៖** គេថាលបស្រលាញ់គ្នាៗ ហើយស្ត្រីហ្នឹងមេម៉ាយ ហើយលបស្រលាញ់ជាមួយនឹងពូៗ។ ពូៗហ្នឹង ខុសសីលធម៌គេដឹង គេដាក់ទារុណកម្មឲ្យរែកដី។ ហើយមួយចំនួនទៀតដាក់ទារុណកម្មហើយខ្មាសគេចងកសម្លាប់ខ្លួនចាស។

[១៣:៥៨:៤៨]

**ស៖** ត្រឡប់និយាយអំពីព័ត៌មានចុងក្រោយ <>ចំពោះអ្នកដែលគេចោទប្រកាន់ថាខុសសីលធម៌ហ្នឹង <និងអ្នក>ចងកខ្លួនឯងហ្នឹង <តើ>លោកស្រីជាសាក្សី<ចំពោះហេតុការណ៍នោះ> ឬក៏គ្រាន់តែឮ

គេនិយាយថាតាមគេទេ? អ៊ីចឹងសូមឲ្យលោកស្រីបំភ្លឺតុលាការបន្តិចមើលថាតើរឿងវាយ៉ាងម៉េចដែរ?

**ឆ៖** ចាស ខ្ញុំអត់ៗដឹងដែររឿងហ្នឹង។ ខ្ញុំឮតាមគេ។ គេហ្នឹងអ្នកមូលដ្ឋានទៀតណាមកប្រាប់ហ្នឹង។ បែបមានចាប់សម្លាប់មែនក៏មិនដឹង ប៉ុន្តែអ្នកមូលដ្ឋានគេមកប្រាប់ខ្ញុំថា "អូរ! អ៊ីហ្នឹងខ្លាសគេ ឥឡូវចងក សម្លាប់ខ្លួនហើយ"។ ខ្ញុំអត់បានឃើញទេ ប៉ុន្តែដឹងតែខុសសីលធម៌ គេយកទៅដាក់នៅវត្តៗលាយបូរ គេដាក់គុកនៅហ្នឹង ហើយត្រង់ចងកខ្លួនឯង ឬក៏គេអ្នកចងខ្ញុំអត់ដឹងទេ ព្រោះអ្នកមូលដ្ឋានគេមកនិយាយប្រាប់ថាអ៊ីហ្នឹងចងកសម្លាប់ខ្លួនចាស។

**ស៖** សូមអរគុណ។ ឥឡូវ ខ្ញុំសល់សំណួរចុងក្រោយមួយ។ ព្រឹកមិញហ្នឹងលោកស្រីចង់និយាយ <>ពីស្ត្រីពីរនាក់ ហើយលោកស្រីបាន<ប្រាប់>លោកប្រធានដែរពេលហ្នឹង។ អ៊ីចឹងៗ ខ្ញុំចង់សួរលោកស្រីថាលោកស្រីចង់និយាយអំពីអ្វីពីស្ត្រីពីរនាក់ព្រឹកមិញ ដែលលោកស្រីបានសុំថាចង់មានមតិយោបល់បន្តិចបន្តួចហ្នឹង?

[១៤:០០:១៩]

**ឆ៖** ស្ត្រីពីរនាក់ជាមិត្តភក្តិខ្ញុំនៅធ្វើការកង កងជិតជាប់ៗគ្នា។ ហើយគាត់ជាប្អូនរបស់លោកៗ -- ប្អូនរបស់លោកអ្នកចម្រៀងៗនៅវិទ្យុជាតិ អ៊ុយ សាមិត, អ៊ុយ សាម៉ាន ហើយប្អូនលោក អ៊ុយ សាខន ជាអ្នកភ្លេង។ ចាស មិត្ត -- ស្រីៗពីរនាក់ហ្នឹងជាមិត្តភក្តិខ្ញុំធ្វើការនៅកង ហើយគាត់រែកដី គាត់ ខ្លាំងពូកែណាស់ គ្មានអ្នកណាខ្លាំងដល់គាត់ទេ។ គាត់រែកបង្គី បីមួយចំហៀងៗ។ រែកខ្លាំងហើយ ក៏គាត់ត្អូញៗថា "ហូបបាយអត់ឆ្អែតទេ" ហើយឲ្យពង្រឹងគោលជំហរៗប្តេជ្ញាប្រឹងរែកដី ហើយហូបបាយអត់ឆ្អែត "ស្លល្ពៅព្រឹក ត្រឡាច – ព្រឹកល្ពៅ ល្ងាចត្រឡាចស្ល អ៊ីចឹងរាល់ថ្ងៃហើយហូបអត់កើត"។ និយាយតែប៉ុណ្ណឹងគត់ ហើយក៏គេចាប់គាត់យកទៅឲ្យនៅពាណិជ្ជ គេឲ្យទៅហូបបាយឆ្អែត គេយកគាត់ឲ្យនៅពាណិជ្ជលាយបូរឲ្យទៅហូបបាយឆ្អែត ឲ្យរែងអង្ករ។ រែងអង្ករនៅពាណិជ្ជហ្នឹង ហើយក៏ពួកនីរសារភូមិខ្ញុំហ្នឹង និរសារភូមិខ្ញុំៗនៅហ្នឹង គេយកព័ត៌មាន យកនាំព័ត៌មានមកចូលភូមិ គេដឹងរឿងមិត្តខ្ញុំពីរនាក់ហ្នឹងទាំងអស់។ មានអ្នកកម្មាភិបាលនៅក្នុងហ្នឹង គឺចាប់រំលោភគ្រប់គ្នាទាំងអស់ នៅពាណិជ្ជ សាលាឃុំលាយបូរ។ បំពាននូវមិត្តភក្តិខ្ញុំពីរនាក់ហ្នឹងទាំងអស់។ ហ្នឹងឈ្លបភូមិខ្ញុំគេយកសំបុត្រអី មានការ រាយការណ៍អី គេនីរសារឃុំភូមិហ្នឹងគេមកហើយ។ ហើយមកគាត់ទៅវិញ គាត់បាននិយាយលេងជាមួយខ្ញុំថា៖ "អូយ! អត់បានទេ តែមានខុសគឺយកដាក់ពាណិជ្ជហ្នឹង ពួកគណៈឃុំ ពួកអ្នកធំនៅក្នុងហ្នឹង គឺគេរំលោភហើយជាការស្រេច។ ហើយគេនាំយកទៅបាត់ មិនដឹងគេយកដាក់នៅគុកណា សម្លាប់នៅកន្លែង

ណា បាត់រហូត"។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំសូមអរគុណលោកស្រី។

លោកប្រធានខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញា ដើម្បីមានឱកាសនៅក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

[១៤:០៣:៣២]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ សូមគោរពភាគី និងអង្គសវនាការទាំងមូល។ សូមជម្រាបសួរ លោកស្រី គីមឡន ខ្ញុំជាតំណាងសហព្រះរាជអាជ្ញាជាតិ ហើយខ្ញុំសំណួរមួយចំនួនតូចចង់ឲ្យលោកស្រីបញ្ជាក់។

**ស៖** សំណួរទី១របស់ខ្ញុំគឺពាក់ព័ន្ធទៅនឹងរឿងដែលអ្នកស្រីបានឆ្លើយប្រាប់មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងទៅនឹងការដែលអ្នកស្រីបានឃើញ តាម៉ុក ជាញឹកញាប់។ ខ្ញុំចង់សួរបញ្ជាក់ថានៅពេលដែលអ្នកស្រីនិយាយថាអ្នកស្រីបានឃើញ តាម៉ុក ជាញឹកញាប់ហ្នឹង តើភាគច្រើនអ្នកស្រីឃើញ តាម៉ុក នៅកន្លែងណា?

**លោកស្រី ជូ គីមឡន៖**

**ឆ៖** ចាស ខ្ញុំឃើញនៅការដ្ឋានដែលខ្ញុំធ្វើការ ដែលខ្ញុំរែកដី ប្រឡាយ ហើយខ្ញុំទៅស្ទូងជាសម្រុក ១ហិកតាប្រាំពីរនាក់ ១ហិកតាអីហ្នឹង ខ្ញុំឃើញហើយ។ ឃើញ តាម៉ុក គាត់ -- ជួនកាលគាត់ជិះកង់ទៅជួនកាលគាត់ជិះឡានអាហ្ស៊ីបគាត់ទៅ។ ចាស ឃើញជាញឹកញាប់។

**ស៖** លោកស្រីដឹងទេថា តាម៉ុកគាត់ ចុះឡើងនៅការដ្ឋានហ្នឹង គាត់ទៅធ្វើអ្វីដែរនៅកន្លែងហ្នឹង?

**ឆ៖** តាមដែលខ្ញុំដឹង និងមេកងខ្ញុំថាៗ គាត់ទៅពង្រឹងគោលជំហរ ឲ្យយើងធ្វើការសម្រុក ដើម្បីឈានទៅរកមហារអស្ចារ្យ មហាលោតផ្លោះ មហាសម្បូរសប្បាយ។ មហាសម្បូរសប្បាយគាត់គឺហូបបបរមួយវែកហ្នឹង ចាស។

[១៤:០៥:២២]

**ស៖** លោកស្រីដឹងទេ តាម៉ុក មានតួនាទីអីដែរ នៅស្រុកត្រាំកក់ហ្នឹង?

**ឆ៖** តាម៉ុក មានតួនាទីជាចៅហ្វាយខេត្ត ត្រួតបីខេត្ត: កំពង់ស្ពឺ តាកែវ កំពត។ ចាស តួនាទីគាត់ធំធេងណាស់។

**ស៖** ចាស អរគុណ។ ហើយកាលពីព្រឹកមិញ លោកស្រីបានរំឭកដល់កូនប្រុសច្បងរបស់លោកស្រី ដែលត្រូវបានគេយកទៅសម្លាប់នៅខាងកើតផ្ទះតាម៉ុក។ លោកស្រីដឹងទេថាផ្ទះតាម៉ុក មានទីតាំងនៅក្នុងភូមិ ឃុំ ណាដែរ?

**ឆ៖** ចាស ផ្ទះតាម៉ុក នៅផ្លូវទៅបារាយណ៍ ខាងជើងខេត្តតាកែវៗ ហើយនៅពីខាងលិចថ្នល់ ចាស។ នៅលើទឹក – ផ្ទះតាម៉ុកនៅលើទឹក។

**ស៖** នៅចាំភូមិទេ នៅក្នុងភូមិឃុំអីដែរ?

**ឆ៖** ឃុំបារាយណ៍ ស្រុកដូនកែវ។

**ស៖** ចាស សូមអរគុណ។ ឥឡូវខ្ញុំចូលមកដល់ប្រធានបទមួយផ្សេងទៀត។ កាលពីព្រឹកមិញ លោកស្រីបានប្រាប់អង្គសវនាការថា លោកស្រីហើយនិងក្រុមគ្រួសាររបស់លោកស្រីត្រូវបានគេជម្លៀសពីភ្នំពេញទៅស្រុកត្រាំកក់ ប៉ុន្តែពេលទៅដល់ភ្លាមហ្នឹង ប្ដីរបស់លោកស្រីត្រូវបានគេឲ្យទៅជួយសាងសង់រោងនៅខាងកើតសាលាឃុំលាយបូរ។ សូមឲ្យលោកស្រីបញ្ជាក់ ថាតើនៅកន្លែងណានៃសាលាលាយបូរហ្នឹង ហើយគាត់ទៅធ្វើហ្នឹង ធ្វើអីគេឲ្យពិតប្រាកដ?

[១៤:០៧:៣០]

**ឆ៖** ចាស ទៅធ្វើហ្នឹង នៅពីខាងជើងសាលាឃុំលាយបូរ មិនមែនខាងកើតទេណា៎។ ចាសពីខាងជើងសាលាឃុំលាយបូរហ្នឹង មានកាប់ដើមត្នោត ចាំង។ ចាំងៗ ហើយកាប់កូនឈើដើម្បីសង់ជាៗរោង រោងតូចៗសម្រាប់យើងអ្នកថ្មីចាស។ សង់ជារោងតូចៗហ្នឹង ប្រហែលជាពីរខែ បីខែ សង់ហើយបានគេដឹកនាំយើងពីខាងលិចអង្គតាសោម មកខាងលិចសាលាគំរូអង្គតាសោមហ្នឹង មកនៅអាខ្ទមៗគេសង់ហើយហ្នឹង។ ចាសមកសង់ខ្ទមច្រើនណាស់ ព្រោះអីប្រជាពលរដ្ឋដែលចេញពីភ្នំពេញទៅ មកនៅម្ដុំហ្នឹង។ ហើយគេបញ្ជូនពីនុងធំមកអស់ មកនៅកន្លែងគេសាងសង់នៅពីខាងជើងសាលាឃុំលាយបូរ។ ចាស មកនៅកន្លែងហ្នឹងបានប៉ុន្មានថ្ងៃ បានមួយថ្ងៃ ពីរថ្ងៃហ្នឹង គេមកហៅយកទៅសម្លាប់ចោលនៅពេលហ្នឹង។ គេឆែកឃើញរូបថត។

[១៤:០៨:៣៧]

**ស៖** ចាសអរគុណ។ ចង់ដឹងថារោងដែលសង់នៅខាងជើងសាលាលាយបូរហ្នឹង គឺសង់សម្រាប់ដាក់តែប្រជាជនថ្មី ឬក៏មានប្រជាជនមូលដ្ឋាននៅក្នុងហ្នឹងដែរ?

**ឆ៖** ប្រជាជនចាស់មូលដ្ឋាននៅហ្នឹងដែរចាស។ ប្រជាជនគេមូលដ្ឋានចាស់ហ្នឹង គេមានរបបគេហូបគ្រប់គ្រាន់ណ៎ា។ យើងគេចែកពោតសាលីចាស។

**ស៖** សូមឲ្យលោកស្រីជួយបញ្ជាក់ថា ការដែលសាងសង់រោងហ្នឹង គឺរោងហ្នឹងគេសាងសង់នៅពេលប្ដីលោកស្រីទៅដល់ហ្នឹង គេកំពុងតែសាងសង់ ឬក៏ពេលទៅដល់បានគេបង្គាប់ឲ្យសាងសង់ថ្មីតែម្ដង? ឬក៏ទៅដល់ហ្នឹងគេកំពុងតែសង់រួចខ្លះហើយ?

**ឆ៖** ចាស រឿងហ្នឹងខ្ញុំអត់ដឹងទេ។ អត់ដឹងថា គេមានសាងសង់ហើយខ្លះឬនៅ អត់ដឹងទេណ៎ះ! តែដល់ពេលខ្ញុំជម្លៀសពីភ្នំពេញទៅដល់ភូមិហ្នឹង បានគេហៅប្ដីយើង អ្នកមានកម្លាំង ពូៗដែលមានប្រពន្ធហ្នឹង ទៅសាងសង់ទាំងអស់គ្នា គ្រប់គ្នា គ្រប់គ្រួសារដែលមានកម្លាំងប្រុសៗ។ ទៅសាងសង់ទាំងអស់គ្នា មិនមែនទៅតែយើងមួយទេ ទៅគ្រប់គ្នា ចាស។

**ស៖** អ៊ីចឹង ខ្ញុំយល់ជាការត្រឹមត្រូវទេ មានន័យថា សាងសង់រោងហ្នឹងហើយ គឺប្រជាជនទាំងចាស់ ទាំងថ្មី គេឲ្យចូលទៅនៅក្នុងរោងហ្នឹង?

**ឆ៖** ទាំងចាស់ ទាំងថ្មី គេឲ្យនៅរោងហ្នឹងហើយ ឲ្យនៅរោងហ្នឹងហើយ គេចាប់ប្រមូលកម្លាំងធ្វើការងារពលកម្ម។ ចាប់ពីយើងសាងសង់ខ្ទមឲ្យនៅហើយ ចាស។

[១៤:១០:៣៤]

**ស៖** ចាស សូមអរគុណ។ ហើយលោកស្រីថា ប្ដីរបស់លោកស្រីត្រូវបានគេយកទៅសម្លាប់។ ចង់ឲ្យលោកស្រីបញ្ជាក់បន្តិច តើប្ដីរបស់លោកស្រីហ្នឹងមានទំនាក់ទំនងអ្វីជាមួយនឹងរបប លន់ នល់? បើសិនជាគាត់មាន ថាតើគាត់មានតួនាទី ឬក៏ឋានៈអ្វីដែរ?

**ឆ៖** ចាស តួនាទីគាត់ គឺគាត់ធ្វើជាពេទ្យទាហាន។ គាត់ពេទ្យព្យាបាលពួកទាហានដែលនៅសមរភូមិត្រូវគ្រាប់។ ចាស គាត់ មុខគាត់ព្យាបាលទាហានត្រូវគ្រាប់។ អ្នកជំងឺទាហានទាំងអស់ គាត់ព្យាបាល។ គាត់នៅពេទ្យបុរីកីឡា ហើយនិងពេទ្យៗ -- ពេទ្យនៅបៀតខាងជើងផ្សារថ្មី ពេទ្យអីហើយទេ។ ខ្ញុំភ្លេចឈ្មោះពេទ្យហ្នឹងហើយ ពេទ្យកេតុមាលា។ ពេទ្យកេតុមាលានៅនុ៎ង។ ពី -- គាត់ធ្វើការនៅកន្លែងមន្ទីរពេទ្យហ្នឹង។

[១៤:១២:០០]

**ស៖** ចាស សូមអរគុណ។ ហើយពាក់ព័ន្ធនឹងប្ដីរបស់លោកស្រីដែរ។ នៅពេលដែលលោកស្រី ហើយនិងក្រុមគ្រួសារត្រូវបានជម្លៀសទៅដល់ស្រុកត្រាំកក់មុនដំបូងនោះ ថាតើគេមានបង្គាប់ឲ្យ ឬក៏ ហៅលោកស្រីឲ្យទៅធ្វើប្រវត្តិរូបសង្ខេប ឬក៏សរសេរជាប្រវត្តិរូបអីទេ ពេលហ្នឹង?

**ឆ៖** គេហៅធ្វើប្រវត្តិរូបពីរដង បញ្ជូនទៅដល់ស្រុកត្រាំកក់ហ្នឹង នៅពោធិ៍(ព្រះ)សង្ឃហ្នឹង ធ្វើ ប្រវត្តិរូបម្ដង។ ដល់មកប្រមូលភូមិមកនៅខ្ទមហ្នឹង ធ្វើប្រវត្តិរូបម្ដងទៀត។ ធ្វើប្រវត្តិរូបហើយម្ដងទៀត ថាគាត់អត់មានធ្វើការទេ គាត់ធ្វើពេទ្យ ព្យាបាលរបួស និងធ្វើពេទ្យ។ ប្រាប់អ៊ីចឹងហើយ ដល់ហើយ គេ ថ្ងៃក្រោយទៀត គេមកឆែក។ ឆែកឆេរក្នុងខោអាវហ្នឹង ដែលមានដោយរូបថត។ រូបថតហ្នឹង ថតទើប តែថតកាលមុនឆ្នាំហ្នឹង ហើយដាក់ក្នុងខោប៉ាវហ្នឹង មិនទាន់បានយកចេញ។ ហើយដល់ពេល គេវាយៗ រំដោះបែកទៅ ក៏អាខោអាវប្រមូលញាត់ក្នុងស្បោងសហ្នឹង ក៏យកមក។ យកមក ក៏ចាក់ជជុះទៅ ឃើញ រូបថត ចាស។

[១៤:១៣:២៤]

**ស៖** លោកស្រីថា គេឲ្យធ្វើប្រវត្តិរូប។ តើប្រវត្តិរូបហ្នឹង គេតម្រូវធ្វើគ្រប់គ្នា មនុស្សនៅក្នុងភូមិ ឬក៏មានការបែងចែកប្រជាជនចាស់ ប្រជាជនថ្មី ត្រូវតែធ្វើដែរ?

**ឆ៖** ប្រជាជនចាស់មានតួនាទីអីត្រូវធ្វើប្រវត្តិរូប។ ប្រជាជនចាស់គេមកធ្វើប្រវត្តិរូបយើងអ្នក ថ្មី។ ប្រជាជនចាស់អត់មានទេ គេ ប្រវត្តិរូបគេមានតាំងពីឆ្នាំ៧១, ៧២ មករហូត។ ហើយយើងនេះ ៧៥ នេះ ១៧មេសានេះ យើងចុះទៅ គេត្រូវធ្វើប្រវត្តិរូបទាំងអស់ ចាស។

**ស៖** អ្នកណាជាអ្នកធ្វើប្រវត្តិរូប? លោកស្រីធ្វើខ្លួនឯង? សរសេរខ្លួនឯង ឬក៏មានអ្នកណាជួយ ធ្វើ ហើយអ្នកណាជាអ្នកប្រាប់ឲ្យធ្វើ?

**ឆ៖** ប្រធានភូមិៗ អនុប្រធានភូមិ អាស្មីគេ នារីៗគេទៀត គេដើរមក ដើរសួរប្រវត្តិរូបយើង ហ្នឹង មានគ្នាបីនាក់។ គេធ្វើខ្លួនគេ គេកត់ខ្លួនគេ យើងអត់មានតួនាទីអីកត់ យើងមានប៊ិក មានសៀវភៅ មកពីណា អត់មានទេ។ យើងរត់ទៅបាត់ដៃទទេ។

**ស៖** ចាស បន្ទាប់ពីធ្វើប្រវត្តិរូបហើយ បើដឹងថាជាប្រជាជនថ្មី ឬប្រជាជនចាស់ ប្រជាជនមូល ដ្ឋានហ្នឹង ថាតើមានការប្រព្រឹត្តដូចគ្នាដែរឬទេ ចំពោះប្រជាជនចាស់ និងប្រជាជនថ្មី?

**ឆ៖** ប្រជាជនចាស់ និងប្រជាជនថ្មីមានខុសៗគ្នាដោយឡែកដាច់ពីគ្នា។ ពួកគេពួកមូលដ្ឋាន ពួក

យើងពួក១៧មេសារង់ចាំតែថ្ងៃដែលយើងមានកំហុស គេនឹងយកយើងទៅរៀនសូត្រៗ គឺអ្នកថ្មីយកទៅសម្លាប់ គេយកអ្នកថ្មីយកទៅសម្លាប់ចោល។ អ្នកចាស់អត់ដែលមានឃើញបាត់ម្នាក់សោះតាំងពីខ្ញុំទៅនៅហ្នឹងប្រមាណ៣ឆ្នាំ៨ខែ២០ថ្ងៃ អត់មានដែលបាត់អ្នកចាស់ទេ បាត់តែអ្នកថ្មីរហូតចាស។

**ស៖** តើខ្ញុំយល់ជាការត្រឹមត្រូវទេ នៅពេលដែលលោកស្រីថាមានការ តាមមើលតាមដានប្រជាជនថ្មីហ្នឹង។ មានន័យថាប្រជាជនថ្មីត្រូវប្រព្រឹត្តឲ្យសមរម្យ បើមិនអ៊ីចឹងទេ អាចនឹងងាយបាត់ខ្លួនឬក៏យ៉ាងណា?

[១៤:១៦:១២]

**ឆ៖** ចាស ជាការពិត បើយើងប្រព្រឹត្តធ្វើមិនសកម្ម មិនខ្លាំងក្លា គឺបាត់ខ្លួនដោយងាយ។ ហើយបើយើងមិនជម្រុះជម្រះពាក្យហៅ “ម៉ាក” ហៅ “ប៉ា” ហ្នឹងទេ ក៏បាត់ខ្លួនដែរ។ ចាស អាហ្នឹងប្អូន -- បងជីដូនមួយខ្ញុំហ្នឹង ប្អូនគាត់ហៅ “ម៉ាក-ប៉ា” ចាស។

**ស៖** ពាក់ព័ន្ធទៅនឹងឪពុកម្តាយបង្កើតរបស់លោកស្រី ថាតើឪពុករបស់លោកស្រីមុនរបបខ្មែរក្រហមហ្នឹងគាត់មានតួនាទី ហើយនិងឋានៈអ្វីដែរ? ឬក៏ជាប្រជាជនធម្មតាទេ?

**ឆ៖** គាត់មានឋានៈជាមន្ត្រីរាជការចៅសង្កាត់ឃុំលាយបូរចាស។

**ស៖** ចៅសង្កាត់លាយបូរហ្នឹង មានន័យថាគាត់ជាមន្ត្រីរដ្ឋការនៅក្នុងរបប លន់ នល់។ តើខ្ញុំនិយាយអ៊ីចឹង តើត្រឹមត្រូវដែរឬទេ?

**ឆ៖** មាន -- គាត់មានធ្វើមន្ត្រីរាជការហ្នឹងតាំងពីសង្គមរាស្ត្រនិយម។ សង្គមរាស្ត្រនិយមចូលមកដល់សង្គម លន់ នល់ ចាស ពីរជំនាន់នោះ គាត់ធ្វើយូរហើយ។

**ស៖** ចាស សំណួរមួយចុងក្រោយដែលខ្ញុំចង់សួរទៅលោកស្រីគឺពាក់ព័ន្ធទៅនឹងស្ថានភាពនៃការលំបាករបស់លោកស្រីនៅក្នុងរបបខ្មែរក្រហមនោះ។ លោកស្រីបានប្រាប់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក៏ដូចជាអង្គសវនាការកាលពីព្រឹកមិញថា ជីវភាពនៃការរស់នៅនៅរបបខ្មែរក្រហមនោះ គឺប្រជាជនថ្មីនិងប្រជាជនចាស់ហ្នឹង រស់នៅ គឺការទទួលទានអាហារគឺមិនដូចគ្នានោះទេ។ ថាតើការទទួលទានអាហារមិនដូចគ្នាហ្នឹង ថាតើមានការបែងចែងអ្វីដែរឬទេ? ហើយទំហំការងារដែលគេចែកឲ្យប្រជាជនថ្មីនិងប្រជាជនចាស់ហ្នឹង វាដូចគ្នាដែរឬក៏មានលក្ខណៈខុសគ្នាដែរ?

**ឆ៖** ចាស ខ្ញុំបានជម្រាបហើយថា ប្រជាជនថ្មីនិងប្រជាជនចាស់ទៅធ្វើការនៅលេណដ្ឋានដូចគ្នា តែរបៀបរបបហូបខុសគ្នាដោយសារផ្ទះគេមានៗ អ្វីៗដែលគេបម្រុង ហើយយើងអ្នកថ្មីអត់មានអ្វីទេ

យើងអាចហូបបានប៉ុន្មានប៉ុណ្ណឹងហើយ។ ហើយធ្វើការនៅលេណដ្ឋានដូចគ្នា។ យើងត្រូវអត់ឃ្លាន។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស អរគុណលោកស្រី។ ខ្ញុំអស់សំណួរ ហើយសូមផ្តល់វេទិកាបន្តឲ្យទៅសហការីអន្តរជាតិរបស់ខ្ញុំ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ។

[១៤:១៩:៣៦]

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលើ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម មេធាវីការពារក្តី លោកស្រី គឹមឡុន ចំពោះវត្តមានរបស់លោកស្រីនៅរសៀលនេះ។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលើ៖**

**ស៖** សំណួរដំបូងរបស់ខ្ញុំ គឺសួរបន្តពីសំណួរដែលសហការីរបស់ខ្ញុំទើបតែបានសួរ។ លោកស្រីបាននិយាយថាប្តីរបស់លោកស្រីជាគ្រូពេទ្យយោធានៅក្នុងរបបលន់នល់។ តើ<>ប្តីលោកស្រីមានបុណ្យស័ក្តិប៉ុនណាដែរ មានឋានន្តរសក្តិប៉ុនណាដែរ?

**លោកស្រី ជូ គឹមឡុន៖**

**ឆ៖** ឋានន្តរសក្តិតូចល្មមទេ។ ស័ក្តិ៣ ស័ក្តិ៤ ចូលឆ្នាំ ប៉ុន្តែមិនទាន់បានប្រើស័ក្តិ៤ ទេ។ តែដល់មកក្នុងរបបខ្មែរក្រហមហ្នឹង គេអាពួកល្ងង់ៗ គេថាប្តីខ្ញុំផ្កាយ១។ មានទោសធ្ងន់ដល់ថ្នាក់ផ្កាយ១ទៀត។ គេយកទៅសម្លាប់អត់មានញញើតដៃអីទេ។ ខ្មែរ អ្នកយកទៅគឺខ្មែរៗមកពីពាណិជ្ជ មកពីសាលាឃុំ ហើយនិងប្រធានភូមិ ប្រធានភូមិក្នុងភូមិហ្នឹង។ បីនាក់មកពីសាលាឃុំ ស្ពាយកាំភ្លើងមាន --ថាពីរនាក់ទៀត។ អាហ្នឹងពេលខ្ញុំចាប់ -- ពេលទៅយកខ្ញុំឃើញតែបីនាក់ទេណា តែដល់ពេលបែកហើយៗ ០៧ មេសា(?) ៧៩ ខ្ញុំបានកោះហៅប្រធានភូមិហ្នឹងមកសាកសួរនៅសាលាឃុំ។ គេថាគេអត់បានសម្លាប់ផ្ទាល់ដៃទេ មានឈ្លបមកពីសាលាឃុំពីរនាក់ទៀត អ្នកយកបន្ត។ តែនេះជាពាក្យដោះសាយករួចខ្លួនទេ។ ទៅទាំងអស់គ្នា ពីរនាក់ហ្នឹងហើយនិងតាប្រធានភូមិហ្នឹង បីនាក់ហ្នឹងទៅទាំងអស់គ្នា។ ចាស ខ្ញុំបានកោះហៅមកសួរហើយ។ កាលបែកយើង ៧៩ រៀតណាមចូល។

[១៤:២២:០១]

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំសូមសួរសំណួរមួយចំនួនអំពីការចុះមកពិនិត្យរបស់មេដឹកនាំខ្មែរក្រហម ដែលលោកស្រីបានលើកឡើងនេះដើម្បីចង់បានព័ត៌មានលម្អិតបន្តិចអំពីដំណើរទស្សនកិច្ចរបស់មេដឹកនាំទាំងនោះ។ សូមលោកស្រីជម្រាបជូនអង្គជំនុំជម្រះ តាមដែលអាចចងចាំប្រាប់ទៅបានថាតើមេដឹកហ្នឹងមកការដ្ឋានការងារនោះនៅពេលណា ដែលលោកស្រីបានឃើញនោះ?

**ឆ៖** គាត់នៅការដ្ឋានអូរចំបក់ នៅខាងលិច នៅខាងកើតថ្នល់រទេះភ្លើងហ្នឹង ខាងលិចផ្ទះតាម៉ុកហ្នឹងឆ្នាំ១៩៧៧ តែខ្ញុំមិនចាំខែទេ មិនដឹងជាខែ៣ ខែ៤ ឬខែ៤ ខែ៥ ទេ អត់បានចាំខែទេ ព្រោះយើងជំនាន់ហ្នឹងដឹងតែខាំងប្រាំង ខែក្ដៅគេជីកប្រឡាយ ជីកប្រឡាយប្រុក ចាស។ ហើយឃើញគាត់ទៅពិតប្រាកដមែន។ គាត់ទៅបំផុសបំផុលចលនាដើម្បីពង្រឹងពង្រីកគោលនយោបាយរបស់គាត់។ គាត់ជាអ្នកកាច់ចង្កូតនាវាប្រទេសកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ តែគាត់កាច់ចង្កូតដោយកាច់ខុស កាច់ពន្លិច។ ខ្ញុំសន្និដ្ឋានអ៊ីចឹង គាត់កាច់ខុស ចាស។ ខ្ញុំចង់ដឹងតើគាត់បានឆ្លើយកាលថ្ងៃ០៧ ខែ៨ តើគាត់ថាគាត់មិនបានដឹងដែលមានសម្លាប់ប្រជាជនដូច្នេះទេ។ តើមូលហេតុអ្វីបានជាគាត់និយាយពាក្យអស់ទាំងនេះ? ព្រោះសម្លាប់ប្រជាជនហ្នឹងចាប់តាំងពីយើងបែកភ្នំពេញមករហូតវា ៣ឆ្នាំ ៨ខែ ២០ថ្ងៃ។ ហើយគាត់ឆ្លើយថាអត់ដឹង។ បើថាសម្លាប់ត្រឹមតែមួយខែ ឬក៏កន្លះឆ្នាំក៏មិនថា អ៎! មួយឆ្នាំ ឬក៏កន្លះមិនថាទេ តែសម្លាប់ជាយូរ យូរយាររចង់វាលមនុស្ស។ រាប់លាននាក់ដែលប្រជាជនខ្មែររងគ្រោះដោយស្លាប់ ដោយស្នាដៃខ្មែរសម្លាប់ខ្មែរគ្នាឯង។ ចាស តើមូលហេតុអី ខ្ញុំចង់ឲ្យគាត់បំភ្លឺរឿងនេះ តើមានអ្នកណានៅពីក្រោយខ្នងគាត់ទៀតក្រៅពីគាត់? ចាស ខ្ញុំអស់សំណួរ។

[១៤:២៤:៣៩]

**ប្រធានអង្គជំនុំ៖**

លោកស្រី ឆ្លើយតបទៅនឹងសំណួរដែលភាគីពាក់ព័ន្ធសួរលោកស្រីទៅបានហើយ។ ហើយសិទ្ធិចុងក្រោយលោកស្រីមានសិទ្ធិក្នុងការតាំងសំណួរ សួរនៅនាទីចុងក្រោយនៃកិច្ចដំណើរការស្ដាប់សក្ខីកម្មរបស់លោកស្រី អង្គជំនុំជម្រះនឹងផ្ដល់ឱកាសក្នុងការតាំងសំណួរ។ អ៊ីចឹងកុំឲ្យមានការច្របូកច្របល់រវាងអំឡុងពេលនៃលោកស្រីដែលត្រូវផ្ដល់សក្ខីកម្មនៅពេលនេះ ហើយនិងពេលវេលាដែលលោកស្រីទទួលសិទ្ធិក្នុងការតាំងសំណួរទៅជនជាប់ចោទ។ អ៊ីចឹងសូមលោកស្រីតម្រង់នូវស្មារតីរបស់លោកស្រីដើម្បីស្ដាប់នូវសំណួរឲ្យបាន ហើយឆ្លើយតបទៅនឹងភាពចាំបាច់នៃវិសាលភាពនៃសំណួរដែលសួរទៅបានហើយ។ កាលណាដែលលោកស្រីនិយាយច្រើនពេកទៅវាអាចមានបញ្ហា វាចេញ ចាកចេញពី ផុតពី

សំណួរដែលវាមិនៗមែនជាភាពចាំបាច់ក្នុងការឆ្លើយតបនោះទេ ដើម្បីយើងបង្កើនល្បឿនកិច្ចដំណើរការនីតិវិធីសវនាការយើងឲ្យអស់លទ្ធភាព និងទៅតាមពេលវេលាដែលយើងបានកំណត់ ព្រោះយើងកំណត់ច្បាស់លាស់ក្នុងការស្តាប់សក្ខីកម្មសាក្សីមួយៗ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗហ្នឹង យើងបានកំណត់ច្បាស់លាស់ដើម្បីឲ្យការពិភាក្សាដេញដោលហ្នឹងបានលឿន។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា អាចបន្តសំណួរតទៅទៀត!

[១៤:២៦:៥៥]

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** លោកស្រី គឹមឡួន តើមានប្រជាជនប្រហែលជាប៉ុន្មាននាក់នៅឯការដ្ឋានការងារហ្នឹងនៅពេលដែលមេដឹកនាំចុះទៅមើលហ្នឹង?

**លោកស្រី ជូ គឹមឡួន៖**

**ឆ៖** ច្រើន ច្រើនណាស់ មិនដឹងប៉ុន្មានរយនាក់ទេ ច្រើន។ មួយឃុំលាយបូរ មកកន្លែងហ្នឹងទាំងអស់ កន្លែងការដ្ឋានអូរចំបក់ ស្ពានយ័យហ្នឹង។ ឃុំលាយបូរ គេចាត់តែកម្លាំងខ្លាំងៗ មកកន្លែងការដ្ឋានហ្នឹងទាំងអស់ ព្រោះត្រូវការជីកយកជម្រៅបូមទឹកចាស។ ច្រើនមិនអាចសន្និដ្ឋានបានទេ បើសន្និដ្ឋានស្មានៗប្រហែលជាបីបួនរយនាក់។

[១៤:២៦:៥៩]

**ស៖** សូមអរគុណហើយ។ លោកស្រីបានឃើញមេដឹកនាំទាំងនោះធ្វើអ្វីដែរនៅពេលដែលពួកៗគាត់ទៅទីនោះ?

**ឆ៖** ពួកគាត់ទៅ អត់មានធ្វើអ្វីទេ គាត់ដើរតាមប្រឡាយ គាត់ចង្អុលដៃខ្វាត់ខ្វែងៗ ហ្នឹងថា "នែ៎! អាប្រឡាយហ្នឹងជីកជ្រៅបូមទឹកទៅដាក់ស្រែ ដាក់ស្រែឲ្យបានធ្វើឲ្យបានស្រូវច្រើន ឲ្យបាន១ហិកតា ៣តោន ទៅ៦តោន"។ គាត់ដើរនិយាយជាមួយប្រធានភូមិ ហើយនិងគណៈឃុំ ដើរបណ្តើរគ្នានិយាយអ៊ីចឹងទៅ។ ហើយតាម៉ុក គាត់បានប្រាប់ទៅទៀតថា "យកទឹកត្នោត គេរែកទឹកត្នោតមកចែក" ពេលហ្នឹងគេកំពុងតែរែកទឹកត្នោតមកចែក ម៉ោងប្រហែលប្រាំបួនជាង គេរែកទឹកត្នោតចែក។ តាម៉ុកថា "អើ! ទឹកត្នោតធ្វើឲ្យផ្អែម ដាក់ -- បើរកពេលដាក់មិនបាន ដាក់ថែមស្ករមួយចំណិតៗ"។ ខ្ញុំចាំច្បាស់ហើយ តា

ម៉ុក គេឲ្យយកទឹកត្នោតឲ្យហូប។ ចាសគាត់ទៅជាមួយគ្នា។ មិនដឹងគាត់ទៅប្រជុំគ្នា ជំនុំគ្នានៅកន្លែងណាទៀត ខ្ញុំអត់ដឹងទេ ព្រោះខ្ញុំនៅប្រឹងរែកដីហ្នឹង គាត់បណ្ដើរគ្នាទៅហើយ ចាស។

**ស៖** សូមអរគុណ។ ហើយសូមលោកស្រីជម្រាបជូនតុលាការបន្តិចឲ្យបានលម្អិតបន្តិចអំពីអង្គប្រជុំ កិច្ចប្រជុំដែលលោកស្រីទើបតែនិយាយអម្បាញ់មិញហ្នឹង?

**ឆ៖** កិច្ចប្រជុំនិយាយអម្បាញ់មិញ -- សូម។ អ៎! សូមម្ដងទៀត។ ចង់សួរពីសំណួរអ្វីសុំម្ដងទៀត អត់ទាន់យល់។

**ស៖** លោកស្រីទើបនិយាយអំពីអង្គប្រជុំ ដែល។នៅពេលដែលមេដឹកនាំហ្នឹងទៅហ្នឹង គេមានប្រជុំ តើគេប្រជុំអំពីអីដែរលោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះបន្តិចមក?

[១៤:២៩:១៧]

**ឆ៖** មេខ្មែរដឹកនាំដែលទៅហ្នឹងគេអត់មាន -- ខ្ញុំអត់មានត្រូវការអីទៅទេណា គេហៅទៅតែគណៈឃុំ ហើយនិងមេកង ប្រធានកងទៅតាម ទៅតាម។គាត់ទាំងអស់ តែខ្ញុំនៅរែកដីចម្ការធម្មតា។ ដល់ពេលយើងហូបបាយហើយ ពេលថ្ងៃត្រង់ គេប្រជុំប្រាប់យើងថា ឲ្យយើងហ្នឹងពង្រឹងគោលជំហរប្រឹងរែកឲ្យឆាប់ហើយក្នុងរវាងរយៈពេល១០ថ្ងៃ ឬក៏កន្លះខែទេ ភ្លេចបាច់ហើយ ឲ្យពង្រឹងគោលជំហរជីកអាហ្នឹងឲ្យឆាប់ ទ្បាលនឹងដកទៅមួយកន្លែងទៀត។ តែគាត់មក មិនដឹងជាប្រជុំអីប្រាប់មេកងខ្ញុំ អត់ដឹងទេ ចាស។

**ស៖** សូមអរគុណច្រើន។ នៅក្នុងសំណុំរឿងឯកសារ E3/135 ចុះថ្ងៃទី៣0 ខែមិថុនា ១៩៧៧ <គណៈកម្មាធិកាមជ្ឈិមបក្ស>បានផ្ដល់ទង់<ក្រហម>កិត្តិយសទៅដល់ស្រុក<គំរូបី> ដែលត្រូវបានប្រកាសនៅតាមវិទ្យុនាពេលនោះ។ យើងអាចរកឃើញនៅក្នុងឯកសារ E3/289 ចុះថ្ងៃទី២៣ ខែកក្កដា ១៩៧៧។ ERN ជាភាសាអង់គ្លេស 00168509 ដល់ 11 ប៉ុន្តែមិនទាន់មានការបកប្រែនៅឡើយ<ទេ តែ>មានសំណើ<ឲ្យ>បកប្រែ<ហើយ>។ <សំណួរ>របស់ខ្ញុំ<ចំពោះ>លោកស្រីគឺ តើលោកស្រី<> អាចនឹកឃើញទេ ធ្លាប់ដែលស្ដាប់ឮតាមវិទ្យុដែលគេបានផ្ដល់មេដាយកិត្តិយស ឬក៏ទង់កិត្តិយសទៅឲ្យស្រុកត្រាំកក់ទេ?

[១៤:៣១:៣៥]

**ឆ៖** ផ្ដល់កិត្តិយស ខ្ញុំអត់បានឮ អត់មានដឹងទេ ព្រោះខ្ញុំ -- អ៊ូ! ដឹង នឹកឃើញហើយ។ គេថាស្រុកត្រាំកក់ ១០៥ហ្នឹង ជាស្រុកដែលមាន។ វាល្អ។ជាងគេ។ ស្រុកត្រាំកក់ ១០៥ហ្នឹងល្អណាស់ គេ

បានភោគផលច្រើន។ តែមេដាយអីៗ កិត្តិយសទង់ជាតិអី ខ្ញុំអត់ដឹង ឮតែមេកងថា "អង្គការថ្នាក់លើ គេសរសើរស្រុកត្រាំកក់" ថាស្រុកត្រាំកក់ហ្នឹងធ្វើពលកម្មបានល្អ ទាំងផងស្រូវ ទាំងប្រព័ន្ធប្រឡាយសព្វទាំងអស់។ ចាស អាហ្នឹងក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងចាស។

**ស៖** លោកស្រី គឹមឡុន លោកស្រីនៅនឹកឃើញបានទេ ការទៅធ្វើទស្សនកិច្ចរបស់មេដឹកនាំជាន់ខ្ពស់<នោះ> មុនពេល<លោកស្រីបានដឹងថា>ស្រុកត្រាំកក់បានទទួលទង់ក្រហមកិត្តិយសហ្នឹង<> ឬក៏ក្រោយ<មកទៀត>?

**ឆ៖** ចាស ទទួលទង់ហ្នឹង ខ្ញុំអត់ដឹងទេ ដល់គេនិយាយប្រាប់ខ្ញុំហ្នឹង។ និយាយប្រាប់ខ្ញុំហ្នឹង មិនដឹងជាថ្ងៃណា ប៉ុន្តែ១៩៧៧ – ៧៧ ពេលយើងកំពុងសម្រុកការងារហ្នឹង។ ប៉ុន្តែមិនដឹងជាខែណា ថ្ងៃណា ទង់អីក៏មិនដឹង គ្រាន់តែដឹងគេថា អង្គការសរសើរ។ ហើយមីទ្ទិងឲ្យយើងប្តេជ្ញា កុំឲ្យយកជើងទៅខ្មាស់នឹងកងប្រវត្តិសាស្ត្រ។

**ស៖** សូមអរគុណលោកស្រី គឹមឡុន។ ខ្ញុំសូមបន្តទៅមុខទៀត បន្តទៅប្រធានបទផ្សេងពីនេះ លោកស្រីបានជម្រាបជូនអង្គជំនុំជម្រះកាលពីព្រឹកមិញ ក៏ដូចជារសៀលនេះខ្លះៗហើយ អំពីការចាប់ខ្លួនប្តីរបស់លោកស្រី។ សូមលោកស្រីជម្រាបជូនអង្គជំនុំជម្រះមើល តើលោកស្រីដែលមានបានឃើញអ្នកដែលគេចាប់<>ណាម្នាក់ក្រៅពីប្តីលោកស្រីហ្នឹងទៀតទេ នៅក្នុងសហករណ៍របស់លោកស្រីហ្នឹង?

[១៤:៣៤:២៣]

**ឆ៖** គេចាប់យកទៅពេលយប់ យើងអត់មានឃើញទេ តែព្រឹកឡើងបានគេខ្សឹបគ្នាលាន់តែម្តងថាគេយកឈ្មោះហ្នឹងទៅបាត់ហើយ គេយកទៅបាត់ហើយ។ ពេលព្រឹកយើងទៅការដ្ឋាន គេខ្សឹបប្រាប់ហើយ គេយកៗតែពេលយប់ អត់មានយកថ្ងៃឲ្យយើងឃើញទេ។ ផ្ទះជាប់គ្នា រំលងមួយ រំលងពីរក៏គេអត់ឲ្យឮសូរដែរ យកទៅដោយស្ងាត់ៗ។

**ស៖** តើខ្ញុំយល់ត្រឹមត្រូវដែរឬទេថា ក្រោយពីការចាប់ខ្លួននៅពេលយប់ហ្នឹង ហើយព្រឹកឡើង<លោកស្រីនឹងបាន>ដឹងថាគេបានចាប់ខ្លួនអ្នកណាម្នាក់ពីយប់មិញ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ដឹងអ៊ីចឹង ដឹងគ្រប់គ្នា ភ័យៗណាស់ម្នាក់ៗពេលយប់អត់ហ៊ាននិយាយគ្នាទេ តែនិយាយគ្នាខ្លាចមានខុសគេលបស្តាប់។ គេដើរកៀនៗខ្ទមយើងហ្នឹង លបស្តាប់យើងជំនុំគ្នាអីខ្លះ ចាសពិសេសអ្នកផ្ទះដែលមានប្តីប្រពន្ធ លបស្តាប់មាំណាស់។ ហើយបើផ្ទះខ្ញុំអ្នកមេម៉ាយ ខ្ញុំមេម៉ាយ គេស្តាប់ដែរប៉ុន្តែមិនសូវញឹកញាប់ដូចផ្ទះមានប្តីប្រពន្ធទេ។ យកទៅគេសុទ្ធតែជាការពិតទាំងអស់ យកទៅៗរៀនសូត្រនៅ

ក្រាំងតាចាន់មិនដឹង នៅកន្លែងណាក៏មិនដឹង យកទៅបាត់ៗរហូតចាស។

**ស៖** តើលោកស្រីអាចប៉ាន់ប្រមាណចំនួនមនុស្សដែលលោកស្រីដឹងថាគេបានចាប់ខ្លួននៅក្នុងសហករណ៍របស់លោកស្រីដែរឬទេ?

[១៤:៣៦:២៤]

**ឆ៖** ដឹងប៉ុនភ្លេចឈ្មោះបាត់ហើយ។ ចាប់ខ្លួននៅភូមិខ្ញុំហ្នឹង ពីរនាក់ ប៉ុន្តែខ្ញុំភ្លេចឈ្មោះបាត់ហើយ បើ៣៦ឆ្នាំ មួយខែទៅហើយចាស។

**ស៖** សូមអរគុណលោកស្រី គឹមឡួន តើប្រជាជនថ្មីជាទិសដៅនៃការចាប់ខ្លួនខ្លាំងជាងពួកប្រជាជនចាស់ដែរឬទេ?

**ឆ៖** ខ្លាំងៗមែនទែន។ ប្រជាជនចាស់តាំងពីខ្ញុំចូលនៅ ពីចេញពីភ្នំពេញទៅនៅៗស្រុកត្រាំកក់ហ្នឹងអត់មានឃើញបាត់ប្រជាជនចាស់ផង បាត់តែប្រជាជនថ្មីរហូតចាស។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

សូមអរគុណលោកស្រី គឹមឡួន។ លោកប្រធាននៅក្នុងសំណុំរឿងនៅក្នុងឯកសារ E3/4083 គឺជាបញ្ជីអ្នកទោសចេញមកពីក្រាំងតាចាន់ មន្ទីរសន្តិសុខក្រាំងតាចាន់ ដែលដាក់បញ្ចូលបុគ្គលមួយចំនួនដែលគេចាត់ទុកថាមកពីភូមិកំណើតរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺធ្នង់រលើង។ ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារនេះទៅដើមបណ្តឹងរដ្ឋប្បវេណីថាតើគាត់ស្គាល់អ្នកណាខ្លះនៅក្នុងបញ្ជីនេះដែលមកពីភូមិរបស់គាត់ដែរឬទេ។ ដូច្នេះសូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបានតុលាការទទួលឯកសារជាក្រដាសពីសហព្រះរាជអាជ្ញារងអន្តរជាតិយកទៅជូនដើមបណ្តឹងរដ្ឋប្បវេណីពិនិត្យ។

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

**ស៖** លោកស្រី គឹមឡួន នៅក្នុងចំណុចដំបូងអង់គ្លេស ERN 00323948, ខ្មែរ ERN 0006 8026, ហើយបារាំង ERN 00778854 លោកស្រីនឹងឃើញឈ្មោះមនុស្ស អ៊ុក ចន ២៨ ឆ្នាំ, ហើយអ៊ុំ គុន ៣៩ឆ្នាំអាយុ, តើលោកស្រីស្គាល់ឈ្មោះមនុស្សទាំងពីរនាក់នេះដែរឬទេ?

**លោកស្រី ជូ គឹមឡួន៖**

**ឆ៖** ឈ្មោះលើធ្លាប់ៗឮឈ្មោះ ធ្លាប់ស្គាល់តាំងពីយើងនៅកងខាងត្បូងសាលាឃុំលាយបូរ

ហើយ គេនៅកងខាងជើង។ ចាសធ្លាប់ឮឈ្មោះ នេះឈ្មោះលើនេះ អ៊ុំ ឆន នេះ។ ចាសធ្លាប់ឮឈ្មោះ នេះ។ ហើយនៅឈ្មោះច្រើនទៀតដែលខ្ញុំស្គាល់ តែមិនដឹងជាមាននៅក្នុងហ្នឹងអត់។ មានឈ្មោះ ងន ឈ្មោះអីទៀត។

[១៤:៤០:១១]

**ស៖** សូមអរគុណលោកស្រី។ អ៊ីចឹង សូមលោកស្រីទៅមើលចំណុចដែលខ្ទាស់ទី២ នៅក្នុងឯកសារហ្នឹង មានឈ្មោះពីរទៀតដែលខ្ញុំចង់សួរលោកស្រី។ អង់គ្លេស ERN 00323961 ដល់ 62, បារាំង ERN 00778865 ដល់ 66, ខ្មែរ ERN 00068030 ឈ្មោះទាំងអស់នោះគឺថា ទេព ថេង គឺអាយុ ៤០ ហើយ ពត ង៉ែត គឺថា អាយុ ៤៦ឆ្នាំ។ តើលោកស្រីស្គាល់ឈ្មោះពីរនាក់នេះទេ បាទ?

**ឆ៖** អត់ស្គាល់ទេ ឈ្មោះពីរនាក់នេះ។ មិនដឹងគេនៅខាងភូមិណា ព្រោះឃុំលាយបូរមានទាំងអស់ ប្រាំបីភូមិ ប្រាំបីកង ភូមិលាយបូរមាន៨កងចាស។ អត់ស្គាល់ទេ លាយបូរហ្នឹង ប្រាំបីកង។

**ស៖** សូមអរគុណលោកស្រី គឹមឡូន។ ហើយខ្ញុំក៏សូមសួរលោកស្រីអំពីថាតើគេធ្លាប់ឱ្យលោកស្រីចូលរួមនៅក្នុងអង្គប្រជុំណាមួយដែរឬទេ នៅពេលដែលធ្វើការនៅសហករណ៍នៅពេលនោះ?

**ឆ៖** អង្គប្រជុំនៅតាមភូមិ ប្រជុំសំលៀងជាញឹកញាប់ តែមីទ្ទិងធំមាន ១០ថ្ងៃម្តង ឬ២០ថ្ងៃម្តង។ អាហ្នឹងមីទ្ទិងធំមាន តាម៉ុក អ្នកទៅ ស្រែកជ័យឃោសអ្នកជំហរចាត់តាំង។ ហ្នឹងមីទ្ទិងធំនៅវត្តលាយបូរ នៅឯកន្លែងព្រៃឈើទាល។ អាហ្នឹងមីទ្ទិង ហើយនៅតាមភូមិញឹកញាប់។ ចាស យើងអ្នកស្តាប់គេ យើងចាំគេប្រើឱ្យប្តេជ្ញា បង្កើនពលកម្ម។ ជម្រុះជម្រះសក្តិភូមិចោល មានតែប៉ុណ្ណឹងទេ យើងអត់មាន--

**ស៖** តើមានអ្នកណាម្នាក់នៅក្នុងអង្គប្រជុំធ្លាប់បានត្អូញត្អែរ ឬតវ៉ាអំពីជីវភាពរស់នៅក្នុងសហ-ករណ៍ដែរឬទេ?

**ឆ៖** ចាស មាន។ ត្អូញថាត្អែរថា "ហូបអត់ឆ្អែត នៅហូបបាយអត់ឆ្អែត ហើយធ្វើស្រែ ខំធ្វើស្រែបានផលច្រើនតែស្រូវដឹកបាត់អស់ អត់មានអីហូប" តើ -- អត់មាននិយាយឱ្យគេឮទេ ត្អូញត្អែរប្រាប់គ្នាយើងទេ តែគេឮគេចាប់យកទៅវ៉ៃចោល។

[១៤:៤៤:០២]

**ស៖** តើលោកស្រីបានដឹងហេតុការណ៍ណាមួយថា នរណាម្នាក់តវ៉ាឬក៏ត្អូញត្អែរនៅក្នុងអង្គប្រជុំ ហើយក្រោយមកត្រូវបានគេចាប់ខ្លួនយកទៅដែរឬទេ?

**ឆ៖** ក្នុងអង្គប្រជុំអត់មានអ្នកណាហ៊ានហើបមាត់មួយសោះ តែពេលមកផ្ទះ តែមានខ្សឹបគ្នា តែ

គេឮអត់បាន។

**លោក ចូហ្វេស អេនឌ្រូ ប៊ិយលី៖**

លោកប្រធាន ខ្ញុំទើបតែបាន -- ខ្ញុំមានសំណួរពីរទៀត ហើយខ្ញុំសូមអនុញ្ញាត ដើម្បីបន្ត។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាតឲ្យបានលឿនបំផុត ហើយសួរខ្លីៗទៅបានហើយណា៎ ពេលវេលាអស់ហើយ។

[១៤:៤៥:០២]

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** បាទខ្ញុំនឹងសួរដោយខ្លីៗ។ លោកស្រី គឹមឡួន សូមលោកស្រីជម្រាបតុលាការ ថាតើ<> លោកស្រីបានដឹងអំពីថាជនជាតិវៀតណាម ឬក្រុមគ្រួសារខ្មែរក្រោមរស់នៅក្នុងឃុំ<>ជាមួយលោកស្រីទេកាលនោះ?

**ឆ៖** ចាសឃើញដោយផ្ទាល់ភ្នែក ស្គាល់ជាមួយគ្នាដោយផ្ទាល់។ ជនជាតិវៀតណាមមួយគ្រួសារ និងជនជាតិកម្ពុជាក្រោម។ និយាយប៉ែឡាំៗ និយាយវៀតណាមក៏ប៉ែឡាំដែរ។ ហើយគ្រួសារមានប្ដីមានប្រពន្ធ។ ស្គាល់ អត់ចេះស្គាល់ផង។ គាត់ស្គាល់ដើរទៅមុខ ហើយយើងគ្រប់គ្នាដើរមកក្រោយ។ ដល់មេកងមេក្រុមអីឃើញអ៊ីចឹង គេក៏ចុចឈ្មោះបញ្ជូនគាត់។ គេទៅប្រាប់គាត់ថា បញ្ជូនគាត់ទៅវៀតណាមវិញ ១៩៧៦។ ចាប់ គេបញ្ជូនគាត់ទៅវៀតណាមវិញ។ តាមការពិត ជាល្បិចពិសពុលដែលគេកុហកបោកប្រាស់។ គេបញ្ជូនគាត់ទៅធ្វើទារុណកម្មសម្លាប់ មិនដឹងជាសម្លាប់នៅឯណាទេ ពីរគ្រួសារ មានកូនតូច មានប្ដី មានប្រពន្ធ រែកអម្រែកទៅ។ មកលាពួកខ្ញុំទៀត ធ្លាប់ស្គាល់ជាមួយគ្នា។ មកលា លាថា "ប្រធានកងគេឲ្យខ្ញុំទៅស្រុកវិញ ខ្ញុំអរណាស់ គេបញ្ជូនខ្ញុំទៅស្រុកវិញ"។ គាត់អរ ហើយគាត់មកលាទៅ ហើយបាត់អត់មានដឹងគេសម្លាប់ឯណា។ ចាសអស់យោបល់។

**ស៖** តើលោកស្រីដឹងដោយរបៀបណាថា ក្រោយមកគេយកអ្នកទាំងនោះៗទៅសម្លាប់?

**ឆ៖** ដឹងដោយរបៀបថា ពួកខ្មែរក្រហមមានចាប់មនុស្សលួចដំឡូង ដកដំឡូងអី ថាយកទៅពេលយប់ ទៅសម្លាប់ចោល។ ដឹងតាមរបៀបហ្នឹង របៀបថាពួកខ្មែរក្រហមមិនអាចបញ្ជូនជនជាតិវៀតណាម កម្ពុជាក្រោមហ្នឹងទៅប្រទេសទេ មានតែយកទៅសម្លាប់ទេ។ ដឹងដោយសារឃើញរបៀបរបបដែលឃោរឃៅ កាប់សម្លាប់រង្គាលហ្នឹង។ ដឹងតាមរបៀបចាស តាមរបៀបហ្នឹង។ យកទៅសម្លាប់ដោយគ្មានគិតអាណិតថា ជីវិតមនុស្សរស់មក ខំរស់ ខំហូបបាយចង់រស់គ្រប់ៗគ្នា តែយកទៅសម្លាប់

ដូចជាសត្វធាតុតិរច្ឆាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី គឹមឡូន។ ឥឡូវនេះ អស់ពេលវេលាសម្រាប់សហព្រះរាជអាជ្ញាហើយ។ ឥឡូវក៏ដល់ពេលសម្រាកហើយដែរ។ អង្គជំនុំជម្រះសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅក្នុង -- រកកន្លែងសម្រាកសមរម្យដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនៅក្នុងរយៈពេលនៃការឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់ផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ ឲ្យបានមុនអង្គជំនុំជម្រះចូលមកកាន់បន្ទប់សវនាការ។ បាទ សម្រាកសិនចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១៤:៤៨ នាទី ដល់ម៉ោង១៥:១០ នាទី)*

[១៥:១១:៥៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគី និងសាធារណជនឲ្យបានជ្រាបថា នៅអំឡុងពេលនៃការឈប់សម្រាកអម្បាញ់មិញនេះ លោក ខៀវ សំផន មានបញ្ហាសុខភាព ដោយសារគាត់សម្ពាធឈាមឡើងខ្ពស់ ហើយនិងអស់កម្លាំង ហើយគ្រូពេទ្យដែលប្រចាំការពិនិត្យថែទាំសុខភាពនៅ អ.វ.ត.ក នេះ បានផ្តល់អនុសាសន៍ថាសូមឲ្យអង្គជំនុំជម្រះសម្រាកត្រឹមនេះ។ ដូច្នេះ អង្គជំនុំជម្រះមិនអាចបន្តដំណើរការសវនាការបានទេ ដោយហេតុថាដំណើរសវនាការនៅ អ.វ.ត.ក នេះ ត្រូវអនុវត្តតាមគោល-ការណ៍ចំពោះមុខ ធ្វើឡើងត្រូវធ្វើនៅចំពោះមុខជនជាប់ចោទ ដោយសារស្ថានភាពគាត់មិនអាចចូលរួមសវនាការបាននៅម៉ោងចុងក្រោយនៅថ្ងៃនេះ ដូច្នេះ អង្គជំនុំជម្រះមិនអាចបន្តបានទេ។ អង្គជំនុំជម្រះលើកសវនាការទៅបន្តធ្វើនៅថ្ងៃស្អែកទៀត។ ហើយក៏អង្គជំនុំជម្រះសូមជម្រាបជូនលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី គឹមឡូន ផងដែរ ថាកិច្ចដំណើរការស្តាប់សក្ខីកម្ម សក្ខីកម្មរបស់លោកស្រីនៅមិនទាន់ចប់នៅឡើយទេ។ គ្រោងថាអាចនឹងចប់នឹងនៅល្ងាចនេះ ប៉ុន្តែមិនអាចចប់បានទេ ដោយសារមូលហេតុដូចបាន

ជម្រាបជូនអម្បាញ់មិញនេះ។ ដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោកស្រីមកបន្តផ្តល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកទៀត។

ហើយចំណុចមួយទៀត អង្គជំនុំជម្រះជម្រាបជូនដល់ភាគីឲ្យជ្រាបផងដែរថាកន្លងមកនេះអង្គជំនុំ ជម្រះទទួលនូវសំណើសុំរបស់មេធាវីការពារក្តី ក៏ដូចជាទទួលនូវអនុសាសន៍របស់អ្នកជំនាញដែលបានវាយតម្លៃបញ្ហាសម្បទាចូលរួមរបស់សវនាការរបស់ជនជាប់ចោទ ហើយដោយសារថាការអង្កេតនិងការកត់សម្គាល់កើតឡើងម្តងហើយម្តងទៀត ចំពោះសុខភាពរបស់លោក ខៀវ សំផន ដែលនាំឲ្យមានការអាក់ខានដល់ដំណើរការប្រព្រឹត្តទៅធម្មតារបស់អង្គជំនុំជម្រះ។ ដូច្នេះ ចាប់ពីស្អែកនេះទៅអង្គជំនុំជម្រះកាត់បន្ថយពេលវេលាសម្រាប់ធ្វើសវនាការ ពេលព្រឹក គឺធ្វើត្រឹមតែពីម៉ោងប្រាំបួន ហើយនិងរហូតដល់ម៉ោងដប់មួយសាមសិបនាទីប៉ុណ្ណោះ ដើម្បីទុកពេលវេលាឲ្យគាត់ពិសាអាហារត្រង់ ហើយនិងបានសម្រាកឲ្យបរិបូរ។ ហើយចំណែកពេលវេលសម្រាក និងពេលប្រព្រឹត្តទៅរសៀល គឺយើងប្រព្រឹត្តទៅដដែល។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងលោកស្រី -- មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនដើមបណ្តឹងរដ្ឋប្បវេណីរូបនេះត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់មកផ្តល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក៕

*(សវនាការផ្អាកនៅម៉ោង ១៥:១៥ នាទី)*